# ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៧នាក់

https://freshnewsasia.com/index.php/en/localnews/288707-2023-04-28-02-41-18.html 2023-04-28 09:41am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន ០៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៦៥ករណី មានមនុស្ស ២,១៥៣នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨២៥សំណើ និងបិទសំណុំរឿង ២៨២សំណើ (រកឃើញមនុស្ស ១,២៣៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣១នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៦៥ករណី៕

## តុលាការកំពូល តម្កល់ទោស ស្ត្រីជាប់ចោទម្នាក់ ជាប់គុក ៧ ឆ្នាំ ពាក់ព័ន្ធនឹងការនាំពលករខ្មែរច្រើននាក់ ទៅធ្វើការនៅប្រទេសថៃខុសច្បាប់

https://cen.com.kh/archives/652879.html Posted ByPen Srey NeatApril 28, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២៣នេះ បានតម្កល់ ទណ្ឌកម្ម ស្ត្រីជាប់ចោទ ម្នាក់ ត្រូវជាប់ពន្ធនាគារ កំណត់ ០៧ ឆ្នាំ ដដែល ជាប់ពាក់ព័ន្ធនឹងបទល្មើស ការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន និង អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅ ព្រំដែនកម្ពុជាថៃ ក្នុងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ប្រព្រឹត្ត កាលពីអំឡុងឆ្នាំ ២០២១ ។

លោក ជីវ កេង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងឲ្យដឹងថា ទណ្ឌិតរូបនេះមានឈ្មោះ ផាង គៀវ ភេទស្រី អាយុ ៣៩ ឆ្នាំ ។ នៅក្នុងសំណុំរឿងនេះ ឈ្មោះ ផាង គៀវ ត្រូវបានសាលាដំបូងខេត្តបាត់ដំបង កាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ : នាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ១១ និង មាត្រា ១២ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។ ឈ្មោះផាង គៀវ ត្រូវបានសមត្ថកិច្ចនគរបាល ចាប់ឃាត់ខ្លួនកាលពីថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០២១ នៅឃុំ សេរីមានន័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង៕ ចន្ទា ភា

## អំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅតែជាបញ្ហាសកលរួមទាំងកម្ពុជា

https://news.btv.com.kh/article/22714 2023/04/28 11:19:17 am

ភ្នំពេញ៖ អង្គការសកម្មភាពដើម្បីកុមារដែលហៅកាត់ថា APLE បានឲ្យដឹងថា អំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅតែជាបញ្ហាសកល រួមទាំងកម្ពុជាផងដែរ បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងសកម្មក្នុងការការពារ និងទប់ស្កាត់ក៏ដោយនោះ។

ថ្លែងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី«ការអនុវត្តបែបកុមារមេត្រី ដើម្បីការការពារកុមាររងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ» នាព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣នេះ នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា នៃក្រសួងយុត្តិធម៌ ដោយមានការចូលរួមពីក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន ជាច្រើនទៀតក្នុងជួររាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិនោះ លោក ផៃ សុភ័ក្រ្ត ប្រធានកម្មវិធីរបស់អង្គការសកម្មភាព ដើម្បីកុមារ បានឲ្យដឹងថា ការរំលោភបំពានលើកុមារនៅតែជាបញ្ហាចោទ ដែលទាមទារឲ្យភាគីពាក់ព័ន្ធ ទាំងអស់រួមគ្នាបង្ការ និងទប់ស្កាត់បន្ថែមទៀត។

លោកបញ្ជាក់ថា«អំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅតែជាបញ្ហាសកល និង នៅព្រះរាជាណាចក្រកម្ពុជា។ ហើយកុមារនៅតែកំពុងប្រឈម នឹងគ្រោះថ្នាក់នៃការរំលោភបំពាន និងកេង ប្រវ័ញ្ចផ្លូវភេទក្នុងរូបភាពផ្សេងៗគ្នា ដែលកើតមាននៅក្នុងគ្រួសារ សហគមន៍ កន្លែងកំសាន្ត និងកេងប្រវ័ញ្ច ផ្លូវភេទតាមប្រព័ន្ធអនឡាញជាដើម ដែលស្ថានភាពទាំងនេះកំពុងបន្តកើតឡើងគួរឲ្យព្រួយបារម្ភ»។ លោក ផៃ សុភ័ក្រ្ត បានបន្តទៀតថា ដោយហេតុថា ភាពរងគ្រោះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទាំងផ្លូវ កាយ ផ្លូវចិត្ត និងអារម្មណ៍របស់កុមារ។កម្រិតនៃការប៉ះពាល់ទង្គិតផ្លូវចិត្តរបស់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ គឺពិបាកក្នុងការវាស់វែង។

លើសជាងនេះទៅទៀត យោងទៅតាមភស្តុតាងនៃការសិក្សាស្រាវជ្រាវ បានឲ្យដឹងថា កុមាររងគ្រោះភាគច្រើនមានអារម្មណ៍ពិបាកក្នុងការទុកចិត្តអ្នកដ ទៃអស់សង្ឃឹម បាក់ទឹកចិត្ត ស្តីបន្ទោសខ្លួនឯង និងធាប់ភ័យខ្លាច ដែលការប៉ះទង្គិចទាំងអស់នេះ ទាមទារ ការព្យាបាលរយៈពេលវែង ឬខ្លីតាមទំហំនៃភាពរងគ្រោះ ដែលផលពិបាកទាំងនេះអាចធ្វើឲ្យពួកគេ បាត់បង់ អនាគត និងក្លាយជាបន្ទុកដ៏ធំសម្រាប់គ្រួសារ និងសង្គមជាតិយើងទាំងមូលផងដែរ។ ទោះជាយ៉ាងណាក៏ដោយទាក់ទងនឹងបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនេះ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ឯកឧត្តម កេង សុម៉ារិទ្ធ បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានកំពុងខិតខំយកចិត្តទុកដាក់យ៉ាងសកម្មបំផុត ដើម្បីបង្ការទប់ស្កាត់នូវអំពើដ៏យង់ឃ្នងនេះ ដោយរាជរដ្ឋាភិបាលបានកំពុងធ្វើសេចក្តី ព្រាងច្បាប់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិកុមារនេះផងដែរ។អត្ថបទ៖ បាន ចក់

## អគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការវីនរ៉ក់អន្តរជាតិចុះ MoU ធ្វើការពង្រឹងសមត្ថភាពមន្ត្រីនគរបាលក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

https://www.postkhmer.com/national/2023-04-27-1754-249453.html រី សុចាន់ | Publication date 27 April 2023 | 17:54 ICT

**ភ្នំពេញ:** អគ្គស្នងការដ្ឋាននគរបាលជាតិ ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយអង្គការវីនរ៉ក់អន្តរជាតិ (Winrock International)ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលជាតិ។ ការចុះMoU នេះធ្វើឡើងនាថ្ងៃទី២៧ ខែមេសា រវាងលោក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ និងលោក ម៉ាក ថេយ៍លឺរ៍ (MarkTaylor) ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៃអង្គការ Winrock International នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាក់ក្រោយពិធីចុះ MoU នេះថា៖ «ឯកឧត្តមអគ្គស្នងការរងនគរបាលជាតិ[លោក ជីវ ផល្លី] បន្តថា ការចុះអនុស្សរណៈនៃការយោគយល់គ្នា(MoU)នេះ គឺសំដៅទៅលើការពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលជាតិ ទាំងនៅនាយកដ្ឋាន និងរាជធានី-ខេត្តដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ចពលកម្មក្នុងគ្រប់រូបភាព ពិសេសអំពើកេងប្រវ័ញ្ចពលកម្មលើកុមារនិងអាជីវកម្មផ្លូវភេទ»។ គេហទំព័រដដែលបញ្ជាក់ថា លោក ថេយ៍លើរ៍ បានថ្លែងអំណរគុណដល់លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ ពិសេសលោក ជីវ ផល្លី ដែលបានសហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីបន្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

គេហទំព័រដដែលបានដកស្រង់សម្ដី លោកថេយ៍លើរ៍ ថា អង្គការវីនរ៉ក់អន្តរជាតិ បានប្ដេជ្ញាចិត្តថា នឹងសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីផ្ដួចផ្ដើមសកម្មភាពបង្ការទប់ស្កាត់តាមរយៈការផ្សព្វផ្សាយ ពីព័ត៌មានហានិភ័យ នៃករណីពលកម្មដោយបង្ខំ និងការគំរាមកំហែងនានា នៃអំពើជួញដូរមនុស្ស ដូចជាការកេងប្រវ័ញ្ចពលកម្មនៅតាមឡជដ្ឋ ក្រុមហ៊ុនជ្រើសរើសពលករ ដែលរំលោភកិច្ចសន្យា និងបោកប្រាស់លុយកាក់»។ លោក ថេយ៍លើរ៍ ត្រូវបានស្រង់សម្ដីទៀតថា សកម្មភាពបង្ការអាចរាប់បញ្ចូលទាំងជំនួយក្នុងសកម្មភាពផ្សព្វផ្សាយច្បាប់ គោលការណ៍ សេចក្តីណែនាំ ប្រកាស និងអនុក្រឹត្យពាក់ព័ន្ធ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព។

លោក ជីវ ផល្លី បានថ្លែងថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន គឺជាសេនាធិការសហការគ្នាក្នុងការកសាងសមត្ថភាពលើការប្រមូលភស្តុតាងទាក់ទងនឹងបទល្មើសនៃអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចពលកម្មនិងពលកម្មដោយបង្ខំលើបុរស ស្ត្រី និងកុមារ។ លោកបន្តថា អង្គការវីនរ៉ក់អន្តរជាតិត្រូវសម្របសម្រួលជាមួយតំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្នុងការរៀបចំប្រធានបទបណ្តុះបណ្តាលដល់មន្ត្រីជំនាញ រួមមាន បច្ចេកទេសស៊ើបអង្កេត ប្រមូលភស្តុតាង ពាក់ព័ន្ធអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត។ លោក ជីវ ផល្លី លើកឡើងថា កិច្ចសហការក្នុងការពង្រឹងសមត្ថភាពរួមមានការពង្រឹងសមត្ថភាពដល់មន្ត្រីស៊ើបអង្កេតនៃការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៅនាយកដ្ឋាននៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងបណ្តារាជធានី-ខេត្តអាទិភាព ដែលមានការចង្អុលបង្ហាញថា ជាតំបន់គោលដៅនៃករណីជួញដូរមនុស្ស។

លោក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ មិនអាចទាក់ទងដើម្បីសុំការបញ្ជាក់បន្ថែមបានទេ នាថ្ងៃទី២៧ ខែមេសា។

អង្គការវីនរ៉ក់អន្តរជាតិ កំពុងអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP) នៅកម្ពុជាដែលផ្ដល់មូលនិធិដោយទីភ្នាក់ងារជំនួយអាមេរិក USAID ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៦ នៅក្នុងខេត្តចំនួន៨ ដែលត្រូវបានវាយតម្លៃថា ជាគោលដៅនៃការជួញដូរមនុស្សដោយសហការជាមួយរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងអង្គការសង្គមស៊ីវិល។

កាលពីឆ្នាំ២០២១ សហរដ្ឋអាមេរិកបានប្រកាសដាក់ឱ្យអនុវត្តគម្រោង CTIP ដែលមានរយៈពេល៥ឆ្នាំនៅកម្ពុជា ដើម្បីដោះស្រាយបញ្ហាឫសគល់ នៃការជួញដូរមនុស្ស ការពារជនងាយរងគ្រោះ ពីការជួញដូរ និងជួយរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនិងគាំទ្រជនរងគ្រោះបន្ថែមទៀតប្រកបដោយប្រសិទ្ធភាព៕

## កម្ពុជា ស្នើសុំថៃ ឈប់ដាក់ខ្នោះច្រវ៉ាក់ចំពោះពលករខ្មែរ ដែលលួចឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/article/1728080.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ឧត្តរមានជ័យ២៨ ខែ មេសា ឆ្នាំ ២០២៣ ម៉ោង ១៧:៥៦

ភ្នំពេញ៖ នៅល្ងាចថ្ងៃទី២៨ ខែមេសានេះ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានប្រកាស ជម្រាបជូននូវបច្ចុប្បន្នភាពអំពីការចាប់ឃាត់ខ្លួន និងដាក់ខ្នោះច្រវ៉ាក់ ចំពោះពលករខ្មែរ ដែលលួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ ដូចតទៅ៖

១. ក្រោយពីទទួលបានព័ត៌មានខាងលើនេះភ្លាម ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ និងស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តសាកែវ បានទាក់ទងអាជ្ញាធរថៃ និងចុះជួបផ្ទាល់ជាមួយពលករខ្មែរខាងលើ ដោយបានទទួលព័ត៌មានថា នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ អាជ្ញាធរមានសមត្ថកិច្ចថៃ បានចាប់ឃាត់ខ្លួនពលករខ្មែរចំនួន ១៤នាក់ ដែលបានលួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ (ក្នុងនោះ មានស្រីចំនួន ៥នាក់) នៅតំបន់ណាត្រាត ខេត្តសាមុតប្រាកាន។

២. នៅពេលបញ្ជូនទៅកាន់មន្ទីរឃុំឃាំង នៅទីក្រុងបាងកក ពលករទាំងនោះ ត្រូវបានអាជ្ញាធរ ថៃ ដាក់ខ្នោះច្រវ៉ាក់ ដោយសារខ្លាចរត់គេចខ្លួន ហើយពួកគាត់ ត្រូវបានអាជ្ញាធរថៃ ដោះខ្នោះច្រវ៉ាក់ចេញវិញ ពេលដល់នៅមន្ទីរឃុំឃាំងបាងកែវ (ទីក្រុងបាងកក)។

៣. តាមការសម្របសម្រួល និងចរចារបស់ស្ថានទូតកម្ពុជា អាជ្ញាធរថៃ នឹងបញ្ជូនពលករខាងលើត្រលប់មកប្រទេសកម្ពុជាវិញ ក្រោយការសួរនាំ និងបំពេញសំណុំឯកសារ ចប់សព្វគ្រប់។

៤. បន្ថែមលើនេះ ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ បានលើកសំណើ ទៅកាន់ក្រសួងការបរទេសថៃផងដែរ ដើម្បីស្នើសុំឱ្យជួយសម្របសម្រួលជាមួយតម្រួតអន្តោប្រវេសន៍ថៃ បន្ថែមទៀត សំដៅជួយពន្លឿនការដោះលែងពលករទាំង ១៤នាក់ខាងលើ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងសូមកុំដាក់ខ្នោះច្រវ៉ាក់បែបនេះទៀត ចំពោះពលករខ្មែរ ដែលលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ព្រោះពួកគាត់ មិនមែនជាឧក្រិដ្ឋជនទេ។ ជាការឆ្លើយតប តំណាងក្រសួងការបរទេសថៃ បានសន្យាថា នឹងពាំនាំសំណើរបស់ស្ថានទូតកម្ពុជា ជម្រាបជូនតម្រួតអន្តោប្រវេសន៍ថៃ៕

# ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០២៣

## សម្តេចក្រឡាហោម ស ខេង៖ បទល្មើសនៃការជួញដូរមនុស្សនៅកម្ពុជាជាង៩០ភាគរយ ប្រព្រឹត្តដោយជនបរទេសដែលយកទឹកដីកម្ពុជាធ្វើសកម្មភាពឆបោកជនជាតិដូចគ្នា

https://www.information.gov.kh/articles/103065 ចេញផ្សាយ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានអញ្ជើញទស្សនកិច្ចសាកលវិទ្យាល័យសន្តិសុខសាធារណៈ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នារសៀលថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣។

ក្នុងឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានជម្រាបជូនថ្នាក់ដឹកនាំសាកលវិទ្យាល័យថា បទល្មើសនៃការជួញដូរមនុស្សនៅកម្ពុជា ជាង៩០ភាគរយ ប្រព្រឹត្តឡើងដោយជនបរទេស ដែលយកទឹកដីកម្ពុជា ដើម្បីប្រព្រឹត្តសកម្មភាពឆបោក ឬអូសទាញជនជាតិដូចគ្នា។ សម្តេចក្រឡាហោមបានលើកឡើងថា ផ្អែកលើបទពិសោធន៍នៃការ

បង្ក្រាបបទល្មើសនេះ កិច្ចសហប្រតិបត្តិការរវាងប្រទេសពាក់ព័ន្ធពិតជាមានសារៈសំខាន់។ នេះបើតាមផេកហ្វេសប៊ុកផ្លូវការរបស់សម្តេចក្រឡាហោម ស ខេង។

សម្តេចក្រឡាហោម ស ខេង និងគណៈប្រតិភូជាន់ខ្ពស់ ក៏បានទស្សនាសារមន្ទីរនៃសាកលវិទ្យាល័យ ដែលបានបង្ហាញពីការកសាង ការបង្កើតសាកលវិទ្យាល័យតាំងពីដំបូងរហូតដល់ពេលបច្ចុប្បន្ន និងបានបង្ហាញពីការវិវឌ្ឍន៍សាកលវិទ្យាល័យរហូតមកដល់បច្ចុប្បន្នផងដែរ។ ដំណើរទស្សនកិច្ចនេះដែរ បានទទួលបដិសណ្ឋារកិច្ចស្វាគមន៍ពីសំណាក់លោកជំទាវ ZENG HAIYAN លេខាធិការគណៈកម្មាធិការបក្សប្រចាំសាកលវិទ្យាល័យ និងលោក Cao Shi Quan លេខាធិការបក្សរង និងជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន។

លោកស្រី ZENG HAIYAN បានគូសបញ្ជាក់ថា ប្រទេសចិន និងកម្ពុជា មានមិត្តភាពយូរលុងណាស់មកហើយ និងថាទំនាក់ទំនងរវាងប្រទេសទាំងពីរ ជាទំនាក់ទំនងគំរូមួយលើឆាកអន្តរជាតិ។ លោកស្រីបានបង្ហាញសេចក្តីសង្ឃឹមជឿជាក់ថា តាមរយៈដំណើរទស្សនកិច្ចរបស់សម្តេច នាឱកាសនេះ ទំនាក់ទំនងរវាងចិន និងកម្ពុជានឹងឈានឡើងកម្រិតថ្មីមួយទៀត។ លោកស្រីក៏បានបញ្ជាក់បន្ថែមថា ក្រោមការដឹកនាំរបស់សម្តេចក្រឡាហោម ស ខេង ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន មានកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដូចជា វិស័យបង្ក្រាបអំពើឧក្រិដ្ឋ ការបង្ក្រាបបទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្ស ព្រមទាំងអំពើឆបោកតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ លោកស្រីបានកត់សម្គាល់ឃើញថា គណៈប្រតិភូបណ្ឌិត្យសភានគរបាលកម្ពុជា តែងបានអញ្ជើញចូលរួមក្នុងវេទិកាអន្តរជាតិផ្តួចផ្តើមដោយសាកលវិទ្យាល័យចិន និងថាសាកលវិទ្យាល័យក៏បានបណ្តុះបណ្តាលមន្ត្រីនគរបាលកម្ពុជាចំនួន ១១វគ្គ ស្មើនឹងមន្ត្រីជាង ១០០ នាក់ លើការងារពង្រឹការអនុវត្តច្បាប់ និងតែងតែជ្រើសរើសមន្ត្រីនគរបាលកម្ពុជាចំនួន១១នាក់ មកសិក្សានៅក្នុងសាសាកលវិទ្យាល័យជារៀងរាល់ឆ្នាំ។

សម្តេចក្រឡាហោម ស ខេង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមតិដ៏មានតម្លៃរបស់លោកស្រី ហើយសម្តេចក្រឡាហោមក៏លើកឡើងថា បណ្ឌិត្យសភានគរបាលកម្ពុជា បង្កើតឡើងប្រមាណ២០ឆ្នាំ ជារយៈពេលខ្លីមួយបើធៀបនឹងសាកលវិទ្យាល័យសន្តិសុខសាធារណចិន។ សម្តេចក្រឡាហោមបន្តថា បណ្ឌិត្យសភាក៏មានទំនាក់ទំនងជាមួយសាលានគរបាល នៃប្រទេសមួយចំនួនផងដែរ ដើម្បីលើកកម្ពស់គុណភាព និងសមត្ថភាពមន្ត្រី។ សម្តេចក្រឡាហោមក៏បានឯកភាពចំពោះការបណ្តុះបណ្តាល និងការផ្លាស់ប្តូរបទពិសោធន៍តាមរយៈវេទិកាអន្តរជាតិនានា រវាងមន្ត្រីនគរបាលកម្ពុជា និងចិន រួមទាំងជាមួយមន្ត្រីនគរបាលប្រទេសផ្សេងទៀត។ សម្តេចក៏បានចែករំលែកព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនៃអំពើជួញដូរមនុស្សនៅកម្ពុជា ដែលមានការធ្លាក់ចុះច្រើននារយៈពេលចុងក្រោយ៕ដោយៈ រិទ្ធី

# ក្រសួងការបរទេស៖ កម្ពុជាបានស្នើឱ្យថៃឈប់ដាក់ខ្នោះច្រវ៉ាក់ពលករខ្មែរដែលឆ្លង ដែនចូលប្រទេសថៃខុសច្បាប់តទៅទៀត

https://www.rfi.fr/km//20230429-?ref=tg_i ចុះផ្សាយនៅថ្ងៃ៖ 29/04/2023 - 09:09

ក្រសួងការបរទេសកម្ពុជាបានបញ្ជាក់ថា រូបភាពពលករជាប់ខ្នោះច្រវ៉ាក់ដែលបង្ហោះនៅបណ្ដាញសង្គមនាពេលថ្មីៗនេះ គឺពិតជាពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃចាប់ឃាត់ខ្លួន បន្ទាប់ពីពួកគេបានលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ។ អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុឃឿន យល់ថា ការដាក់ខ្នោះច្រវ៉ាក់ ពលករខ្មែរដែលលួចឆ្លងដែនខុសច្បាប់របស់អាជ្ញាធរថៃបែបនេះ ជារូបភាពមិនសមរម្យព្រោះពលករខ្មែរមិនមែនជាឧក្រិដ្ឋជនឡើយ។

រូបភាពពលករខ្មែរ មានប្រុសមានស្រី ដែលដៃទាំងសងខាងកំពុងជាប់ខ្នោះច្រវ៉ាក់ចងផ្ទឹបជុំគ្នានៅក្នុងឡានលើបណ្ដាញសង្គម នាប៉ុន្មានថ្ងៃចុងក្រោយនេះ គឺជាពលករខ្មែរដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួន កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បន្ទាប់ពីពួកគេបានឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ នៅតំបន់ណាត្រាត ខេត្តសាមុតប្រាកាន។ តាមរយៈវិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុឃឿន បញ្ជាក់ថា អាជ្ញាធរថៃបានចាប់ដាក់ខ្នោះច្រវ៉ាក់ពលករខ្មែរចំនួន១៤នាក់នោះ ដោយសារបារម្ភខ្លាចពួកគេរត់គេចខ្លួន។

ជ្បិតថានៅពេលនេះ ពលករខ្មែរទាំងជាង១០នាក់នោះ ត្រូវបានអាជ្ញាធរថៃដោះខ្នោះច្រវ៉ាក់ចេញវិញ នៅពេលដល់នៅមន្ទីរឃុំឃាំងបាងកែវ ក្រុងបាងកក រួចហើយក៏ពិតមែន ប៉ុន្តែក្រសួងការបរទេសកម្ពុជា យល់ថា ការដាក់ខ្នោះច្រវ៉ាក់បែបនេះ ចំពោះពលករខ្មែរដែលលួចឆ្លងដែនខុសច្បាប់របស់អាជ្ញាធរថៃ គឺជារូបភាពមិនសមរម្យព្រោះពលករខ្មែរមិនមែនជាឧក្រិដ្ឋជនឡើយ។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានស្នើឱ្យថៃ បញ្ឈប់ការដាក់ខ្នោះច្រវ៉ាក់ពលករខ្មែរ ដែលឆ្លងដែនចូលប្រទេសថៃខុសច្បាប់បែបនេះតទៅទៀត។ ទន្ទឹមគ្នានេះដែរ អ្នកនាំពាក្យរូបនេះ បានបញ្ជាក់ទៀតថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានលើកសំណើទៅកាន់ក្រសួងការបរទេសថៃ ដើម្បីស្នើសុំឱ្យជួយសម្របសម្រួលជាមួយតម្រួតអន្តោប្រវេសន៍ថៃបន្ថែមទៀត ដើម្បីជួយពន្លឿនការដោះលែងពលករទាំង១៤នាក់ខាងលើ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ បើតាម លោក អាន សុឃឿន អ្នកនាំពាក្យក្រសួងការបរទេស អាជ្ញាធរថៃនឹងបញ្ជូនពលករខាងលើត្រលប់មកប្រទេសកម្ពុជាវិញ ក្រោយការសួរនាំនិងបំពេញសំណុំឯកសារ ចប់សព្វគ្រប់។

គួរជម្រាបថា ពលករអន្តោប្រវេសន៍ខ្មែរ ដែលមិនមានឯកសារគ្រប់គ្រាន់ ឬពលករខុសច្បាប់ នៅតែព្យាយាមចូលទៅក្នុងប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើជារៀងរាល់ថ្ងៃ។ របាយការណ៍ក្រសួងការងារឱ្យដឹងថា ត្រឹមដំណាច់ឆ្នាំ២០២២ មានពលករខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសសរុបជាង ១លាន៣សែននាក់ ក្នុងនោះប្រទេសថៃ មានចំនួនជាង ១លាន២សែននាក់។ ចំណែករបាយការណ៍របស់អង្គការសង់ត្រាល់ (Central) រកឃើញថា ពលករខ្មែរ ដែលកំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់មានជាងពីរលាននាក់៕

## ពលករកម្ពុជានៅក្រៅប្រទេសមាន ១.៣លាននាក់ ខណៈអត្រាមានការងារក្នុងប្រទេស ៩៩.៣%

https://freshnewsasia.com/index.php/en/localnews/289017-2023-05-01-01-40-52.html 2023-05-01 08:40am

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានបញ្ជាក់តាមរយៈសារលិខិត ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ នាថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣នេះថា បច្ចុប្បន្នពលករកម្ពុជា ដែលកំពុងធ្វើការនៅក្រៅប្រទេសមានប្រមាណ ១.៣លាននាក់ ខណៈអត្រាមានការងារក្នុងប្រទេសរក្សាបាន ៩៩.៣%។ សម្តេចតេជោបានឱ្យដឹងថា រាជរដ្ឋាភិបាលបាន និងកំពុងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍទីផ្សារការងារ ដែលមានប្រាក់ចំណូលខ្ពស់។ បន្តពង្រឹងប្រសិទ្ធភាពនៃយន្តការ សម្របសម្រួលទីផ្សារការងារ តាមរយៈការពង្រីកវិសាលភាពនៃការផ្តល់សេវាការងារនិងព័ត៌មានទីផ្សារការងារ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយបានបង្កើនមជ្ឈមណ្ឌលការងារ និងមជ្ឈមណ្ឌលការងារចល័ត បានដាក់ឱ្យអនុវត្តថ្នាល់ឌីជីថលសេវាការងារ ព្រមទាំងរៀបចំវេទិកាការងារថ្នាក់ជាតិ និងនៅតាមមូលដ្ឋាន ដោយបានផ្តល់សេវាជួយស្វែងរកការងារ និងប្រឹក្សាការងារ។

សម្តេចតេជោនាយករដ្ឋមន្ត្រីនៃបានបញ្ជាក់ថា**«អត្រាមានការងារធ្វើនៅកម្ពុជាបច្ចុប្បន្នមានចំនួន៩៩.៣%»** សម្តេចតេជោ ហ៊ុន សែន បានបន្តថា ទន្ទឹមនឹងឱកាសការងារក្នុងស្រុក រាជរដ្ឋាភិបាលខិតខំផ្តល់ជម្រើស ជូនប្រជាពលរដ្ឋដែលមានបំណងចង់ធ្វើការងារ នៅក្រៅប្រទេស ដោយបានខិតខំពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសដៃគូ ដើម្បីទទួលបានឱកាសការងារ នៅក្រៅប្រទេស ជូនពលករសរុបចំនួនប្រមាណ១.៣លាននាក់ ដែលមិនត្រឹមតែអាចបានប្រាក់ចំណូល បានចំណេះជំនាញប៉ុណ្ណោះទេ ថែមទាំងអាចផ្ញើប្រាក់បញ្ញើមកក្នុងប្រទេសជូនគ្រួសារ និងចូលរួមការអភិវឌ្ឍប្រទេសជាតិ។

គួរជម្រាបថា ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងបម្រើការនៅក្រៅប្រទេសនោះ រួមមាននៅប្រទេសថៃ កូរ៉េខាងត្បូង ជប៉ុន ម៉ាឡេស៊ី សិង្ហបុរីជាដើម៕

## កម្ពុជាត្រៀមអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍ជនជាតិហ្វីលីពីន ចំនួន ៤ នាក់

https://www.postkhmer.com/national/2023-04-30-1829-249540.html ជា សុខនី | Publication date 30 April 2023 | 18:29 ICT

**ភ្នំពេញៈ** ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវបណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានប្រកាសឱ្យដឹងថា សមត្ថកិច្ចជំនាញរបស់កម្ពុជា បានបញ្ជូនជនជាតិហ្វីលីពីនចំនួន៤នាក់ ទៅកាន់មណ្ឌលត្រៀមបណ្តេញចេញរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍។នេះបើយោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។ សេចក្តីប្រកាសបានឱ្យដឹងថា ក្រុមប្រតិបត្តិការ បានទទួលកំណត់ទូតពីស្ថានទូតហ្វីលីពីន ប្រចាំកម្ពុជាចំនួន ២លើក ដោយស្នើសុំជួយសង្គ្រោះប្រជាពលរដ្ឋហ្វីលីពីនលើករណីបង្ខាំងមនុស្ស ធ្វើទារុណកម្ម និងជំរិតទារប្រាក់ នៅទីតាំងក្រុមហ៊ុនកាស៊ីណូមួយកន្លែង ស្ថិតក្នុងខេត្តកោះកុង ដោយលើកទី១ ស្នើសុំជួយសង្គ្រោះចំនួន៣០នាក់ និងលើកទី២ ស្នើសុំជួយសង្គ្រោះចំនួន ២០នាក់។ ប្រភពដដែលបានបន្តថា សមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង បានចុះស្រាវជ្រាវស្វែងរកជនជាតិហ្វីលីពីន តាម សំណើសុំអន្តរាគមន៍ទាំង២លើក ដោយលើកទី១ បានរកឃើញប្រជាពល

រដ្ឋហ្វីលីពីនចំនួន ២០នាក់ ប៉ុន្តែពួកគេត្រូវបានដោះលែងវិញ ដោយសារពួកគេស្នាក់នៅ និងធ្វើការស្របតាមច្បាប់នៃប្រទេសកម្ពុជា។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានឱ្យដឹងទៀតថា ក្រោយទទួលបានសំណើលើកទី២ សមត្ថកិច្ចជំនាញបានរកឃើញពលរដ្ឋហ្វីលីពីនចំនួន ៧នាក់ ដែលមានឈ្មោះ ប្រហាក់ប្រហែលនឹងឈ្មោះក្នុងសំណើសុំរបស់ស្ថានទូត ទើបសម្រេចអញ្ជើញពួកគេមកទីកន្លែងរបស់សមត្ថកិច្ចដើម្បីធ្វើការសាកសួរ។ គណៈកម្មាធិការនេះថា ៖ «តាមការបំភ្លឺនៅចំពោះមុខមន្ត្រីទូត ពួកគេបានចូលមកប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០២២ តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងគោលបំណងស្វែងរកការងារធ្វើ តាមរយៈភ្នាក់ងារ និងបានចូលធ្វើការរហូតមកដល់បច្ចុប្បន្ន ដោយទទួលបានអាហារគ្រប់គ្រាន់ កន្លែងស្នាក់នៅសមរម្យ ប្រាក់ខែទៀងទាត់ និងពុំធ្លាប់ត្រូវបានបង្ខាំងធ្វើទារុណកម្ម ឬបង្ខិតបង្ខំឱ្យធ្វើការ ខុសច្បាប់នោះទេ»។ ពួកគេក៏ពុំបានដឹងអំពីការប្ដឹង ឬស្នើសុំជំនួយទៅកាន់ស្ថានទូតនោះដែរ ហើយឈ្មោះ ដែលមានក្នុងកំណត់ទូតនោះ គឺជាឈ្មោះដែលពួកគេប្រើលើបណ្ដាញសង្គមប៉ុណ្ណោះ។ នេះបើតាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សបញ្ជាក់បន្ថែម។ ដោយពិនិត្យឃើញភាពស្របច្បាប់ចំពោះការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសកម្ពុជា ព្រមទាំងមានសំណូមពរពីសាមីខ្លួន សមត្ថកិច្ចបានអនុញ្ញាតឱ្យជនជាតិហ្វីលីពីនចំនួន ៣នាក់ ត្រឡប់ទៅបន្តការងារវិញជាធម្មតា និង៤នាក់ ផ្សេងទៀត ស្ម័គ្រចិត្តលាឈប់ពីការងារត្រឡប់ទៅប្រទេសកំណើតវិញ។

សូមបញ្ជាក់ផងដែរថា ក្នុងរយៈពេលជាង ៤ខែចុងឆ្នាំមុន គឺគិតពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានទទួលបញ្ជីតាមដានពាក់ព័ន្ធសំណើឱ្យជួយអន្តរាគមន៍ការជួញដូរមនុស្សជិត ៧០០សំណើ ក្នុងនោះមានជនបរទេសសរុបជាង ១ ៥០០នាក់ និងមាន ១៦សញ្ជាតិ។

យោងតាមព័ត៌មានដែលបានបង្ហោះនៅលើគណនីហ្វេសប៊ុករបស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឱ្យដឹងថា គ.ជ.ប.ជ បានទទួលបញ្ជីតាមដានពាក់ព័ន្ធសំណើ និងសំណូមពរ តាមរយៈហ្វេសប៊ុក និងប្រភពផ្សេងៗទៀត សរុបចំនួន ៦៦១សំណើ ជនបរទេស ១ ៥៩៦នាក់ (ស្រី ១៧២នាក់)ស្មើ១៦សញ្ជាតិ។ របាយការណ៍ថា ក្នុងចំណោមអ្នកដែលបានដាក់សំណើ និងសំណូមពរ សុំកិច្ចអន្តរាគមន៍នោះ រួមមាន ជនជាតិខ្មែរ៩នាក់ ចិន៦៦៨នាក់ ជប៉ុន១នាក់ ថៃ៩នាក់ នេប៉ាល់១នាក់ បង់ក្លាដែស២២នាក់ ប៉ាគីស្ថាន១នាក់ ម៉ាឡេស៊ី១៤៥នាក់ មីយ៉ាន់ម៉ា៥នាក់ វៀតណាម៤១៦នាក់ សិង្ហបុរី១នាក់ ស្រីលង្កា៤នាក់ ហ្វីលីពីន២នាក់ ឥណ្ឌា៨៣នាក់ ឥណ្ឌូនេស៊ី១៧៨នាក់ និងអាមេរិក២នាក់៕

## អង្គការ ILO បានផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីយន្តការដោះស្រាយ បណ្ដឹងពលករចំណាកស្រុកដល់អ្នកពាក់ព័ន្ធក្នុងខេត្តចំនួន ៣

https://www.postkhmer.com/national/2023-05-01-1853-249585.html ជា សុខនី | Publication date 01 May 2023 | 18:53 ICT

**ភ្នំពេញៈ** អង្គការអន្តរជាតិខាងការងារ (ILO) សហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារ និងស្ត្រី នឹងរៀបចំវគ្គបណ្ដុះបណ្ដាលមួយ ស្ដីពីយន្តការដោះស្រាយបណ្ដឹងពលករចំណាកស្រុក ដល់មន្ត្រីរដ្ឋាភិបាល សហជីព និងអង្គការសង្គមស៊ីវិលក្នុងខេត្តចំនួន ៣ ដោយផ្ដោតលើវិស័យនេសាទ និងវិស័យកែច្នៃអាហារសមុទ្រ។

នេះបើតាមការលើកឡើងរបស់លោក សុខ សំបូរ អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃគម្រោង Ship to Shore Rights South-East Asia នៅថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០២៣។ លោកបានសរសេរក្នុងប្រព័ន្ធតេឡេក្រាមរបស់លោកថា អង្គការ ILO ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារ និងស្ត្រី នឹងរៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹងយន្តការដោះស្រាយបណ្តឹងពលករចំណាកស្រុកក្នុងវិស័យនេសាទ និងវិស័យកែច្នៃអាហារសមុទ្រ ទៅកាន់មន្ត្រីរដ្ឋាភិបាល សហជីព និងអង្គការសង្គមស៊ីវិល ក្នុងខេត្តចំនួន៣ ដែលមានពលករធ្វើចំណាកស្រុកច្រើន រួមមាន៖ ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង។

លោកថា កម្មវិធីនេះមានការគាំទ្រពីសហភាពអឺរ៉ុប ក្រោមជំនួយបច្ចេកទេសអង្គការ ILO ក្នុងគម្រោង Ship to Shore Rights South-East Asia ផ្នែកទេសន្តរប្រវេសន៍ការងារ ដោយផ្តោតលើផ្នែកនេសាទ និងការកែច្នៃអាហារសមុទ្រ។ លោកសុខ សំបូរ បញ្ជាក់ថា៖«វគ្គបណ្តុះបណ្តាលនេះនឹងពង្រីកលទ្ធភាពទទួលបានយុត្តិធម៌ និងដំណោះស្រាយសម្រាប់ពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ ដែលកំពុងជួបប្រទះការរំលោភបំពានលើសិទ្ធិការងារ រួមទាំងអ្នកដែលធ្វើការក្នុងវិស័យនេសាទ និងវិស័យកែច្នៃអាហារសមុទ្រផងដែរ»។

លោកហ៊ុ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងតាមរយៈសេចក្តីប្រកាសព័ត៌មានរបស់អង្គការ ILO ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ថា វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់ឱកាសដ៏ល្អសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ខេត្ត ដើម្បីយល់កាន់តែច្បាស់ពីដំណើរការដោះស្រាយបណ្តឹងសម្រាប់ពលករចំណាកស្រុកនៅកម្ពុជា។ លោកបានថ្លែងថា៖ «នៅមានការងារជាច្រើនទៀតដែលត្រូវការជានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យជនចំណាកស្រុកមានសិទ្ធិទទួលបានសំណងជាក់ស្តែង។វឌ្ឍនភាពជាច្រើនត្រូវបានបង្កើតឡើងក្នុងការរៀបចំយន្តការឆ្លើយតបដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា»។

ជាមួយគ្នានេះ លោក ទុន សុភ័ណ អ្នកសម្របសម្រួលថ្នាក់ជាតិរបស់អង្គការ ILOប្រចាំនៅកម្ពុជា ក៏បានឱ្យដឹងដែរថា នៅក្នុងប្រទេសគោលដៅសំខាន់ៗ ឱនភាពការងារសមរម្យសំខាន់ៗនៅតែមានសម្រាប់ពលករចំណាកស្រុកកម្ពុជាដែលធ្វើការក្នុងវិស័យនេសាទនិងវិស័យកែច្នៃអាហារសមុទ្រ។ ការស្រាវជ្រាវថ្មីៗរបស់អង្គការអន្តរជាតិខាងការងារ(ILO)បានបង្ហាញពីភាពប្រសើរឡើងមួយចំនួននៅក្នុងលក្ខខណ្ឌការងារសម្រាប់អ្នកចំណាកស្រុកក្នុងវិស័យនេសាទ និងវិស័យកែច្នៃអាហារសមុទ្រ។ ទោះជាយ៉ាងណា លោកបានបញ្ជាក់ថា ៖ «ការរំលោភសិទ្ធិការងារធ្ងន់ធ្ងរ ក៏ត្រូវបានរកឃើញថានៅតែបន្តកើតមាន ដូចជា ការជំនួសកិច្ចសន្យា ការរក្សាទុកឯកសារអត្តសញ្ញាណ ការជាប់បំណុល ការធ្វើការលើសម៉ោង ការកិបកេងប្រាក់ឈ្នួល អំពើហិង្សា និងការបៀតបៀន ហើយនិងការបង្ខំឱ្យធ្វើការជាដើម»។

យោងតាមទិន្នន័យរបស់អង្គការសហប្រជាជាតិបង្ហាញថា មានជនចំណាកស្រុកកម្ពុជាជាង១,១លាននាក់ដែលកំពុងធ្វើការនៅក្រៅប្រទេស ហើយរាប់ពាន់នាក់ទៀតត្រូវបានធ្វើការមិនច្បាស់លាស់ដោយស្ថានភាពមិនស្របច្បាប់។ភាគច្រើននៃពលករចំណាកស្រុកទាំងនេះត្រូវបានជួលធ្វើការងារសំខាន់ៗ រួមទាំងក្នុងវិស័យនេសាទ និងវិស័យកែច្នៃអាហារសមុទ្រផងដែរ។

សូមបញ្ជាក់ថា គម្រោង Ship to Shore Rights South-East គឺជាគំនិតផ្តួចផ្តើមជាច្រើនប្រទេសរបស់សហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិដែលអនុវត្តដោយអង្គការអន្តរជាតិខាងការងារ(ILO)សហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)៕

# ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០២៣

## IOM ចង់ឃើញកិច្ចសហការជិតស្និទ្ធ ក្នុងចំណោមសមាជិកអាស៊ាន ប្រឆាំងរត់ពន្ធមនុស្ស និងគ្រឿងញៀន

https://dap-news.com/national/2023/05/03/329545/ ByPH104Posted on May 3, 2023

ភ្នំពេញ ៖ ថ្លែងសារចេញពីទឹកដីកម្ពុជា លោកស្រី Sarah Lou Arriola នាយកប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានបង្ហាញបំណង ចង់ឃើញកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន ក៏ដូចជា រវាងអាស៊ាន និងក្រុមប្រឹក្សាកិច្ច សហប្រតិបត្តិការឈូងសមុទ្រ (Gulf Cooperation Council-GCC) ដើម្បីប្រឆាំងការរត់ពន្ធមនុស្ស ការរត់ពន្ធគ្រឿងញៀន និងការគ្រប់គ្រង ត្រួតពិនិត្យតាមព្រំដែន ។

ក្នុងជំនួបសម្ដែងការគួរសមជាមួយ លុយ ដាវីត រដ្ឋលេខាធិការក្រសួងការបរទេសខ្មែរ កាលពីថ្ងៃទី២ ខែឧសភា លោកស្រី Sarah Lou Arriola បានអះអាងអំពីការផ្ដល់ការគាំទ្រ និងជំនួយរបស់អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍ដល់កម្ពុជា ដើម្បីជំរុញដល់ការគ្រប់គ្រងទេសន្តរប្រវេសន៍ ។ លោកស្រី Sarah Lou Arriola បានអបអរជោគជ័យ នៃភាពជាប្រធានអាស៊ាន របស់កម្ពុជា កាលពីឆ្នាំ២០២២ និងការទទួលធ្វើជាម្ចាស់ផ្ទះ ជាប្រវត្តិសាស្ត្ររៀបចំ 32nd SEA Games ។ ជាមួយការកោតសរសើរពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងកម្ពុជា និង IOM លោកស្រីបានជម្រាបពីការប្ដេជ្ញាចិត្ត របស់លោកស្រីក្នុងការថែរក្សា កិច្ចសហប្រតិបត្តិការយ៉ាងល្អប្រពៃ ដែលមានស្រាប់នេះ និងបន្តធ្វើការងារយ៉ាងជិតស្និទ្ធជាមួយ ភាគីពាក់ពន្ធ័ទាំងអស់ នៅក្នុងការគ្រប់គ្រងទេសន្តប្រវេសន៍ ។

ជាមួយគ្នានោះលោក លុយ ដាវីត បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះដំណើរទស្សនកិច្ចរបស់លោកស្រី Sarah Lou Arriola នៅកម្ពុជា និងអបអរសាទរចំពោះលោកស្រីដែលត្រូវបានតែងតាំងជានាយកប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការ IOM កាលពីពេលថ្មីៗ នេះ។ លោករដ្ឋលេខាធិការ បានវាយតម្លៃខ្ពស់ ចំពោះជំនួយគាំទ្ររបស់អង្គការ IOM ក្នុងការការពារជនទេសន្តរប្រវេសន៍កម្ពុជា ដែលងាយរងគ្រោះ ក៏ដូចជាការកសាងសមត្ថភាពនៅកម្ពុជា ។ លោកបានថ្លែងកោតសរសើរអង្គការ IOM ចំពោះកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ ជាមួយអាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋានកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្នុង ការផ្ដល់ជំនួយបន្ទាន់ដល់ពលករចំណាកស្រុកដែលវិលត្រឡប់មកកម្ពុជាវិញ ក្នុងកំឡុងវិបត្តិជាសាកល នៃការរាតត្បាតជំងឺកូវីដ-១៩ ។ ភាគីទាំងពីរបានបញ្ជាក់ការប្ដេជ្ញាចិត្តសាជាថ្មី ក្នុងការលើកកម្ពស់ថែមទៀតនូវកិច្ចសហប្រតិបត្តិការ ដ៏ជិតស្និទ្ធរវាងកម្ពុជា និង IOM ៕

## សម្តេចក្រឡាហោម ស ខេង ចាត់ទុកការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការជួយសង្គ្រោះជនរងគ្រោះ ជាកិច្ចការមួយដ៏មានសារៈសំខាន់

https://www.information.gov.kh/articles/103531 ចេញផ្សាយ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២៣

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឯកភាពចំពោះអ្វីដែលនាយកអង្គការ IOM ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដោយចាត់ទុកការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការជួយសង្គ្រោះជនរងគ្រោះ ជាកិច្ចការមួយដ៏មានសារៈសំខាន់។ ការលើកឡើងរបស់សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនេះ ក្នុងឱកាសអនុញ្ញាតឱ្យលោកស្រី Sarah Lou Arriola ប្រធានអង្គការ IOM ប្រចាំ

តំបន់អាស៊ី-ប៉ាស៊ីហ្វិក ទើបតែងតាំងថ្មី ចូលជួបសម្តែងការគួរសម នៅវិមានសន្តិភាព នាព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣។

សម្តេចក្រឡាហោម ស ខេង បានស្វាគមន៍ និងថ្លែងអំណរគុណចំពោះអង្គការ IOM ដែលបានជួយគាំទ្រដល់ប្រទេសកម្ពុជាពាក់ព័ន្ធទៅនឹងការងារទេសន្តរប្រវេសន៍ និងចូលរួមអបអរសាទរចំពោះកិច្ចសហប្រតិបត្តិការដែលអង្គការមានជាមួយនឹងបណ្តាក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំងក្រសួងមហាផ្ទៃផងដែរ។ សម្តេចក្រឡាហោមសង្ឃឹម និងជឿជាក់ថា អង្គការ IOM និងក្រសួងមហាផ្ទៃ នឹងបន្តពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យពាក់ព័ន្ធរវាងភាគីទាំងពីរឱ្យកាន់តែការរីកចម្រើនឡើងថែមទៀត។

លោកស្រី Sarah Lou Arriola ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកបានអរគុណចំពោះការវាយតម្លៃរបស់សម្តេចក្រឡាហោម មកលើទំនាក់ទំនង និងកិច្ចសហប្រត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ក្រសួងមហាផ្ទៃ។ លោកស្រីសម្តែងនូវការអេបអរសាទរចំពោះកម្ពុជា ដែលបានទទួលតួនាទីប្រកបដោយជោគជ័យជាប្រធានអាស៊ានឆ្នាំ២០២២កន្លងទៅ និងអបអរសាទរចំពោះកម្ពុជាដែលស្ថិតក្នុងចំណោមប្រទេស ៦ នៅតំបន់អាស៊ី ជាប់ជាប្រទេសជ័យលាភីក្នុងការងារទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងមានរបៀបរៀបរយ។

ប្រធានអង្គការ IOM បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង ក៏ដូចជាសមិទ្ធផលដែលកម្ពុជាខិតខំសម្រេចបាននៅក្នុងការក្លាយទៅជាប្រទេសជ័យលាភីនេះ និងយកឱកាសនេះសម្តែងការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដើរស្របទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ។ លោកស្រីក៏បានជម្រាបជូនសម្តេចក្រឡាហោម អំពីស្ថានភាពក្រុមការងារប្រឆាំងការជួញដូរមនុស្សនៅប្រទេសរបស់លោកស្រី គឺប្រទេសហ្វីលីពីន ដែលសម្រេចបានវឌ្ឍនភាពល្អប្រសើរលើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

លោកស្រីជឿជាក់ថា លោកស្រីអាចយកបទ ពិសោធន៍ល្អទាំងនោះមកចែករំលែកជាមួយនឹងបណ្តាប្រទេសអាស៊ាន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំងជាមួយកម្ពុជាផងដែរ។ លោកស្រីបានថ្លែងកោតសរសើរចំពោះអាជ្ញាធរអន្តោប្រវេសន៍របស់កម្ពុជា ដែលបានផ្តល់កិច្ចសហការជាពិសេសក្នុងរយៈពេលនៃវិបត្តិជំងឺកូវីដ-១៩ ដែលមន្ត្រីបំពេញតួនាទីអន្តោប្រវេសន៍តាមព្រំដែន បានផ្តល់កិច្ចសហការដ៏ល្អក្នុងការគ្រប់គ្រងត្រួតពិនិត្យព្រំដែន ក៏ដូចជាការផ្តល់នូវការថែទាំយកចិត្តទុកដាក់ចំពោះជនភៀសខ្លួនចូលមកកម្ពុជា ការត្រួតពិនិត្យនូវឯកសារឆ្លងដែន និងកិច្ចការពាក់ព័ន្ធផ្សេងៗទៀត ដែលកិច្ចការនេះជាការរួមចំណែកមួយទៅដល់ការការពារ និងការប្រឆាំងអំពើជួញដូរមនុស្ស។

សម្តេចក្រឡាហោម ស ខេង បានឯកភាពចំពោះអ្វីដែលលោកស្រីបានលើកឡើង ដោយចាត់ទុកការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការជួយសង្គ្រោះជនរងគ្រោះ ជាកិច្ចការមួយដ៏មានសារៈសំខាន់។ សម្តេចក្រឡាហោម បានជម្រាបជូនដោយសង្ខេបអំពីកិច្ចការមួយចំនួនទៀតដែលកម្ពុជាបាន និងកំពុងខិតខំធ្វើ គឺទីមួយពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ដែលកម្ពុជា ត្រូវបានដកចេញពីបញ្ជីប្រផេះកាលពីដើមឆ្នាំ២០២៣។ ទន្ទឹមនោះ ពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដែលកម្ពុជាកំពុងខិតខំប្រឹងប្រែងធ្វើការងារនេះ។ សម្តេចក្រឡាហោមសង្ឃឹថា តាមអ្វីដែលលោកស្រីបានលើកឡើង កម្ពុជាអាចនឹងរៀនសូត្រនូវអ្វីដែលជាបទពិសោធន៍ល្អៗរបស់ប្រទេសហ្វីលីពីន លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សម្តេចក្រឡាហោមក៏បានលើកទឹកចិត្តឱ្យក្រុមការងារពាក់ព័ន្ធបន្តកិច្ចសហប្រតិបត្តិការ ក៏ដូចជាចែករំលែកបទពិសោធន៍ទៅវិញទៅមកលើការងារនេះផងដែរ។

លោកស្រី Sarah Lou Arriola ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកបានសម្តែងសេចក្តីរីករាយ និងបានគូសបញ្ជាក់ថា ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនេះ ពិតជាទាមទារឱ្យមាននូវកិច្ចសហប្រតិបត្តិការជាមួយគ្នាជិតស្និទ្ធ ជាពិសេសប្រទេសក្នុងតំបន់មេគង្គ ដែលមានព្រំដែនជាប់ជាប់គ្នារវាងប្រទេសមួយទៅប្រទេសមួយ ទាមទារជាចាំបាច់នូវការបង្កើតកិច្ចសហប្រតិបត្តិការជិតស្និទ្ធដើម្បីរួមគ្នាទប់ស្កាត់នូវអំពើជួញដូរមនុស្ស។ លោកស្រីបានបន្ថែមថា ប្រទេសទាំងអស់ សុទ្ធតែមានតួនាទីសំខាន់ៗក្នុងការរួមគ្នាទប់ស្កាត់នូវអំពើជួញដូរមនុស្ស៕ដោយ ចាន់ សុធីវង្ស

## កម្ពុជា នឹងរៀនសូត្របទពិសោធន៍ល្អៗ ពីហ្វីលីពីន លើការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://dap-news.com/national/2023/05/03/329641/ ByPH104Posted on May 3, 2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បានថ្លែងថា កម្ពុជាអាចនឹងរៀនសូត្រនូវអ្វីដែលជាបទពិសោធន៍ល្អៗរបស់ប្រទេសហ្វីលីពីន លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ សម្តេចក្រឡាហោម ស ខេង លើកឡើងបែបនេះ ក្នុងជំនួបពិភាក្សាការងារជាមួយ លោកស្រី Sarah Lou Arriola ប្រធានអង្គការ IOM ប្រចាំតំបន់អាស៊ី-ប៉ាស៊ីសហ្វិច ទើបតែងតាំងថ្មី នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣នេះ។

នាឱកាសនោះ លោកស្រី Sarah Lou Arriola បានជម្រាបជូន សម្តេច ស ខេង អំពីស្ថានភាពក្រុមការងារប្រឆាំង ការជួញដូរមនុស្ស នៅប្រទេសរបស់លោកស្រី គឺប្រទេសហ្វីលីពីន ដែលសម្រេចបានវឌ្ឍនភាពល្អប្រសើរលើការងារប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស និងសង្ឃឹមជឿជាក់ថា លោកស្រីអាចយកបទ ពិសោធន៍ល្អទាំងនោះមកចែករំលែកជាមួយនឹងបណ្តាប្រទេសអាស៊ាន ក្នុងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស រួមទាំងជាមួយកម្ពុជាផងដែរ ។

លោកស្រី ក៏យកឱកាសនេះថ្លែង កោតសរសើរចំពោះអាជ្ញាធរ អន្តោប្រវេសន៍របស់កម្ពុជា ដែលបានផ្តល់កិច្ចសហការជាពិសេស ក្នុងរយៈពេលនៃវិបត្តិជំងឺកូវីដ-១៩ ដែលមន្ត្រីបំពេញតួនាទីអន្តោប្រវេសន៍ តាមព្រំដែន បានផ្តល់កិច្ចសហការដ៏ល្អក្នុងការគ្រប់គ្រងត្រួតពិនិត្យព្រំដែន ក៏ដូចជាការផ្តល់នូវការថៃទាំយកចិត្តទុកដាក់ ចំពោះជនភៀសខ្លួនចូលមកកម្ពុជា ការត្រួតពិនិត្យនូវឯកសារឆ្លងដែន និងកិច្ចការពាក់ព័ន្ធផ្សេងៗទៀត ដែលកិច្ចការនេះជាការរួមចំណែកមួយទៅដល់ការការពារ និងការប្រឆាំង អំពើជួញដូរមនុស្ស។

សម្តេចក្រឡាហោម ស ខេង បានឯកភាពចំពោះអ្វី ដែលលោកស្រីបានលើកឡើង ដោយចាត់ទុកការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការជួយសង្គ្រោះជនរងគ្រោះ ជាកិច្ចការមួយដ៏មានសារៈសំខាន់។ សម្តេចក៏សង្ឃឹមជឿជាក់ថា «តាមអ្វីដែលលោកស្រីបានលើកឡើង កម្ពុជាអាចនឹងរៀនសូត្រនូវអ្វីដែលជាបទពិសោធន៍ល្អរបស់ប្រទេសហ្វីលីពីន លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស»៕

# រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
# គាំទ្រឱ្យដំណើរការឡើងវិញ ការសុំកូនអន្តរប្រទេសរវាងកម្ពុជា និងអ៊ីតាលី

https://freshnewsasia.com/index.php/en/localnews/289728-2023-05-03-09-27-25.html 2023-05-03 04:27pm

**(ភ្នំពេញ)៖** លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា បានទទួលជួបពិភាក្សាការងារជាមួយ លោកវេជ្ជបណ្ឌិត រីនសេនហ្ស៊ូ ស្តារីតា អនុប្រធានអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអ៊ីតាលី នៅទីស្តីការក្រសួងសង្គមកិច្ច នាព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០២៣នេះ ។ ក្នុងជំនួបនេះ លោក វង សូត ថ្លែងថាបន្ទាប់ពីរៀបច្បាប់ រាជរដ្ឋាភិបាលក៏បានប្រកាស ដាក់ឲ្យដំណើរការឡើងវិញ ការងារសុំកូន ក្រោយមានការអាក់ខាន ដោយសារតែកូវីដ-១៩។ ម្យ៉ាងវិញទៀត លោក វង សូត បានគូសបញ្ជាក់ថា អ៊ីតាលី បានផ្តល់ការបណ្តុះបណ្តាល ទាក់ទិនទៅនឹងនីតិវិធីសុំកូន បង្ហាត់បង្រៀនច្បាប់ដើម្បីការពារជនរងគ្រោះ សិទ្ធិផ្សេងៗទៀត សំដៅធានាការសុំកូនឲ្យស្របតាមគោលការណ៍កំណត់ និងបញ្ចៀសការ ប្រើប្រាស់រូបភាពនេះជាការជួញដូរ។ ហើយក៏មានភ្នាក់ងាររបស់អ៊ីតាលី ធ្វើការងារសុំកូនបានសហការយ៉ាងជិតស្និទជាមួយក្រសួង ធ្វើការងារសុំកូននេះឡើងវិញផងដែរ ។ ជាមួយគ្នានេះ រដ្ឋមន្ត្រី វង សូត ក៏បានណែនាំកិច្ចការទាំងអស់នេះទៅដល់ក្រុមការងារឲ្យធ្វើបន្ត ចែករំលែកផ្លាស់ប្តូរបតិយោបល់គ្នាទៅវិញទៅមក ហើយសង្ឃឹមថា បន្ទាប់ពីស្ថានភាពជំងឺដកូវីដ-១៩បានវិលទៅរកភាពធម្មតាវិញ ការងារទាក់ទងនឹងការសុំកូន ក៏អាចធ្វើទៅធម្មតាវិញដូចគ្នាដែរ។

ក្នុងឱកាសនោះ លោកវេជ្ជបណ្ឌិត រីនសេនហ្ស៊ូ ស្តារីតា មានប្រសាសន៍ថា លោកនិងក្រុមការងារ ពិតជាមានកិត្តិយសណាស់ដែលបានជួបជាមួយនឹងលោករដ្ឋមន្ត្រី និងក្រុមការងាររបស់ក្រសួងសង្គមកិច្ចនៅពេលនេះនិងបានថ្លែងអំណរគុណចំពោះក្រុមការងារដែលបានធ្វើការជាមួយនឹងមជ្ឈមណ្ឌលកែ របស់អ៊ីតាលី និងបានអរគុណទៅដល់អាជ្ញាធរសុំកូនកម្ពុជា ដែលបានខិតខំប្រឹងប្រែងគ្រប់កាលៈទេសៈ ទាំងអស់ដែលអាចធ្វើការងារមួយនេះប្រព្រឹត្តទៅដោយរលូន លោកក៏បានលើកឡើងថា លោកបានធ្វើការងារជាមួយនឹងក្រសួងយុត្តិធម៌ អំពីកិច្ចការសុំកូនអន្តរជាតិនេះ ហើយក៏បានជជែកអំពីសិទ្ធិកុមារ ការការពារកុមារនៅក្នុងប្រទេសកម្ពុជាផងដែរ ហើយលោកបានលើកឡើងថាការធ្វើកិច្ចការទាំងអស់នេះ មិនមែនតែក្មេងដែលជាក្មេងមកពីប្រទេសកម្ពុជា ឬក៏ក្មេងនៅក្នុងប្រទេសអ៊ីតាលី នោះទេគឺលោកបានធ្វើកិច្ចការទាំងអស់នេះ ក្មេងទូទាំងពិភពលោកតែម្តង ហើយលោកក៏បានធ្វើការទៅតាមអនុសញ្ញាក្រុងឡាអេ ដែលជាកិច្ចការមួយដែលនិយាយពីការសុំកូននេះដែរ នឹងធ្វើការដោយគោរពសិទ្ធិរបស់កុមារជាមួយនឹងគ្រួសាររបស់កុមារទាំងអស់នោះ។

បន្ថែមពីលើនេះ រដ្ឋមន្ត្រី វង សូត បានលើកឡើងថា ទាំងអត្ថប្រយោជន៍ ទាំងបទដ្ឋានគតិយុត្តិទាក់ទិននឹងការសុំកូនអន្តរប្រទេស គឺធ្វើយ៉ាងម៉េចដើម្បីការពារផលប្រយោជន៍របស់កុមារ ហើយសម្រាប់លោកប្រធានអង្គការក៏បានបង្ហាញពីការយកចិត្តទុកដាក់ចំពោះកុមារ ដែលនេះគឺជាការបង្ហាញមួយ ពីព្រោះថាមានកុមារខ្លះគឺជាជនរងគ្រោះជា ហើយទាក់ទិនទៅនឹងការសុំកូន កុមារទទួលបានសិទ្ធិមួយដែលទទួលបានស្របទៅតាមច្បាប់៕

**សម្តេច ស ខេង ស្នើបន្តជំរុញ អនុវត្តនូវការងារផ្សេងៗទៀតដែលក្រសួងមហាផ្ទៃ មានជាមួយនគរបាលសហព័ន្ធអូស្ត្រាលីតាមរយៈការចុះកិច្ចព្រមព្រៀង MOU**

https://cen.com.kh/archives/654809.html Posted ByPen Srey NeatMay 4, 2023

ភ្នំពេញ៖ នាព្រឹកថ្ងៃពុធ ទី៣ ខែឧសភា ឆ្នាំ២០២៣នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូន ឯកឧត្តម Justin Kevin ឯកអគ្គរដ្ឋទូតអូស្ត្រាលី ទើបតែងតាំងថ្មី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានសន្តិភាព។

សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ស្វាគមន៍ និងចូលរួមអបអរសាទរឯកឧត្តម ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋ និងបានជម្រាបជូនអំពីប្រវត្តិទំនាក់ទំនងរវាងប្រទេសទាំងពីរក្នុងរយៈពេលជាង៧០ឆ្នាំ ដែលបើទោះបីជាត្រូវបានកាត់ផ្តាច់ក្នុងចន្លោះពេលខ្លះដោយសារស្ថានភាពនយោបាយនៅកម្ពុជា ប៉ុន្តែភាគីទាំងពីរបានបន្តរក្សានូវទំនាក់ទំនងនេះយ៉ាងល្អប្រសើរ។ សម្តេចក្រឡាហោម ក៏បានបង្ហាញការសង្ឃឹមជឿជាក់ថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា នឹងរួមចំណែកដល់ការពង្រឹង និងពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែខ្លាំងក្លាថែមទៀត។

ចំពោះកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជាវិញ សម្តេចក្រឡាហោម បានជម្រាបជូន ឯកឧត្តមអគ្គរដ្ឋទូតថា ក្រសួងមហាផ្ទៃ មានកិច្ចសហប្រតិបត្តិការ និងទទួលការជួយគាំទ្រពីខាងភាគីអូស្ត្រាលីផងដែរ ជាពិសេសពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គម ។ សម្តេចក៏បានជម្រាបផងដែរថា សម្តេចក៏ធ្លាប់បានរៀបចំដំណើរទស្សនកិច្ចរួមគ្នាជាមួយឯកឧត្តមអគ្គរដ្ឋទូតអូស្ត្រាលី និងឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ក៏ដូចជាដៃគូអភិវឌ្ឍន៍ផ្សេងទៀតនៅតាមបណ្តាខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងយល់អំពីដំណើរការកំណែទម្រង់ក៏ដូចជាការអនុវត្តគម្រោងនានានៅមូលដ្ឋាន ។

សម្តេចក្រឡាហោម ស ខេង ក៏បានជម្រាបជូនអំពីគម្រោងនគរបាលសហគមន៍ ដែលជាគម្រោងមួយល្អ និងទទួលបានការគាំទ្រពីខាងភាគីអូស្ត្រាលី។ សម្តេចក៏យកឱកាសនេះថ្លែងអំណរគុណ ដោយគូសបញ្ជាក់ថា គម្រោងនគរបាលសហគមន៍បានរួមចំណែកធ្វើឲ្យសហគមន៍កាន់តែទទួលបានសុខសុវត្ថិភាព។ សម្តេចបន្តថា ការងារនេះ បានជួយបណ្តុះបណ្តាល និងលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់។ សម្តេចក៏ស្នើបន្តជំរុញ និងលើកទឹកចិត្តដល់ភាគីទាំងពីរបន្ត អនុវត្តនូវការងារផ្សេងៗទៀតដែលក្រសួងមហាផ្ទៃ មានជាមួយនគរបាលសហព័ន្ធអូស្ត្រាលី តាមរយៈការចុះកិច្ចព្រមព្រៀង MOU ជាមួយគ្នាកន្លងមក ឲ្យទទួលបានលទ្ធផលល្អប្រសើរថែមទៀត។

ជាការឆ្លើយតប ឯកឧត្តម Justin Kevin ឯកអគ្គរដ្ឋទូតអូស្ត្រាលី បានថ្លែងអំណរគុណចំពោះពាក្យពេចន៍របស់ សម្តេចក្រឡាហោម និងថាឯកឧត្តមពិតជាមានសេចក្តីរីករាយ ដែលបានត្រឡប់មកកាន់ប្រទេសកម្ពុជា ជាថ្មីម្តងទៀត បន្ទាប់ពីអស់រយៈពេល២០ឆ្នាំមកហើយ ដែលឯកឧត្តមធ្លាប់បានបំពេញតួនាទី និងភារកិច្ចនៅកម្ពុជា។ ឯកឧត្តមក៏ឯកភាពចំពោះការវាយតម្លៃរបស់សម្តេច ទៅលើកិច្ចសហប្រតិបត្តិការទ្វេភាគី ក៏ដូចជាក្នុងកម្រិតតំបន់ និងបានជម្រាបជូនដែរថា ក្នុងតួនាទីឯកឧត្តមជាឯកអគ្គរដ្ឋទូតនឹងបន្តខិតខំស្វែងរកឱកាសពង្រីកទំនាក់ទំនងទ្វេភាគី ពហុភាគីជាមួយកម្ពុជា ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលជាក្តីបារម្ភ និងកង្វល់រួមរបស់ភាគីទាំងពីរ។

ចំពោះទំនាក់ទំនង និងកិច្ចសហការជាមួយនឹងក្រសួងមហាផ្ទៃ ឯកឧត្តមក៏បានឯកភាពជាមួយនឹងការលើកឡើងរបស់សម្តេច ដោយបានគូសបញ្ជាក់ដែរថា អូស្ត្រាលី មានទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អជាមួយនឹងក្រសួងមហាផ្ទៃ ក៏ដូចជាជាមួយនគរបាលកម្ពុជា ទាំងក្នុងក្របខណ្ឌនៃការរៀបចំគោលនយោបាយ ក៏ដូចជាក្នុងប្រតិបត្តិការការងារផ្ទាល់ផងដែរ។ ឯកឧត្តមក៏សម្តែងនូវសេចក្តីរីករាយចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការកន្លង

មកដ៏ល្អរវាងក្រុមការងារ នៃនគរបាលសហព័ន្ធអូស្ត្រាលីជាមួយនឹងនគរបាលកម្ពុជាលើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការងារប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់។

ឯកឧត្តម ឯកអគ្គរដ្ឋទូតបន្តថា ភាគីអូស្ត្រាលីនឹងបន្តខិតខំជំរុញលើកកម្ពស់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការលើការងារទាំងនេះឱ្យកាន់តែទទួលបានលទ្ធផលវិជ្ជមានច្រើនឡើងថែមទៀត។ សម្តេចបន្តថា ចំពោះការងារកិច្ចសហប្រតិបត្តិការនៅក្នុងការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជាការងារគណនេយ្យភាពសង្គម ឯកឧត្តមពិតជាមានសេចក្តីរីករាយចំពោះវឌ្ឍនភាព ដែលកម្ពុជាទទួលបានក្នុងដំណើរការកាងាររយៈពេលប្រមាណជាង២០ឆ្នាំកន្លងមក។ ឯកឧត្តមបញ្ជាក់ថា អូស្ត្រាលីក៏រីករាយក្នុងការបន្តចូលរួមចំណែកជាមួយនឹងកម្ពុជាក្នុងការអនុវត្តការងារនេះ។ ក្នុងជំនួបនោះដែរ ឯកឧត្តមអគ្គរដ្ឋទូត និងសម្តេចក្រឡាហោម ក៏បានជជែកពិភាក្សាផ្លាស់ប្តូរយោបល់លើកិច្ចការមួយចំនួន រួមមានការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ និងអំពីស្ថានភាពនយោបាយនៅកម្ពុជា ពិសេសក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នោតជាតិនាខែកក្កដាខាងមុខ និងល្អកិច្ចសហប្រតិបត្តិការនៅក្នុងការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

# ថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ២០២៣

## រដ្ឋមន្ត្រី ម៉ម ប៊ុនហេង លើកទឹកចិត្ត IOM សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ទទួលបានជោគជ័យ

https://freshnewsasia.com/index.php/en/localnews/289771-2023-05-03-14-28-58.html 2023-05-03 09:28pm

**(ភ្នំពេញ)៖** លោកសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានជំរុញលើកទឹកចិត្តដល់ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (International Organization for Migration-IOM) ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលមាន លោកស្រី Sarah Lou - Arriola ជាប្រធាន សហការឱ្យបានជិតស្និទ្ធិជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ទទួលបានជោគជ័យ។

ការថ្លែងដូច្នេះរបស់លោករដ្ឋមន្ត្រី ក្នុងឱកាសបានអនុញ្ញាតឱ្យលោកស្រី Sarah Lou - Arriola ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (International Organization for Migration-IOM) ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចូលជួបសវនាការ និងសម្តែងការគួរសម ក្នុងឱកាសដែលលោកស្រី ត្រូវបានតែងតាំងជាប្រធានអង្គការ IOM ថ្មី ប្រចាំតំបន់ ។ជំនួបនេះប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣នេះនាទីស្តីក្រសួងសុខាភិបាល។ ជាមួយគ្នានេះ រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានសម្តែងមនោសញ្ចេតនាស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះលោកស្រីប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងថ្លែងអំណរគុណចំពោះអង្គការ IOM ដែលបានសហការ និងគាំទ្រវិស័យសុខាភិបាល ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។

លោកស្រីប្រធានអង្គការ IOM ប្រចាំតំបន់ ក៏បានថ្លែងអបអរសាទរ និងកោតសរសើររាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រង ទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ-១៩ នៅកម្ពុជា ក្នុងរយៈពេលជាង ២ឆ្នាំកន្លងមកនេះ បានទទួលជោគជ័យ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោ ហ៊ុន

សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ជាអគ្គមេបញ្ជាការដឹកនាំ ចង្អុលបង្ហាញផ្ទាល់ ដែលអាចឱ្យកម្ពុជា បើកដំណើរការប្រទេស ទាំងសកម្មភាពសេដ្ឋកិច្ច និងសង្គមឡើងវិញតាំងពីខែវិច្ឆិកា ឆ្នាំ២០២១។ លោកស្រីប្រធានអង្គការ IOM ក៏បានថ្លែងអំណរគុណដល់ក្រសួងសុខាភិបាល ដែលបានសហការ គាំទ្រដល់បេសកកម្មរបស់អង្គការ IOM សម្រេចបានសមិទ្ធផលមួយចំនួនដូចខាងក្រោម ជាពិសេស ដើម្បីចូលរួមចំណែកក្នុងការសម្រេចបានការគ្របដណ្ដប់សេវាសុខភាព ជាសកលៈ

*បានបង្កើតគោលនយោបាយជាតិស្តីពី សុខភាពជនទេសន្តរប្រវេសន៍ កាលពីខែមករាឆ្នាំ២០២១ បានបង្កើត និងដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពី សុខភាពជនទេសន្តរប្រវេសន៍ឆ្នាំ២០២២-២០៣០ កាលពីចុងខែធ្នូ ឆ្នាំ២០២២ គាំទ្រដល់ដំណើរការក្រុមការងារបច្ចេកទេសសុខភាពជនទេសន្តរប្រវេសន៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងនោះ លោករដ្ឋមន្ត្រីក៏បានសម្ដែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្ដងទៀត ចំពោះការជួយឧបត្ថម្ភគាំទ្ររបស់អង្គការ IOM ក្នុងស្មារតីសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងក្រសួងសុខាភិបាល និងអង្គការ IOM និងបានជូនពរប្រធានអង្គការ IOM ប្រចាំតំបន់បានទទួលជោគជ័យក្នុងបេសកកម្ម៕

## អង្គការផ្លែនអន្តរជាតិកម្ពុជា
## ណែនាំពីគន្លឹះមួយចំនួនដើម្បីរក្សាសុវត្ថិភាពកុមារនៅលើប្រព័ន្ធអ៊ីនធឺណិត

https://www.postkhmer.com/national/2023-05-03-1839-249656.html ឡុង គីមម៉ារីតា | Publication date 03 May 2023 | 18:39 ICT

**ភ្នំពេញៈ** អង្គការផ្លែនអន្តរជាតិកម្ពុជាណែនាំពីគន្លឹះមួយចំនួនដល់អាណាព្យាបាល ដើម្បីរក្សាសុវត្ថិភាពកុមារនៅលើប្រព័ន្ធអ៊ីនធឺណិត ដោយអះអាងថា សុវត្ថិភាពកុមារនៅលើប្រព័ន្ធអ៊ីនធឺណិតនៅតែជាកត្តាព្រួយបារម្ភដែលត្រូវយកចិត្តទុកដាក់ និងអាចទប់ស្កាត់បានតាមរយៈការចូលរួម។ លិខិតណែនាំរបស់អង្គការផ្លែនបានលើកឡើងថា ក្នុងនាមអ្នកជាឪពុកម្ដាយ ឬអាណាព្យាបាល និងគ្រូបង្រៀន គឺត្រូវចូលរួម និងដឹងពីរបៀបដែលអាចការពារសុវត្ថិភាពកុមារបាននៅលើប្រព័ន្ធអ៊ីនធឺណិត ហើយវិធីសាស្ត្រទាំងនោះ នឹងអាចជួយកុមារ និងយុវជនឱ្យគេចចេញពីហានិភ័យ ឬគ្រោះថ្នាក់ដែលអាចជះឥទ្ធិពលអាក្រក់ដល់កុមារ និងយុវជន។

អង្គការផ្លែន បានណែនាំថា៖«សូមលើកទឹកចិត្តកុមារ និងយុវជនឱ្យបង្ហាញអ្នកអំពីសកម្មភាពដែលពួកគេចូលចិត្តធ្វើនៅលើប្រព័ន្ធអ៊ីនធឺណិត។ សូមបង្កើត និងមានការព្រមព្រៀងលើវិន័យក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅក្នុងផ្ទះរបស់អ្នក។ សូមណែនាំ និងលើកទឹកចិត្តកុមារ និងយុវជនឱ្យចេះកំណត់ភាពឯកជន ដោយមិនបង្ហាញឈ្មោះពេញ អាសយដ្ឋាន លេខទូរស័ព្ទ ព័ត៌មានផ្ទាល់ខ្លួន ឬរូបថតដែលអាចកំណត់អត្តសញ្ញាណ»។ អង្គការនោះក៏បានណែនាំឱ្យអាណាព្យាបាលគ្រប់រូបត្រូវលើកទឹកចិត្តកុមារ និងយុវជនគិតគូរឱ្យបានច្បាស់លាស់ មុននឹងបង្ហោះខ្លឹមសារនៅលើប្រព័ន្ធអ៊ីនធឺណិត មានដូចជា រូបថត វីដេអូ ពាក្យពេចន៍ ឬអត្ថបទនានា ហើយចូលពិភាក្សាជាមួយកុមារ និងយុវជនអំពីហានិភ័យនានាដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការជួបដោយផ្ទាល់ជាមួយ "មិត្តភក្តិ" ដែលស្គាល់តាមរយៈប្រព័ន្ធអ៊ីនធឺណិត។

ក្រៅពីវិធីសាស្ត្រទាំងនេះ អង្គការផ្លែន ក៏បានណែនាំដែរថា អាណាព្យាបាលត្រូវបង្រៀនកុមារ និងយុវជនឱ្យចេះពិចារណា និងវាយតម្លៃព័ត៌មាននៅលើប្រព័ន្ធអ៊ីនធឺណិត និងត្រូវតាមដានពីគោលបំណងនៃការប្រើប្រាស់ ប្រវត្តិនៃការប្រើប្រាស់ និងប្រភពនៃការស្វែងរកព័ត៌មានរបស់កុមារ និងយុវជននៅលើប្រព័ន្ធអ៊ីនធឺណិត។ អង្គការផ្លែនបានបន្តថា៖«ត្រូវលើកទឹកចិត្តកុមារ និងយុវជន បង្កើតទំនាក់ទំនងនៅលើប្រព័ន្ធអ៊ីនធឺណិតជាមួយតែជនណា ឬ បុ

គួលណាដែលពួកគេធ្លាប់ស្គាល់នៅខាងក្រៅប្រព័ន្ធអ៊ីនធឺណិតប៉ុណ្ណោះ។ ត្រូវចូលរួមជាមួយកុមារ និងយុវជនក្នុងការប្រើប្រាស់ និងស្វែងរកព័ត៌មាននានានៅលើប្រព័ន្ធអ៊ីនធឺណិត។ ត្រូវបិទតំណភ្ជាប់ ឬវេបសាយណាដែលមិនផ្ដល់អត្ថប្រយោជន៍ និងមិនគួរឱ្យទុកចិត្ត»។ ជាមួយនឹងវិធីសាស្ត្រទាំងនោះ អង្គការភ្លែន ក៏បានណែនាំឱ្យអាណាព្យាបាលទាំងអស់ មិនត្រូវបដិសេធខ្លាំងហួសហេតុពេកចំពោះការប្រើប្រាស់របស់កុមារ និងយុវជននៅលើប្រព័ន្ធអ៊ីនធឺណិតនោះទេ។

លោកយី គឹមថាន នាយករងប្រចាំប្រទេសទទួលបន្ទុកកម្មវិធីនៃអង្គការភ្លែនអន្តរជាតិកម្ពុជា បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី៣ ឧសភាថា ការចេញសារ និងគន្លឹះណែនាំអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអ៊ីនធឺណិតក្នុងពេលនេះ ក៏ព្រោះតែដើម្បីចូលរួមអបអរទិវាក្មេងស្រីក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍អន្តរជាតិ (ICT)។ លោកបានបន្តថា គន្លឹះទាំងនោះ គឺជាវិធីសាស្ត្រដ៏ចាំបាច់ ដើម្បីជួយរំឭកទៅដល់អាណាព្យាបាល និងមាតាបិតាក្នុងការការពារកុមារឱ្យចៀសផុតពីការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតព្រោះការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតគឺជារឿងមួយដ៏រសើប និងត្រូវយកចិត្តទុកដាក់ ស្របពេលដែលមានកុមាររងគ្រោះគួរឱ្យព្រួយបារម្ភ។ លោកបានបញ្ជាក់ថា៖«ឪពុកម្ដាយ គឺជាតួអង្គមួយសំខាន់ នៅក្នុងការជួយទៅដល់កូនគាត់ ដើម្បីធ្វើម៉េចឱ្យកូនគាត់ចៀសផុតពីការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដោយសារឪពុកម្ដាយ គឺជាអ្នកដែលនៅជិតកូន និងជាអ្នកដែលដើរតួនាទីតាមដានផ្ដល់ឱវាទទៅដល់កូន។ កន្លងមក យើងមើលឃើញថា ឪពុកម្ដាយមួយចំនួន គាត់មិនបានចាប់អារម្មណ៍ និងយល់នោះទេ»។

តាមលទ្ធផលនៃការសិក្សាក្នុងឆ្នាំ២០២២ របស់ UNICEF សហការជាមួយ Interpol និង EPACT បានបង្ហាញថា មានកុមាររាប់រយនាក់នៅក្នុងប្រទេសកម្ពុជា កំពុងទទួលរងនូវការកេងប្រវ័ញ្ចផ្លូវភេទ ហើយការរំលោភបំពានលើអ៊ីនធឺណិត មានដល់១១ ភាគរយ នៃកុមារដែលប្រើអ៊ីនធឺណិត ដែលមានអាយុចាប់ពី១២ ដល់១៧ឆ្នាំ។ ការសិក្សានេះ ក៏បានរកឃើញដែរថា កុមាររងគ្រោះទាំងនោះ គឺត្រូវបានទទួលរងយ៉ាងច្បាស់ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត និងការរំលោភបំពាននៅក្នុងឆ្នាំដែលពួកគេត្រូវបានអង្កេត។ នេះបើតាមការសិក្សារបស់អង្គការទាំងនោះ បន្ទាប់ពីបានសិក្សាទៅលើកុមារប្រមាណ១៦០ ០០០នាក់៕

## អង្គការសង់ត្រាល់រកឃើញថា
## ពលករខ្មែរ ៨០០នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ចាប់តាំងពីក្រោយពិធីបុណ្យចូលឆ្នាំ

https://www.rfa.org/khmer/news/human-rights/central-asks-government-to-intervene-with-thai-authorities-to-release-a-group-of-cambodian-workers-who-crossed-the-border-into-thailand-illegally-05042023133504.html ដោយ សេក បណ្ឌិត 2023.05.04

អង្គការសង់ត្រាល់ (CENTRAL) ស្នើទៅរដ្ឋាភិបាលជួយអន្តរាគមន៍ទៅសមត្ថកិច្ចថៃ ដោះលែងពលករខ្មែរដែលត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន។ សំណើនេះធ្វើក្រោយពេលអង្គការការពារសិទ្ធិពលករមួយនេះរកឃើញថា ពលករខ្មែរជាង ៨០០នាក់ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ក្រោយចប់ពិធីបុណ្យចូលឆ្នាំថ្មី។ អង្គការសង់ត្រាល់ (CENTRAL) រកឃើញថា ពលករខ្មែរភាគច្រើនត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ពួកគាត់ត្រូវបានរងការធ្វើទុក្ខទោសទារុណកម្ម ដោយការចាប់ដាក់ខ្នោះ និងត្រូវដាក់ឱ្យជាប់ឃុំក្នុងបន្ទប់តូចចង្អៀត។

សេចក្ដីថ្លែងការណ៍របស់អង្គការសង់ត្រាល់ចុះ កាលពីថ្ងៃទី៣ ខែឧសភា ឱ្យដឹងថា នៅរយៈពេលចុងក្រោយនេះ ពលករខ្មែរជាង ៨០០នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនកំឡុងពេលធ្វើដំណើរវិលត្រឡប់ទៅបំពេញការងារវិញនៅប្រទេសថៃក្រោយចប់បុណ្យចូលឆ្នាំថ្មី។ ពលករទាំងនោះគ្មានឯកសារគ្រប់គ្រាន់ ឯកសារផុតសុពលភាព ឬ

ការធ្វើដំណើរពួកគាត់មិនត្រឹមត្រូវតាមនីតិវិធីរបស់ថៃ និងពលករខ្លះទៀត លួចឆ្លងដែនតាមច្រករបៀង ព្រោះគ្មានលទ្ធភាពបង់ប្រាក់តាមច្រកព្រំដែនផ្លូវការ ជាដើម។ អង្គការសង់ត្រាល់ ស្នើទៅរដ្ឋាភិបាលកម្ពុជា ឬសមត្ថកិច្ចពាក់ព័ន្ធ ជួយអន្តរាគមន៍ និងស្វែងរកដំណោះស្រាយជាមួយភាគីថៃ ដើម្បីឱ្យពលករដែលកំពុងជាប់ឃុំទទួលបានសេរីភាពឡើងវិញ។

មន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៤ ខែឧសភាថា ទីតាំងដែលសមត្ថកិច្ចថៃចាប់ពលករខ្មែរមានពីរកន្លែង គឺនៅព្រំដែន និងកន្លែងពលករស្នាក់នៅឬកន្លែងពួកគាត់ធ្វើការ។ លោកសង្កេតឃើញទៀតថា ក្រុមពលករមួយចំនួនដែលត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួននៅព្រំដែន មានការសម្របសម្រួល ឬការជួយធ្វើអន្តរាគមន៍ពីអាជ្ញាធរខ្មែរខ្លះដែរ ដែលធ្វើឱ្យពលករទាំងនោះអាចវិលទៅស្រុកវិញ។ ដោយឡែក លោកថា ចំពោះពលករដែលសមត្ថកិច្ចថៃចាប់ខ្លួននៅកន្លែងស្នាក់នៅ ឬកន្លែងធ្វើការងារភាគច្រើនកំពុងជាប់ឃុំព្រោះមិនមានការអន្តរាគមន៍ពីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ឬមានការជួយធានាពីថៅកែរបស់ពលករទាំងនោះ។ មន្ត្រីសង្គមស៊ីវិលធ្វើការងារការពារសិទ្ធិពលកររូបនេះ យល់ថា ប្រសិនបើមន្ត្រីស្ថានទូតខ្មែរស្វះស្វែងជួយធ្វើអន្តរាគមន៍ នោះពលករដែលកំពុងជាប់ឃុំ អាចនឹងត្រូវសមត្ថកិច្ចថៃដោះលែងពួកគេឱ្យមានសេរីភាពឡើងវិញ។

លោក លឹង សុផុន៖ «បើសិនជាអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ ដូចជា ស្ថានទូត គាត់ចុះជួយសម្របសម្រួលផ្តល់ភាពកក់ក្តៅដល់បងប្អូនពលករ ខ្ញុំក៏ជឿជាក់ថា ពលករនឹងអាចបានចេញពីមន្ទីរឃុំឃាំងឆាប់ៗ នេះបាទដែរបាទ ក្នុងមន្ទីរឃុំឃាំងមើលលំបាករស់នៅ ហើយការហូបចុក ក៏លំបាក»។ លោក លឹង សុផុន ឱ្យដឹងទៀតថា លោកបានទាក់ទងទៅពលករមួយចំនួន ដែលកំពុងជាប់ឃុំពួកគាត់ថា ពួកគាត់ជាប់ឃុំជាង ១ខែមកនេះ តែមិនទាន់ឃើញមន្ត្រីស្ថានទូតខ្មែរ ឬតំណាងរបស់ពួកគាត់ មកជួយធ្វើអន្តរាគមន៍នៅឡើយទេ។

ទាក់ទងបញ្ហានេះ វិទ្យុអាស៊ីសេរីមិនអាចសុំបំភ្លឺពីមន្ត្រីអនុព័ន្ធការងារនៃស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ លោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេសលោក អាន សុខខឿន និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បានទេ នៅថ្ងៃទី៤ ខែឧសភា។

ពលករខ្មែរធ្វើការនៅផ្សារមួយកន្លែងក្នុងខេត្តប៉ាធុមថានី (Pathum Thani) ដែលត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនកាលពីថ្ងៃទី២៤ ខែមេសា លោក ព្រំ ប៊ុនថន ឱ្យវិទ្យុអាស៊ីសេរីដឹងថា សមត្ថកិច្ចថៃចាប់ខ្លួនលោក ព្រោះ ឯកសារការងាររបស់លោកមិនគ្រប់គ្រាន់។ លោកឱ្យដឹងទៀតថា ពេលនេះថៅកែរបស់លោកទៅបង់ប្រាក់មួយចំនួនទៅសមត្ថកិច្ចថៃ ដើម្បីសុំធានាឱ្យលោកនៅក្រៅឃុំ តែលោកមិនដឹងថា អស់ប្រាក់ប៉ុន្មានឡើយ ហើយថៅកែរបស់លោកក៏អះអាងដែរថា គេមិនយកប្រាក់ធានាលោកដែរ។ លោក ព្រំ ប៊ុនថន ឱ្យដឹងទៀតថា កាលពីលោកជាប់ឃុំមានពលករខ្មែរជិត១០នាក់ទៀត មិនទាន់ត្រូវបានសមត្ថកិច្ចថៃដោះលែងទេ ព្រោះគ្មានថៅកែមកធានា ឬមានការអន្តរាគមន៍ពីមន្ត្រីស្ថានទូតខ្មែរ។ លោក ព្រំ ប៊ុនថន៖ «ខ្ញុំក៏សំពះអរគុណទឹកចិត្តរបស់គាត់ (ថៅកែ) ទី១ ឯកសារអត់គ្រប់ ធ្វើហើយតែធ្វើអត់បានដល់អ៊ីចឹងទៅយើងទៅទៅបន្តឯកសារអត់បានដល់ពេលជួបបញ្ហាហ្នឹងគេថា ដាច់ឯកសារហើយអត់ទៅត (បន្តឯកសារ)។

អង្គការសង់ត្រាល់លើកឡើងថា ករណីសមត្ថកិច្ចថៃចាប់ខ្លួនពលករនៅពេលនេះ មិនត្រឹមតែ កំពុងជះឥទ្ធិពលអវិជ្ជមាន មកលើសេដ្ឋកិច្ច និងជីវភាពប្រចាំថ្ងៃរបស់ក្រុមគ្រួសារពលករ ដោយសារការមិនមានប្រាក់ចំណូល ការកើនឡើងនៃបំណុល និងផលប៉ះពាល់សុខភាពផ្លូវចិត្តជាដើម។ របាយការណ៍របស់អង្គការសង់ត្រាល់ រកឃើញទៀតថា ត្រឹមរយៈពេល ៤ខែ ចាប់ពីខែមករា ដល់ខែមេសា សមត្ថកិច្ចថៃ បានឃាត់ខ្លួនពលករកម្ពុជា ដែលឆ្លងដែន

ខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃមានជាង ១.២០០នាក់ (១.២៩៧) ក្នុងស្ត្រីជាង ៧០០នាក់ និងកុមារជាង ៦០នាក់៕

## អ្នកជំនាញច្បាប់
## និងសិទ្ធិមនុស្សជំរុញឱ្យរដ្ឋាភិបាលប្ដឹងអ.ស.បករណីថៃយកច្រវាក់ចងពលករខ្មែរ

https://www.rfa.org/khmer/news/human-rights/legal-and-human-rights-experts-urge-govt-to-sue-thai-authorities-for-handcuffing-cambodian-workers-to-un-05042023075426.html ដោយ សេក បណ្ឌិត 2023.05.04

អ្នកជំនាញធ្វើការងារផ្នែកច្បាប់ និងសិទ្ធិមនុស្សជំរុញដល់អាជ្ញាធរឱ្យមានវិធានការដាក់លាក់រួមទាំងប្ដឹងទៅអង្គការសហប្រជាជាតិផង ករណីសមត្ថកិច្ចថៃចាប់ពលករខ្មែរដាក់ច្រវាក់ជាក្រុមៗ។ ទោះជារូបភាពដាក់ច្រវាក់នោះផ្សព្វផ្សាយ ប្រមាណកន្លះខែមក ហើយក៏ដោយ ក៏នៅមិនទាន់មានឃើញប្រតិកម្មជាក់លាក់ណាមួយពីអាជ្ញាធរកម្ពុជាទេ។ អ្នកជំនាញធ្វើការលើផ្នែកច្បាប់ និងសិទ្ធិមនុស្សចាត់ទុកសកម្មភាពសមត្ថកិច្ចថៃចាប់ពលករខ្មែរដាក់ច្រវាក់ជាក្រុមៗនោះ ជាទម្រង់នៃការធ្វើទារុណកម្ម និងប្រមាថជាតិសាសន៍ហើយរដ្ឋាភិបាលមានកាតព្វកិច្ចចេញសេចក្ដីថ្លែងការណ៍ប្រតិកម្ម ឬប្ដឹងទៅអង្គការសហប្រជាជាតិ។

ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់ លោក ឌីថេ ហូយ៉ា មានប្រសាសន៍ថា រូបភាពពលរដ្ឋខ្មែរ ជាប់ច្រវាក់ ជាក្រុមនោះ គឺជាសកម្មភាពដែលយោធាថៃចុះបង្ក្រាបអ្នករស់នៅក្នុងទីក្រុងបាងកកខុសច្បាប់។ លោក ឌីថេ ហូយ៉ា បន្តថា ពេលនោះសមត្ថកិច្ចថៃចាប់ខ្លួន ពលករបរទេស ជាង ៨០០នាក់។ លោក ឌីថេ អូយ៉ា ចាត់ទុកសកម្មភាពសមត្ថកិច្ចថៃនេះថា ហួសពីវិធានការអនុវត្តន៍ច្បាប់ ហើយបើមិនមានវិធានការពីអាជ្ញាធរកម្ពុជាទេ នោះពលរដ្ឋខ្មែរនឹងបន្តរងគ្រោះច្រើនទៀត។ លោក ឌីថេ ហូយ៉ាៈ «នៅពេលដែលមានការអនុវត្តនូវអំពើទារុណកម្មវាលើសពីមនុស្សធម៌សិទ្ធិមនុស្ស ទាំងអស់ហ្នឹងវាគួរតែចេញសេចក្ដីថ្លែងការណ៍ណាមួយបញ្ឈប់កុំឱ្យមានរូបភាពបែបហ្នឹងទៀត។ អាហ្នឹងរូបភាពដែលយើងឃើញចុះរូបភាពដែលយើងមិនឃើញច្រើនទៀត។ វាអាចកើតមានលើពលរដ្ឋយើង អ៊ីចឹងហើយរដ្ឋាភិបាលត្រូវគិតគូរលើបញ្ហាហ្នឹង»។ រូបភាពដែលចែកចាយតាមបណ្ដាញទំនាក់ទំនងសង្គមគឺមានមនុស្សវ័យកណ្ដាលអាយុពី២០ ទៅ៤៥ឆ្នាំ ដៃជាប់ច្រវាក់ភ្ជាប់គ្នាជាក្រុមអង្គុយលើឡានទ្រុងសមត្ថកិច្ច ក្នុងស្ថានភាពទឹកមុខស្រពោន ខ្លះក៏ឱនមុខចុះក្រោម។

សាស្ត្រាចារ្យ និងជាអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់លោក ស៊ឹម វិបុល ពន្យល់ថា ពលរដ្ឋដែលឆ្លងដែនឬរស់នៅក្នុងប្រទេសណាមួយខុសច្បាប់ ម្ចាស់ប្រទេសមានសិទ្ធិចាប់ខ្លួន។ ប៉ុន្តែលោកថា ករណីសមត្ថកិច្ចថៃដាក់ច្រវាក់ពលរដ្ឋខ្មែរនេះជា ជាទម្រង់ នៃការធ្វើទារុណ ឬប្រមាថមើលងាយ។ លោកបន្តថា ករណីនេះ កម្ពុជាជាប្រទេសសាមីមានកាតព្វកិច្ចដាក់កំណត់ទូត ទៅរដ្ឋាភិបាលថៃ ឬប្ដឹងទៅស្ថាប័នអន្តរជាតិនានារួមទាំងអង្គការសហប្រជាជាតិ។ លោក លោក ស៊ឹម វិបុលៈ «ក្នុងច្បាប់អន្តរជាតិគេអនុញ្ញាតឱ្យយើងក្នុងឋានៈជារដ្ឋហ្នឹងធ្វើកំណត់ទូតដើម្បីតវ៉ាទាមទារឱ្យគេ អនុវត្តន៍តាមបទដ្ឋាន ឬស្តង់ដារសិទ្ធិមនុស្សអ៊ីចឹងទៅ។ ដំបូងរដ្ឋទ្វេភាគីហ្នឹងហើយបើអត់ទេ យើងត្រូវមានសិទ្ធិធ្វើរបាយការណ៍ធ្វើអីចឹងទៅដាក់ចូលទៅក្នុងសន្និបាតអង្គការសិទ្ធិមនុស្សអីចឹងទៅដើម្បីតវ៉ារឿងហ្នឹង»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេសលោក អាន សុខឃឿន និងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដើម្បីអត្ថាធិប្បាយបានទេ នៅថ្ងៃទី៣ ខែមីនា។ លោក អាន សុខឃឿន ប្រាប់វិទ្យុបារាំងផ្សាយជាខេមរភាសាថា រូបភាពជាប់ច្រវាក់ ដៃជាក្រុមនោះពិតជារូបពលករខ្មែរដែលសមត្ថកិច្ចថៃចាប់ខ្លួនមែន។

ទោះយ៉ាងណាទាំងក្រសួងការបរទេសកម្ពុជា និងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃមិនឃើញមានវិធានការច្បាស់លាស់លើករណីនេះទេ។ សូម្បីតែនៅលើផេកហ្វេសប៊ុក របស់ស្ថាប័នទាំង២ ក៏មិនឃើញមាននិយាយពីពលករខ្មែរដែលរងការធ្វើបាបនេះដែរ។

អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក ស៊ឹង សែនករុណា ជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបើកការស៊ើបអង្កេតលើករណីនេះ ដើម្បីស្វែងរកការពិត។ លោកបន្តថា បើរកឃើញសមត្ថកិច្ចថៃបានធ្វើបែបនេះមែន គឺជាការរំលោភបំពាន ដែលកម្ពុជាត្រូវមានវិធានការបន្ត។ លោក ស៊ឹង សែនករុណា៖ «បើសិនជារកឃើញរឿងនេះកើតឡើងតែលើពលរដ្ឋកម្ពុជា យើងអាចចោទប្រកាន់ថា ថៃកំពុងតែប្រព្រឹត្តិដោយរើសអើងលើជនជាតិកម្ពុជាតែម្តង។ អ៊ីចឹងចំណុចទាំងអស់នេះនៅក្នុងគោលការណ៍សេចក្តីប្រកាសជាសកល និងកតិកាសញ្ញាសិទ្ធិពលរដ្ឋ និងនយោបាយរបស់អន្តរជាតិហ្នឹង គឺគេហាមដាច់ខាតពីការរើសអើងជាតិសាសន៍ ឬក៏សាសនា»។

លោក ឌីថេ ហូយ៉ា បញ្ជាក់ថា នេះគ្រាន់តែរូបភាពដែលមានការចែកចាយតាមបណ្តាញសង្គមតែប៉ុណ្ណោះ ហើយលោកបារម្ភថា សកម្មភាពការធ្វើទារុណផ្សេងៗ ទៀតក៏កើតមានដែរតែមិនមានអ្នកដឹង ខណៈលោកថា សន្ទុះពលករខ្មែរសម្រុកឆ្លងដែនទៅរកការងារធ្វើនៅក្នុងប្រទេសថៃ មិនមានការថយចុះនោះទេ។ ទន្ទឹមនឹងពលរដ្ឋជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬជាប់បំណុលកាន់តែច្រើន ហើយធ្វើចំណាកស្រុកទៅទៅថៃបន្តបន្ទាប់ទាំងប្រឈមគ្រោះថ្នាក់នេះ លោកហ៊ុន សែន ក៏បន្តផ្សព្វផ្សាយពីរដ្ឋាភិបាលដែលលោកដឹកនាំមានបេះដូងធំ មានចិត្តល្អ។

លោក ហ៊ុន សែន ថ្លែងថា ការមិនគិតលុយពីប្រតិភូបរទេសមកចូលរួម ការប្រកួតស៊ីហ្គេមនេះជាចំណុចនៃទឹកចិត្តល្អរបស់លោកដែលធ្លាប់ធ្វើកន្លងមកជាច្រើន។ លោកបន្តថា បើកម្ពុជាជាប្រទេសមានទ្រព្យសម្បត្តិច្រើន លោកនឹងធ្វើល្អ ឱ្យបានជាងនេះឱ្យពិភពលោកដឹង។ លោក ហ៊ុន សែន៖ «សម្រាប់កម្ពុជាប្រទេសតូចក្រតែថ្លើមធំ។ ខ្លះវាបង្អាប់ឯងថាថ្លើមធំហ្នឹងទាល់តែមហារីក តែសូមបញ្ជាក់ នេះជាទឹកចិត្តរបស់កម្ពុជាដែលកម្ពុជាមាន។ ហើយខ្ញុំជម្រាបជូន បើខ្ញុំមានប៉ុណ្ណឹងខ្ញុំផ្តល់ជំនួយទៅក្រៅប្រទេសច្រើន សូម្បីតែក្រប៉ុណ្ណឹងពេលកូវីដខ្ញុំនាំជំនួយទៅដល់នេប៉ាល់ ទីម័រឡេស្ត ដល់វៀតណាម ដល់ឡាវ ដល់មីយ៉ាន់ម៉ា ហើយហ៊ានផ្តល់ជំនួសទៅដល់គុយប៉ា»។ នៅលើហ្វេសប៊ុកផេករបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏មិនមានប្រតិកម្ម ចំពោះសមត្ថកិច្ចថៃយកច្រវាក់ចងពលរដ្ឋខ្មែរនេះដែរ។

របាយការណ៍អង្គការសង់គ្រាល់បង្ហាញថា ពលរដ្ឋកម្ពុជាកំពុងធ្វើការនៅក្នុងប្រទេស ថៃមានប្រមាណ២លាននាក់ ក្នុងនោះពាក់កណ្តាលមិនមានឯកសារស្របច្បាប់ទេ។ ទន្ទឹមនឹងនេះ ពលរដ្ឋដែលបាត់បង់ការងារធ្វើក្នុងវិស័យសំណង់ ការងាររោងចក្រ និងកសិកម្ម បានបន្តឆ្លងដែនទៅប្រទេសថៃរកការងារធ្វើរាល់ថ្ងៃ៕

# អង្គការសង់ត្រាល់៖
# ពលករខ្មែរជាងមួយពាន់នាក់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនក្នុងពេលបួនខែចុងក្រោយ

https://khmer.voanews.com/a/about-a-thousand-cambodian-migrant-workers-arrested-in-thailand-finds-report/7078381.html ០៤ ឧសភា ២០២៣ហាន ណូយ

ភ្នំពេញ៖ គិតចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ ២០២៣ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃចំនួនជាង ១.០០០ នាក់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ដែលនេះបង្កជាក្ដីបារម្ភយ៉ាងខ្លាំងដល់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (Central)។ ក្នុងចំណោមពលករទាំងនោះ ក៏មានពលករខ្មែរដែលត្រូវអាជ្ញាធរថៃ ចាប់ដាក់ខ្នោះច្រវាក់នៅនឹងដៃ ហើយត្រូវគេថតបាន និងយកមកផ្សព្វផ្សាយនៅលើបណ្ដាញទំនាក់ទំនងសង្គមកាលពីពេលថ្មីៗនេះ។

បើតាមសេចក្ដីថ្លែងការណ៍ ស្ដីពីការចាប់ខ្លួនពលករកម្ពុជាពីសំណាក់អាជ្ញាធរថៃ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០២៣ មានការចាប់ខ្លួនពលករខ្មែរជាបន្តបន្ទាប់ ក្រោយពួកគេត្រឡប់មកពីប្រទេសកម្ពុជានៅក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ដោយសារតែពួកគេខ្លះគ្មានឯកសារស្របច្បាប់គ្រប់គ្រាន់ ហើយអ្នកខ្លះទៀតមានឯកសារអនុញ្ញាតឱ្យធ្វើការនៅប្រទេសថៃស្របច្បាប់ តែអស់សុពលភាព។ សេចក្ដីថ្លែងការណ៍ដដែលលើកឡើងថា នៅក្នុងរយៈពេលបួនខែនេះ ករណីនៃការឃាត់ខ្លួនពលករកម្ពុជាដែលឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចំនួន ២៥ ករណី ហើយមានជនរងគ្រោះសរុបចំនួន ១.២៩៧ នាក់ ក្នុងនោះជាង ៧០០ នាក់ជាស្ត្រី និងជាង ៦០ នាក់ជាកុមារ។ សេចក្ដីថ្លែងការណ៍បញ្ជាក់ថា៖ «ពលករខ្មែរភាគច្រើនត្រូវបានចាប់ឃាត់ខ្លួន និងទទួលរងការធ្វើទុក្ខទោស ទារុណកម្ម ការចាប់ដាក់ខ្នោះ និងការចាប់ឃុំខ្លួនបណ្ដោះអាសន្នពីសំណាក់អាជ្ញាធរថៃ ដោយសារតែពួកគេពុំមានឯកសារគ្រប់គ្រាន់ ឬក៏ផុតសុពលភាព ឬក៏ការធ្វើដំណើរមិនត្រឹមត្រូវតាមនីតិវិធី និងមិនមានលទ្ធភាពក្នុងការបង់ប្រាក់តាមច្រកព្រំដែនផ្លូវការ»។ បើតាមសេចក្ដីថ្លែងការណ៍ ក្រោយពួកគេត្រូវបានចាប់ខ្លួន ពួកគេទាំងនោះត្រូវបានឃុំខ្លួននៅក្នុងអគារតូចចង្អៀត ដែលការណ៍នេះបានបង្កផលប៉ះពាល់ទៅលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេ និងជះផលអវិជ្ជមានទៅលើសេដ្ឋកិច្ចគ្រួសាររបស់ពួកគេផងដែរ។

ប្រធានផ្នែកប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា ប្រាប់វីអូអេតាមប្រព័ន្ធតេឡេក្រាមថា ការចាប់ពលករខ្មែរដោយការដាក់ច្រវាក់ មិនមែនជាការអនុវត្តច្បាប់ឡើយ ប៉ុន្តែជាអំពើអមនុស្សធម៌។ លោកថ្លែងថា៖ «គាត់អត់មានឯកសារ អាជ្ញាធរថៃចាប់ហ្នឹងក៏មានការទាក់ច្រវាក់អីហ្នឹងដូចបានឃើញតាមរូបភាពគេបង្ហោះ ហើយមានការជំរិតទារលុយ ដែលវាជាទង្វើមួយមិនឆ្លុះបញ្ចាំងពីការអនុវត្តច្បាប់ទេ ផ្ទុយទៅវិញ វាជាអំពើហិង្សាអមនុស្សធម៌»។

វីអូអេមិនទាន់អាចសុំការអត្ថាធិប្បាយពី លោក អាន សុខខឿន អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា និងលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ បាននៅឡើយទេនៅថ្ងៃព្រហស្បតិ៍នេះ ទាំងតាមប្រព័ន្ធទំនាក់ទំនងតេឡេក្រាម និងទូរសព្ទ។

យោងតាមរបាយការណ៍ឆ្នាំ ២០១៩ របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) មួយភាគបីនៃពលករចំណាកស្រុកដែលត្រូវបានគេសាកសួរព័ត៌មាន ពុំមានការងារធ្វើក្នុងស្រុក មុនពេលពួកគេចេញពីកម្ពុជា។ ជិតពាក់កណ្ដាល គឺគ្មានចំណូល និងប្រហែលពីរភាគបីបានសម្រេចចិត្តទៅប្រទេសថៃ ដើម្បីស្វែងរកការងារដោយសារពុំមានឱកាសការងារនៅក្នុងស្រុក និងដោយសារចង់បានចំណូលប្រសើរជាងមុន។ របាយការណ៍បង្ហាញថា ចំនួនពាក់កណ្ដាលនៃអ្នកដែលត្រូវបានសម្ភាសបានផ្ញើប្រាក់ត្រឡប់ទៅស្រុកកំណើតប្រមាណ ១.២២៨ ដុល្លារក្នុងមួយ

ឆ្នាំ។ ប្រាក់ទាំងនេះ គឺជាប្រាក់ចំណូលចម្បងសម្រាប់ទំនុកបម្រុងគ្រួសារនៅប្រទេសកម្ពុជា ឬក៏ដើម្បីប្រើប្រាស់ធ្វើឲ្យជីវភាពប្រសើរឡើង។

ក្នុងពេលចូលរួមពិធីសង្ក្រាននៅប្រទេសថៃ កាលពីថ្ងៃទី ៩ ខែមេសា រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង ក៏បានលើកឡើងថា ពលករខ្មែរ ១ លាន ២ សែននាក់កំពុងធ្វើការក្នុងប្រទេសថៃ ហើយក្នុងម្នាក់ៗបានផ្ញើប្រាក់ទៅផ្ទះចំនួន ១៦៧ ដុល្លារអាមេរិកក្នុងមួយខែ។ នេះបើយោងតាមសារដែលបង្ហោះនៅលើហ្វេសប៊ុករបស់ក្រសួងការងារ។៕

# ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៧នាក់

https://freshnewsasia.com/index.php/en/localnews/289971-2023-05-05-04-30-00.html 2023-05-05 11:30am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន ០៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៨៦៥ករណី មានមនុស្ស ២,១៥៣នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨២៥សំណើ និងបិទសំណុំរឿង ២៨២សំណើ (រកឃើញមនុស្ស ១,២៣៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣១នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៦៥ករណី៕

## អង្គការសង់ត្រាល់បារម្ភពីការកើនឡើងនៃករណីចាប់ខ្លួនពលករចំណាកស្រុកខ្មែរនៅថៃ ខណៈមន្ត្រីកម្ពុជាកំពុងដោះស្រាយរឿងនេះ

https://www.postkhmer.com/national/2023-05-04-1819-249698.html សំបាន ច័ន្ទដារ៉ា | Publication date 04 May 2023 | 18:19 ICT

**ភ្នំពេញៈ** មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បង្ហាញក្ដីបារម្ភជុំវិញកំណើននៃការឃាត់ខ្លួនពលករកម្ពុជាដោយអាជ្ញាធរថៃ អំឡុងពេលពួកគេធ្វើដំណើរឆ្លងដែនចូលរកការងារធ្វើនៅទឹកដីថៃ ពិសេសអំឡុងពេលក្រោយពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរកន្លងទៅ ខណៈមន្ត្រីកម្ពុជាកំពុងដោះស្រាយករណីនេះ។ ការលើកឡើងពីក្ដីព្រួយបារម្ភរបស់អង្គការសង់ត្រាល់ដូច្នេះ ធ្វើឡើងតាមរយៈសេចក្ដីថ្លែងការណ៍ កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីការចាប់ខ្លួនពលករកម្ពុជាពីសំណាក់អាជ្ញាធរថៃ ដោយបានបញ្ជាក់ថា ការឃាត់ខ្លួនពលករកម្ពុ

ជាដែលចំណាកស្រុកនៅទឹកដីថៃនេះ ពាក់ព័ន្ធនឹងការគ្មានឯកសារស្របច្បាប់គ្រប់គ្រាន់ ឬអស់សុពលភាពឯកសារ ឬក៏ការធ្វើដំណើរមិនត្រឹមត្រូវតាមនីតិវិធីនិងមិនមានលទ្ធភាពបង់ប្រាក់តាមច្រកព្រំដែនផ្លូវការ។

សេចក្ដីថ្លែងការណ៍អះអាងថា៖ «តាមរយៈការអង្កេត និងការកត់ត្រាទិន្នន័យរបស់អង្គការសង់ត្រាល់យើងបានរកឃើញថា ក្នុងរយៈពេល៤ខែ ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២៣ ករណីនៃការឃាត់ខ្លួនពលករកម្ពុជាដែលឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលមានរហូតដល់២៥ករណី ក្នុងនោះមានជនរងគ្រោះចំនួន ១ ២៩៧នាក់ ស្ត្រីជាង ៧០០នាក់ និងកុមារជាង៦០នាក់»។ ប្រភពដដែលបានបន្តថាពលករខ្មែរភាគច្រើនត្រូវបានចាប់ឃាត់ខ្លួន និងទទួលរងការធ្វើទុក្ខទោស ទារុណកម្ម ការចាប់ដាក់ខ្នោះ និងចាប់ឃុំខ្លួនបណ្ដោះអាសន្នពីសំណាក់អាជ្ញាធរថៃ។ ពលករខ្មែរជាច្រើនបានត្រូវឃុំខ្លួនក្នុងអគារដែលមានលក្ខណៈតូចចង្អៀត។ ទាក់ទងនឹងករណីនេះដែរ អង្គការសង់ត្រាល់ បានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា ពិសេសអាជ្ញាធរមានសមត្ថកិច្ច ជួយអន្តរាគមន៍ និងស្វែងរកដំណោះស្រាយជាមួយភាគីថៃ ក្នុងការដោះលែងពលករកំពុងជាប់ឃុំឱ្យមានសេរីភាពឡើងវិញ និងការពារសិទ្ធិរបស់ពួកគេឱ្យមានសុខសុវត្ថិភាពទាំងពេលធ្វើដំណើរ ស្នាក់នៅ និងធ្វើការនៅប្រទេសគោលដៅ។

អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោក ហេង សួរ មិនអាចទាក់ទងសុំការអធិប្បាយទាក់ទងនឹងករណីនេះបានទេ។

ក៏ប៉ុន្តែ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ (គ.ជ.ប.ជ) បានឱ្យដឹងតាមរយៈតេឡេក្រាមកាលពីល្ងាចថ្ងៃទី៣ ខែឧសភា ថាក្រសួងការងារកម្ពុជាបានជួបពិភាក្សាជាមួយក្រសួងការងារថៃកាលពីសប្ដាហ៍មុន។ លោកស្រីបានបញ្ជាក់ថា ៖ « ចំណែកខ្ញុំនឹងដឹកនាំគណៈប្រតិភូអន្តរស្ថាប័នទៅពិនិត្យស្ថានភាពពលករតាមការអញ្ជើញរបស់ភាគីថៃ។ សង្ឃឹមថាអាចរកឃើញដំណោះស្រាយមួយចំនួន»។ សូមបញ្ជាក់ដែរថា កាលពីដើមខែមេសា លោកស្រី ជូ ប៊ុនអេង បានពិភាក្សាជាមួយអន្តរក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ។ បើតាមក្រសួងមហាផ្ទៃ កិច្ចពិភាក្សានេះធ្វើឡើងដើម្បីរកដំណោះស្រាយសមស្របក្នុងនីតិវិធីនៃការផ្ដល់ភាពស្របច្បាប់ សម្រាប់ពលករនៅក្នុងប្រទេសថៃ ដើម្បីចៀសវាងបញ្ហាដដែលៗដែលពលករនៅតែមិនទទួលភាពស្របច្បាប់ ។

ពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍របស់អង្គការសង់ត្រាល់ អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោកជិន ម៉ាលីន បានលើកឡើងពីបញ្ហាផ្លូវច្បាប់ថា ជារឿងធម្មតាសម្រាប់ករណីនេះ ដោយសារពលករកម្ពុជាត្រូវតែគោរពច្បាប់របស់ប្រទេសដែលខ្លួនអាស្រ័យការងារ តួយ៉ាងដូចករណីនៅប្រទេសថៃនេះ ប្រសិនបើពលករនោះបានបំបានគោលការណ៍ច្បាប់របស់គេទាំងបញ្ញត្តិព្រហ្មទណ្ឌ ឬច្បាប់អន្តោប្រវេសន៍ ពលករត្រូវទទួលខុសត្រូវ ប្រឈមមុខនឹងផ្នែកច្បាប់។ ទោះជាយ៉ាងណាសម្រាប់ដំណោះស្រាយករណីនេះលោក ជិន ម៉ាលីន បានប្រាប់ថា៖ «រដ្ឋាភិបាលកម្ពុជាដែលមានតំណាងស្ថានទូតនៅទីនោះ[ប្រទេសថៃ] ក្នុងការពារសិទ្ធិរបស់ពលរដ្ឋខ្លួនឯងយើងអាចធ្វើការសម្របសម្រួល ផ្ដល់សេវាផ្នែកច្បាប់ផ្សេងៗដើម្បីការពារពលរដ្ឋយើងដែលកំពុងប្រឈមមុខផ្លូវច្បាប់ និងអាចអនុវត្តនូវកិច្ចព្រមព្រៀងផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌរវាងប្រទេសទាំង២»៕

## ឥណ្ឌូណេស៊ីៈ កម្ពុជាមិនមែនជាគោលដៅរបស់ពលករចំណាកស្រុកទេ

https://www.khmertimeskh.com/501285469//?p=1285469 Khmer Times May 6, 2023

កម្ពុជា មីយ៉ាន់ម៉ា និងឡាវ មិនមែនជាប្រទេសគោលដៅសម្រាប់ការបញ្ជូនពលករចំណាកស្រុកឥណ្ឌូណេស៊ីទេ នេះបើយោងតាមទីភ្នាក់ងារការពារពលករចំណាកស្រុកឥណ្ឌូនេស៊ី (BP2MI)។ ប្រមុខ BP2MI លោក Benny Rhamdani បាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា "(ការបញ្ជូនទៅកាន់) ប្រទេសទាំងបីនេះមាននិន្នាការសម្រាប់រយៈពេលពីរឆ្នាំចុងក្រោយនេះ ប៉ុន្តែយើងចង់រំលឹក (ពលករចំណាកស្រុក) ថាប្រទេសទាំងបីមិនមែនជាទិសដៅសម្រាប់ការបញ្ជូនពលករនោះទេ" ។ លោកបានព្រមានថា ដូច្នេះការដាក់ពង្រាយពលករចំណាកស្រុកទៅប្រទេសទាំងបីគឺខុសច្បាប់។ ប្រធានទីភ្នាក់ងារបានកត់សម្គាល់ថា យើងឃើញអ្នកដែលបានចាកចេញបន្ទាប់ពីត្រូវបានបោកប្រាស់ ថាបានប្រាក់ខែខ្ពស់ ឥឡូវនេះមានការសោកស្ដាយ។ ពេលនេះពួកគេតវ៉ាព្រោះពួកគេមិនបានទទួលនូវអ្វីដែលពួកគេបានសន្យា។ ពួកគេត្រូវបានបង្ខាំងទុក ហើយឯកសារធ្វើដំណើររបស់ពួកគេត្រូវបានកាន់កាប់ដោយអ្នកដែលយកពួកគេទៅទីនោះ។

លោក Rhamdani បាននិយាយថា ជនជាតិឥណ្ឌូនេស៊ីរាប់ពាន់នាក់ រួមទាំងមួយចំនួនមកពី North Sulawesi ត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសទាំងបី បន្ទាប់ពីជួបប្រទះបញ្ហានៅពេលធ្វើការនៅទីនោះ។ លោក Rhamdani ពន្យល់ថា "ប្រទេសឥណ្ឌូណេស៊ី មានភាពលេចធ្លោ ព្រោះប្រទេសនេះនៅតែប្រកាន់យកគោលការណ៍សុវត្ថិភាពរបស់ប្រជាជន ដែលត្រូវដាក់ក្នុងច្បាប់កំពូលរបស់ប្រទេស។ នៅពេលដែលពលរដ្ឋជួបបញ្ហាពាក់ព័ន្ធនៅក្រៅប្រទេស ហើយទោះបីជាការស៊ើបអង្កេតនានារកឃើញថាពួកគេបានចាកចេញដោយខុសច្បាប់ក៏ដោយ ក៏រដ្ឋាភិបាលនៅតែជួយសង្គ្រោះពួកគេ។

ជនជាតិឥណ្ឌូនេស៊ីរាប់រយនាក់ដែលបានហោះហើរមកកម្ពុជាក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ត្រូវបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ទៅមាតុប្រទេសវិញ នៅពេលដែលពួកគេត្រូវបានរកឃើញថាជាជនរងគ្រោះនៃការជួញដូរមនុស្ស និងប្រតិបត្តិការឆបោកពាក់ព័ន្ធនឹងល្បែងអនឡាញ។ *Antara News.com*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ២នាក់

https://freshnewsasia.com/index.php/en/localnews/290218-2023-05-06-08-02-59.html 2023-05-06 03:02pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិនចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៨៦៩ករណី មានមនុស្ស ២,១៥៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៤០សំណើ និងបិទសំណុំរឿង ២៩១សំណើ (រកឃើញមនុស្ស ១,២៥២នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣១នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៩ករណី។

## អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ត្រៀមជួយកម្ពុជាក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍

https://www.postkhmer.com/national/2023-05-05-0936-249727.html ភ្នំពេញ ប៉ុស្តិ៍ | Publication date 05 May 2023 | 09:36 ICT

**ភ្នំពេញ៖** លោកស្រី Sarah Lou Arriola ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកថ្មី បានប្តេជ្ញាចិត្ត ត្រៀមខ្លួន ក្នុងការបន្តជួយកម្ពុជា ដើម្បីសម្រេចបាននូវបេសកកម្មរបស់ខ្លួន ក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងការអភិវឌ្ឍធនធានមនុស្ស។ នេះបើយោងតាមផេកហ្វេសប៊ុកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លោកស្រី Sarah Lou Arriola បានថ្លែងបែបនេះ ក្នុងពេលដែលលោកស្រីបានដឹកនាំគណៈប្រតិភូអង្គការ IOM មកទស្សនកិច្ចនៅកម្ពុជា និងបានចូលជួបសម្តែងការគួរសមជាមួយលោក ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារកាលពីថ្ងៃទី ៣ ខែឧសភា។

ក្រៅពីស្វាគមន៍ និងថ្លែងអំណរគុណដល់អង្គការ IOM លោក ហ៊ូ វុឌ្ឍី បានលើកឡើងពីការគាំទ្ររបស់អង្គការ IOM រួមមានការបន្តកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងដល់សមាគមទីភ្នាក់ងារជ្រើសរើសពលករឯកជន ស្តីពីប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត។ លោករដ្ឋលេខាធិការលើកឡើងទៀតថា IOM បានបន្តសហការជាមួយក្រសួងក្នុងការសម្របសម្រួល និងផ្តល់អាហារូបករណ៍ដល់ពលករទេសន្តរប្រវេសក៍ដែលវិលត្រឡប់ ចូលរៀនជំនាញអគ្គិសនី និងបរិក្ខារត្រជាក់ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅខេត្តសៀមរាប និងពង្រីកទៅបណ្តាខេត្តផ្សេងៗទៀត ស្របតាមប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវធ្វើការបណ្តុះបណ្តាលវគ្គជំនាញខ្លីៗបន្ថែមទៀតដល់យុវជនកម្ពុជា ឱ្យធ្វើការក្នុងស្រុកបាន ១,៥ លាននាក់។

លោកស្រី Sarah Lou Arriola ក៏បានថ្លែងអំណរគុណអំពីការផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ និងបានលើកឡើងអំពីសារៈសំខាន់នៃការអភិវឌ្ឍជំនាញ និងការលើកកម្ពស់ការជ្រើសរើសពលករប្រកបដោយសុចរិតភាព និងយុត្តិធម៌ ដែលមានក្នុងប្រព័ន្ធ IRIS។ លោកស្រីបានវាយតម្លៃខ្ពស់ចំពោះភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងអង្គការ IOM និងក្រសួងការងារ៕

## ប៉ូលិសហ្វីលីពីន ដោះលែងពួកជនឆបោកតាមប្រព័ន្ធអ៊ិនធ័រណែត ជាង ១ ០០០នាក់

https://www.rfi.fr/km//20230506-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 06/05/2023 - 17:07

នៅប្រទេសហ្វីលីពីន ថ្ងៃសៅរ៍ នគរបាលបានសម្រេចដោះលែងពួកជនឆបោកតាមប្រព័ន្ធអ៊ិនធ័រណែត ជាង ១ ០០០ នាក់។ ពួកគេទាំងនេះ ក៏ជាជនរងគ្រោះដែរ ដែលត្រូវឆបោកកេងប្រវញ្ចពីពួកក្រុមមេគំនិត និងមេខ្សែបណ្តាញជួញដូរបោកប្រាស់ ប្រមាណជាង ១០នាក់ ភាគច្រើនជាជនជាតិ ចិន ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ អ្នកច្បាប់ហ្វីលីពីន បានអំពាវនាវឲ្យអាជ្ញាធរពង្រឹងវិធានការឲ្យម៉ឺងម៉ាត់ទប់ស្កាត់អំពើជួញដូរមនុស្ស និងការបោកបញ្ឆោតតាមប្រព័ន្ធបច្ចេកវិទ្យា។

ជនឆបោកតាមប្រព័ន្ធអ៊ិនធ័រនែត ចំនួន ១០៩០ នាក់ ត្រូវនគរបាលហ្វីលីពីន ចាប់ឃាត់ខ្លួននៅក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសជួញដូរមនុស្សដ៏ធំ ពីថ្ងៃព្រហស្បតិ៍ នៅ Mabalacat ចម្ងាយប្រមាណ ៩០ គីឡូម៉ែត្រ ប៉ែកខាងជើងពីរដ្ឋធានីម៉ានីល និងត្រូវដោះលែងវិញ នៅថ្ងៃសៅរ៍។ នេះបើតាមអ្នកនាំពាក្យនគរបាលជាតិហ្វីលីពីន Michelle Sabino និងដែលឲ្យដឹងទៀតថា ភាគច្រើននៃពួកគេទាំងនោះ គឺជាជនជាតិ ចិន វៀតណាម និងឥណ្ឌូនេស៊ី។

បើតាមប៉ូលិស ពួកជនឆបោកតាមប្រព័ន្ធអ៊ិនធ័រនែតទាំងនោះ ក៏ជាជនរងគ្រោះដែរ ព្រោះតែត្រូវពួកមេគំនិតបោកបញ្ឆោតឲ្យចូលទៅប្រទេសហ្វីលីពីន ហើយក៏ត្រូវចាប់បង្ខាំង និងត្រូវដកហូតលិខិតឆ្លងដែនទុក ហើយត្រូវគេបង្ខំឲ្យធ្វើការជាទម្ងន់ រហូតដល់១៨ម៉ោងក្នុង១ថ្ងៃ ដើម្បីបោកបញ្ឆោតអ្នកដទៃទៀត បន្តៗគ្នា។ មធ្យោបាយសម្រាប់ឆបោកបន្តៗគ្នានេះ គឺទាក់ទងតាមអ៊ិនធ័រនែត និងដោយការសន្យាផ្តល់ការងារធ្វើ មានប្រាក់ខែច្រើន ឬ សន្យារៀបការ បង្កើតគ្រួសារ ទិញផ្ទះសម្បែងកសាងអនាគតរួមគ្នា ឬក៏ សន្យាបង្កើតមុខរបររកស៊ីរួមគ្នា នៅពេលមកដល់ប្រទេស ហ្វីលីពីន ជាដើម។ ហើយដើម្បីសម្រេចដំណើរការនីមួយៗដូចការសន្យា ពួកគេទាំងនោះបានលួងលោមល្បួងចិត្ត ឲ្យផ្ញើផ្ទេរលុយឲ្យពួកគេ។ ជនរងគ្រោះ មួយចំនួន ឆោត ត្រចៀកស លង់ជឿ មិនត្រឹមតែផ្ញើលុយកាក់ទេ តែថែមទាំងរហូតដល់ធ្វើដំណើរទៅ ហ្វីលីពីន ហើយត្រូវជាប់ទន្ទាក់កាន់តែធ្ងន់ គឺ ត្រូវពួកនេះ បោកប្រើសព្វគ្រប់ ធ្វើបាបរាងកាយ និងឃុំខ្លួនដូចអ្នកទោស ក្នុងបន្ទប់តូចៗ។

បើតាមប៉ូលិសហ្វីពីនដដែល អ្នកចាញ់បោកគេទាំងនោះ ក៏មានជនជាតិហ្វីលីពីនខ្លួនឯង ហើយនិងមានជនជាតិ ម៉ាឡេស៊ី ថៃ តៃវ៉ាន់ ហុងកុង ភូមា និង នេប៉ាល់ ជាដើម។ ក្រុមមនុស្សគោលដៅដែលពួកគេចង់ឆបោកដ៏សំខាន់ដែរ គឺអ្នករស់នៅ កាណាដា អាមេរិក និង អឺរ៉ុប ។ ស្នងការនគរបាលអន្តោប្រវេសន៍ហ្វីលីពីន ក៏បានពញ្ញាក់ស្មារតីចំពោះព្រឹត្តិការណ៍អន្តរជាតិផ្សេងៗ នៅក្រៅប្រទេស ដែល ក្រុមជនខិលខូចឆបោក អាចឆ្លៀតឱកាសឆបោកបាន ដ្បិតថា ករណីជាក់ស្តែងមាន បេក្ខបុរស បេក្ខនារី ត្រូវគេអញ្ជើញទៅប្រកួតប្រជែងសម្រស់នៅឆាកអន្តរជាតិ ក៏ប៉ុន្តែបែរជាទីបំផុត ត្រូវប៉ូលិសរកឃើញនៅក្នុងសំណាញ់របស់ពួកជនល្មើសឆបោកទៅវិញ។ ក្នុងស្មារតីប្រុងប្រយ័ត្ននេះដែរ នគបាលហ្វីលីពីន បានផ្តាំឲ្យ ក្រុមកីឡាករហ្វីលីពីន ដែលទៅចូលរួមព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ (ស៊ីហ្គេម) នៅកម្ពុជា ឲ្យចេះប្រយ័ត្នប្រយែងខ្លួន៕

# ថ្ងៃទី១១ ខែ ឧសភា ឆ្នាំ២០២៣

## កម្ពុជា-សិង្ហបុរី រួមគ្នាទប់ស្កាត់បទល្មើសធំៗ ពិសេសបញ្ហាគ្រឿងញៀន ជួញដូរមនុស្ស និង បទល្មើសបច្ចេកវិទ្យា

https://dap-news.com/national/2023/05/09/330706/ ByKD102Posted on May 9, 2023

ភ្នំពេញ៖ សម្តេច ស ខេង នាយករដ្ឋមន្ត្រីស្តីទី និងលោក ជាវ ឈី ហាន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីសម្របសម្រួលសន្តិសុខសិង្ហបុរី បានរួមគ្នាទប់ស្កាត់បទល្មើសធំៗមួយចំនួន ពិសេសបញ្ហាគ្រឿងញៀន អំពើជួញដូរមនុស្ស និងបទល្មើសបច្ចេកវិទ្យា ជាដើម។

ក្នុងជំនួបពិភាក្សាការងាររវាងសម្តេច ស ខេង និងលោក ជាវ ឈី ហាន នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ នេះ ភាគីទាំងពីរ បានជជែកពិភាក្សាផ្លាស់ប្តូរយោបល់ទៅវិញទៅមក ពាក់ព័ន្ធទៅនឹងការពង្រឹងពង្រីក កិច្ចសហប្រតិបត្តិការក្នុងការ ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលទាក់ទងបទល្មើសប្រពៃណី និងបទល្មើសមិនប្រពៃណី និងការខិតខំស្វែងរកនូវឱកាស ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការនេះ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ក្របខ័ណ្ឌតំបន់

តាមរយៈអាស៊ាន និងក្របខ័ណ្ឌអន្តរជាតិសំដៅ ទប់ស្កាត់បទល្មើសធំៗមួយចំនួន ពិសេសបញ្ហាគ្រឿងញៀន អំពើជួញដូរមនុស្ស និងបទល្មើសបច្ចេកវិទ្យាជាដើម។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខ នាយករដ្ឋមន្ត្រីស្តីទី បានថ្លែងអំណរគុណរដ្ឋាភិបាលសិង្ហបុរី កន្លងមកបានរៀបចំបើក វគ្គបណ្តុះបណ្តាលសិក្ខាសាលា ឬកិច្ចប្រជុំផ្សេងៗដោយបានផ្តល់ឱកាស ឱ្យមន្ត្រីអនុវត្តច្បាប់របស់កម្ពុជាបានចូលរួម។ សម្តេចបន្តថា ភាគីទាំងពីរកំពុងតែជជែកពិភាក្សា ដើម្បីរៀបចំឯកសារសហប្រតិបត្តិការជាផ្លូវការជាមួយគ្នា។

សម្តេច ស ខេង បានបង្ហាញក្តីសង្ឃឹមជឿជាក់ដែរថា ការរៀបចំឲ្យមានឯកសារសហប្រតិបត្តិការនេះ គឺជាកិច្ចការមួយដែលសមស្របទៅនឹង បរិបទបច្ចុប្បន្នដែលប្រទេសទាំងពីរ ក៏ដូចជាប្រជាជននៃប្រទេសទាំងពីរ មានការធ្វើដំណើរទៅវិញទៅមកកាន់តែច្រើនឡើង មួយវិញទៀតនោះក៏សមស្របទៅនឹងកាលៈទេសៈ នៃស្ថានភាពប្រែប្រួលនៃបទល្មើសឆ្លងដែន ពិសេសបទល្មើសមិនប្រពៃណី ៕

## HRW ស្នើឱ្យប៉ូលីសអន្តោប្រវេសន៍ថៃ បើកការស៊ើបអង្កេតករណីពលករខ្មែរត្រូវអាជ្ញាធរថៃដាក់ច្រវ៉ាក់ដៃ

https://www.rfi.fr/km//20230509-hrw?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 09/05/2023 - 08:06

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិអះអាងថា ខ្លួនមិនអាចទទួលយកបានឡើយ នូវសកម្មភាពដែលអាជ្ញាធរថៃប្រើច្រវ៉ាក់ដាក់ខ្នោះដៃមកលើពលករចំណាកស្រុកជាជនជាតិខ្មែរ ខណៈទង្វើមិនសមរម្យបែបនេះ Human Right Watch ចាត់ទុកថា ជារូបភាពបង្ហាញពីភាពខ្វះខាតនៃការគោរពសិទ្ធិមនុស្សរបស់អាជ្ញាធរក្នុងមូលដ្ឋានរបស់ថៃ និងទាមទារឱ្យបើកការស៊ើបអង្កេត។ ការចេញមករិះគន់អាជ្ញាធរថៃនាពេលនេះ ធ្វើឡើងបន្ទាប់ពីមានរូបថតពលករខ្មែរក្មេងចាស់អង្គុយក្នុងឡានដៃជាប់ច្រវ៉ាក់ ត្រូវបានបង្ហោះលើបណ្តាញសង្គម និងក្រោយពេលដែលអង្គការស្រង់តាល់ចេញផ្សាយរបាយការណ៍មួយដោយរកឃើញថា យ៉ាងហោចណាស់ពលរដ្ឋខ្មែរជិត១ពាន់នាក់ត្រូវអាជ្ញាធរថៃចាប់ខ្លួន និងធ្វើទារុណកម្ម។

លោក ហ្វីល រ៉ូបឺតសុន (Phil Robertson) នាយករងប្រចាំតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Right Watch បានបង្ហោះលើបណ្តាញសង្គមTwitterថា លោកមិនអាចទទួលបានឡើយចំពោះទង្វើដែលអាជ្ញាធរក្នុងមូលដ្ឋានរបស់ប្រទេសថៃចាប់ពលករខ្មែរដោយដាក់ច្រវ៉ាក់ដៃ ពីព្រោះទង្វើនេះបង្ហាញពីភាពមិនសមរម្យ និងការមិនគោរពសិទ្ធិមនុស្ស។ លោក រ៉ូបឺតសុនចាត់ទុកថា សមត្ថកិច្ចថៃដូចជាប្រមាថមើលងាយពលករខ្មែរ ហើយលោកជំរុញឱ្យសមត្ថកិច្ចផ្នែកអន្តោប្រវេសន៍ថៃបើកការស៊ើបអង្កេតករណីនេះឱ្យបានម៉ត់ចត់ ដើម្បីធានាថា ករណីដាក់ច្រវ៉ាក់ដៃ ការមើលងាយមកលើពលករមិនមានទៀតនាថ្ងៃខាងមុខ។

រូបភាពដែលបង្ហោះនៅលើបណ្តាញសង្គមយ៉ាងព្រោងព្រាតនាប៉ុន្មានថ្ងៃនេះ គឺបង្ហាញឱ្យឃើញថា ពលករខ្មែរមានទាំងចាស់ មានទាំងក្មេង ត្រូវបានអាជ្ញាធរថៃដាក់ឱ្យអង្គុយក្នុងឡានទ្រុងជុំគ្នា ដោយមានច្រវ៉ាក់ជាប់ដៃផង។ ពលករខ្មែរទាំងនេះត្រូវបានគេអះអាងថា មានចំនួន១៤នាក់ ក្នុងនោះមានស្រីចំនួន៥នាក់ ហើយត្រូវបានអាជ្ញាធរថៃចាប់ឃាត់ខ្លួននៅតំបន់ណាត្រាត ខេត្តសាមុតប្រាកាន ក្រោយឆ្លងដែនខុសច្បាប់។ រូបភាពពលករខ្មែរអង្គុយក្នុងឡាននេះ គឺប៉ូលីសថៃបានដឹកបញ្ជូនទៅមន្ទីរឃុំឃាំងបាងកែវ ស្ថិតក្នុងទីក្រុងបាងកក។

ជុំវិញករណីនេះ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក អាន សុឃឿន បានប្រាប់វិទ្យុបារាំងអន្តរជាតិ RFIថា អាជ្ញាធរថៃនឹងត្រៀមបញ្ជូនពលករខ្មែរខាងលើនេះត្រឡប់មកប្រទេសវិញ នៅពេលដែលការសួរនាំ និងបំពេញសំណុំឯកសារចប់សព្វគ្រប់។ អ្នកនាំពាក្យរូបភាពអះអាងថា ភាគីកម្ពុជាក៏ស្នើឱ្យភាគីថៃពន្លឿននីតិវិធី និង

ស្នើមិនឱ្យមានការដាក់ខ្នោះច្រវ៉ាក់ដៃនេះបន្តទៀតចំពោះពលករខ្មែរណាដែលលួចឆ្លងដែនខុសច្បាប់ ពីព្រោះនេះមិនមែនជាបទឧក្រិដ្ឋ។

ចំណែក លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃអង្គការសង់ត្រាល់ចាត់ទុកថា ការអនុវត្តច្បាប់ដ៏តឹងរ៉ឹងរបស់អាជ្ញាធរថៃមកលើពលករខ្មែរដោយធ្វើការដាក់ច្រវ៉ាក់ដៃបែបនេះ ជាទង្វើដ៏ឃោរឃៅ និងរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលមិនគួរឱ្យបន្តកើតមានទៀតឡើយ។ បន្ថែមពីនេះ លោក យុន ថារ៉ូ យល់ថា ករណីនេះ អាចជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ត្បិតប្រទេសថៃកំពុងខិតជិតដល់ថ្ងៃបោះឆ្នោតថ្នាក់ជាតិរបស់ខ្លួន។ ម្ល៉ោះហើយ ករណីនេះអាចស្ថិតក្នុងរបៀបវារៈដែលអ្នកនយោបាយ ឬគណបក្សនយោបាយក្នុងប្រទេសថៃលើកយកមកឃោសនាពិសេសពាក់ព័ន្ធនឹងរឿងពលករចំណាកស្រុក និងការឆ្លងដែនខុសច្បាប់។

កាលពីថ្ងៃទី ០៣ ខែឧសភា អង្គការសង់ត្រាល់ បានចេញសេចក្តីថ្លែងការណ៍មួយដោយរកឃើញថា ក្នុងរយៈពេល៤ខែ ឆ្នាំ២០២៣ ពលករខ្មែរយ៉ាងហោចណាស់ជាង១ពាន់នាក់ត្រូវបានអាជ្ញាធរថៃចាប់ឃាត់ខ្លួន នៅពេលដែលពួកគេឆ្លងដែនទៅធ្វើការនៅប្រទេសថៃ។ ហើយពលករជាង៨០០នាក់ត្រូវបានចាប់ខ្លួនអំឡុងពេលពួកគេធ្វើដំណើរត្រឡប់ទៅបំពេញការងារវិញក្រោយបុណ្យចូលឆ្នាំ។ បើតាមសេចក្តីថ្លែងការណ៍បានឱ្យដឹងថា ពលករខ្មែរភាគច្រើនទទួលរងការធ្វើទុក្ខទោស ទារុញកម្ម ការចាប់ដាក់ខ្នោះ និងការចាប់ឃុំខ្លួនបណ្តោះអាសន្នពីសំណាក់អាជ្ញាធរថៃ ដោយហេតុថា ពួកគេខ្វះឯកសារ ឬផុតសុពលភាព និងគ្មានលទ្ធភាពបង់ប្រាក់តាមច្រកព្រំដែន៕

## ជនរងគ្រោះនៃការជួញដូរមនុស្ស
## ជនជាតិឥណ្ឌូនេស៊ី ២០ នាក់ ត្រូវបានគេជួយសង្គ្រោះនៅមីយ៉ាន់ម៉ា

https://www.postkhmer.com/international/2023-05-08-1714-249812.html ហួន ឌីណា | Publication date 08 May 2023 | 17:14 ICT

ក្រុមមន្ត្រីឥណ្ឌូនេស៊ី បានឱ្យដឹងកាលពីថ្ងៃអាទិត្យថា ខ្លួនបានជួយសង្គ្រោះជនជាតិឥណ្ឌូនេស៊ីចំនួន ២០ នាក់ ដែលត្រូវគេជួញដូរទៅប្រទេសមីយ៉ាន់ម៉ាដើម្បីឱ្យធ្វើការក្នុងប្រតិបត្តិការឆបោកតាមអ៊ីនធឺណិត នៅពេលដែលករណីជួញដូរមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍កើនឡើង។

ក្រសួងការបរទេសឥណ្ឌូនេស៊ី បាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា ស្ថានទូតឥណ្ឌូនេស៊ីប្រចាំទីក្រុងយ៉ាំងហ្គោន ក្រោមជំនួយនៃបណ្តាញក្នុងស្រុកមីយ៉ាន់ម៉ា បានគ្រប់គ្រងការជួយសង្គ្រោះជនរងគ្រោះទាំងអស់នោះចេញពីក្រុង Myawaddy នៃរដ្ឋ Kayin State ដែលនៅជាប់ព្រំដែនថៃ ហើយនាំពួកគេទៅកាន់ប្រទេសថៃកាលពីថ្ងៃសៅរ៍។ មន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ីម្នាក់គឺលោក Judha Nugraha បានឱ្យដឹងថា ក្រុមអ្នករើសកម្មករក្លែងក្លាយបានសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់ដល់ជនជាតិឥណ្ឌូនេស៊ី ប៉ុន្តែជំនួសមកវិញ ជនរងគ្រោះទាំងនោះ ត្រូវបានគេដឹកយកទៅធ្វើការនៅទីក្រុង Myawaddy ដើម្បីឱ្យធ្វើការបោកប្រាស់តាមអ៊ីនធឺណិត ឬកម្មវិធីគ្រីបតូ ឬកម្មវិធីទូរស័ព្ទជាដើម។ ការណ៍នេះ បានបង្កជាកំហឹងក្នុងប្រទេសឥណ្ឌូនេស៊ី ក្រោយមានការចែកចាយនូវវីដេអូមួយកាលពីខែមុន ដែលបង្ហាញពីជនរងគ្រោះឥណ្ឌូណេស៊ីម្នាក់អង្គុយក្នុងបន្ទប់ទាំងទឹកមុខក្រៀមក្រំ ហើយអង្វរសុំឱ្យរដ្ឋាភិបាលឥណ្ឌូនេស៊ីជួយសង្គ្រោះខ្លួន ដែលរងការធ្វើបាបលើរូបរាងកាយស្ទើររាល់ថ្ងៃ។

ជនរងគ្រោះនោះ និយាយក្នុងខ្សែវីដេអូថា៖«សូមជួយពួកយើងត្រឡប់ទៅឥណ្ឌូនេស៊ីវិញផង ពីព្រោះជីវិតរបស់យើងនៅទីនេះពិតជាវេទនា និងរងការគំរាមកំហែងខ្លាំងណាស់» តាមរយៈការធ្វើទារុណកម្មរូបកាយដូចជាឆក់ខ្សែភ្លើង និងទណ្ឌកម្មលើរាយកាយផ្សេងៗទៀត នៅពេលធ្វើការងារមិនបានសម្រេចគោលដៅដាក់លាក់។ ជនរង

គ្រោះបន្តថា គ្រប់គ្នាត្រូវបានគេផ្ទេរពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀតក្នុងរយៈពេល ៨ ខែកន្លងមកនេះ មុនគេផ្ទេរទៅក្រុង Myawaddy ដែលនៅជាប់ព្រំដែនថៃ។

អាជ្ញាធរ បានអះអាងថា ជនរងគ្រោះទំនងជាត្រូវបានគេជួញដូរទៅប្រទេសមីយ៉ាន់ម៉ាតាមមធ្យោបាយខុសច្បាប់ដោយសារតែគ្មានកំណត់ត្រាចូលមីយ៉ាន់ម៉ាណាមួយ មាននៅក្នុងប្រព័ន្ធអន្តោប្រវេសន៍របស់មីយ៉ាន់ម៉ា។ យ៉ាងណាក៏ដោយ គេមិនច្បាស់ទេថាតើការដោះលែងជនរងគ្រោះទាំង ២០នាក់ ត្រូវបានធានាដោយរបៀបណា ប៉ុន្តែអ្នកនាំពាក្យប៉ូលិសជាតិឥណ្ឌូនេស៊ី លោកSandi Nugroho បាននិយាយថា ការចរចាត្រូវបានធ្វើឡើងជាមួយក្រុមហ៊ុនដែលជួលជនរងគ្រោះទាំងនោះ។ បន្ថែមពីលើនេះ កាលពីថ្ងៃសុក្រ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី លោកស្រី Retno Marsudi បានប្រាប់សន្និសីទសារព័ត៌មានថា រដ្ឋាភិបាលកំពុងធ្វើការដើម្បីជួយដល់ជនរងគ្រោះឥណ្ឌូនេស៊ី ដែលជាជនរងគ្រោះនៃការឆបោកតាមអ៊ីនធឺណិតនៅមីយ៉ាន់ម៉ា កម្ពុជា ថៃ វៀតណាម ឡាវ និងហ្វីលីពីន៕

## ស្ត្រីមីយ៉ាន់ម៉ាទាមទារសិទ្ធិស្មើភាពសម្រាប់ពលករបរទេសនៅថៃ

https://kbn.news/archives/293396 May 9, 2023

ប្រទេសថៃ ៖ ស្ត្រីមីយ៉ាន់ម៉ាម្នាក់បានបង្ហោះវីដេអូឃ្លីបមួយ ហើយធ្វើឱ្យមានការជជែកតវ៉ាគ្នាក្នុងបណ្តាញសង្គមប្រទេសថៃ រហូតមានពលរដ្ឋថៃបណ្តេញឱ្យស្ត្រីរូបនេះចេញពីប្រទេសថៃផងដែរ ប៉ុន្តែមិនយូរប៉ុន្មាន ស្ត្រីរូបនេះបានបង្ហោះវីដេអូមួយទៀតសូមទោស ។ អ្នកជំនាញផ្នែកពលករបរទេសប្រចាំប្រទេសថៃបង្ហាញថា ពលករមីយ៉ាន់ម៉ាបាននាំគ្នាតវ៉ាក្នុងថ្ងៃទិវាពលកម្មកន្លងមក រហូតមានរឿងកើតឡើង ព្រោះពួកគេអំពាវនាវឱ្យមានប្រព័ន្ធគ្រប់គ្រងការងារត្រឹមត្រូវសម្រាប់ពលករបរទេស ។

កាលពីថ្ងៃទី១ ខែឧសភា ពលករបរទេសបានប្រមូលផ្តុំគ្នាតវ៉ានៅបរិវេណផ្លូវបំបែករ៉ាជព្រះសុង ។ ក្រោយមក មានស្ត្រីពលករមីយ៉ាន់ម៉ាម្នាក់ បានបង្ហោះវីដេអូឃ្លីបទាមទារសិទ្ធិពលករបរទេស ដែលធ្វើការនៅប្រទេសថៃដើម្បីឱ្យពួកគេមានសិទ្ធិស្មើគ្នា ។ ប៉ុន្តែនៅចុងបញ្ចប់នៃវីដេអូឃ្លីប ស្ត្រីរូបនេះបាននិយាយស្តីមិនសមរម្យ រហូតធ្វើឱ្យពលរដ្ឋថៃខ្លះដែលមើលវីដេអូរបស់នាងក្នុងតិកតុកចេញមកប្រកែក ។ បន្ទាប់មក ស្ត្រីរូបនេះបានចេញវីដេអូសូមទោស ហើយមានអ្នកចូលមកបញ្ចេញយោបល់ជាច្រើនម៉ឺននាក់ ។

លោក Siwawong Suktawee មន្ត្រីតំណាងមកពី Migrant Working Group ដែលធ្វើការផ្នែកពលករបរទេស បាននិយាយមកកាន់សារព័ត៌មានថៃរ៉ាត់ថា ការចេញមកតវ៉ារបស់ពលករមីយ៉ាន់ម៉ាជាច្រើននាក់ក្នុងថ្ងៃទិវាពលកម្ម គឺពាក់ព័ន្ធនឹងបញ្ហាការធ្វើលិខិតឆ្លងដែនដែលកំពុងជាប់គាំងនៅឡើយ ព្រោះនៅព្រំដែនខ្លះ ពលករមីយ៉ាន់ម៉ាមិនអាចឆ្លងដែនទៅធ្វើលិខិតឆ្លងដែនបានទេ ។ លើសពីនេះ មានបញ្ហានយោបាយក្នុងប្រទេសធ្វើឱ្យពលករមួយចំនួនមិនហ៊ានត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ព្រោះខ្លាចមិនអាចត្រឡប់មកធ្វើការនៅថៃបន្តទៀត ។ កន្លងមកប្រទេសថៃបានលើកលែងដោយសារមានជំងឺកូវីដរាតត្បាត ប៉ុន្តែប្រទេសថៃនឹងឈប់លើកលែងចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ។

បញ្ហាប្រឈមពេលនេះ គឺស្ថានទូតមីយ៉ាន់ម៉ានៅថៃបានកំណត់ចំនួនមនុស្សមកបន្តសុពលភាពលិខិតឆ្លងដែន ដោយសារបារម្ភពីរដ្ឋាភិបាលយោធាមីយ៉ាន់ម៉ា ខណៈថៃនឹងបោះឆ្នោតនៅថ្ងៃទី១៤ ខែឧសភា ។ ដូច្នេះ វាពិបាកដោះស្រាយបញ្ហារបស់ពលករទាំងនេះណាស់ ទើបធ្វើឱ្យពលករមីយ៉ាន់ម៉ាជាង១សែននាក់រស់នៅថៃ ត្រូវក្លាយជាពលករខុសច្បាប់ ។ បើគ្មានដំណោះស្រាយទេ វានឹងក្លាយជាបញ្ហាសំខាន់ចំពោះពលករមីយ៉ាន់ម៉ា ហើយពួកគេចេញមកតវ៉ាកាន់តែច្រើន ។ កន្លងមក ពលករមីយ៉ាន់ម៉ាបានធ្វើឯកសារធ្វើការនៅថៃ២ឆ្នាំម្តង ហើយពួកគេបានចំណាយប្រាក់ថ្លៃឯកសារមិនដល់១ម៉ឺនបាតទេ ប៉ុន្តែក្រោយមក ឈ្មួញកណ្តាលបានដំឡើងថ្លៃឈ្នួលធ្វើឯកសារ

គឺធ្វើឯកសារម្តងអស់២ម៉ឺនបាត ។ ហេតុនេះ ពលករមីយ៉ាន់ម៉ាជាច្រើននាក់មានអារម្មណ៍ថា ធ្វើការស្ទើរស្លាប់នៅថៃ ហើយត្រូវយកប្រាក់យ៉ាងច្រើនមកធ្វើឯកសារតែម្យ៉ាង និងគ្មានប្រាក់សល់ជាប់ខ្លួន ពួកគេក៏រងសម្ពាធកាន់តែខ្លាំង ។ លើសពីនេះ បើឯកសារធ្វើការនៅថៃមិនត្រឹមត្រូវ ពួកគេត្រូវប្រឈមនឹងអាជ្ញាធរថៃចាប់ខ្លួន និងត្រូវបង់ប្រាក់ពិន័យទៀត ។

ក្រោយពីជំងឺកូវីដធូរស្រាល ពលករមីយ៉ាន់ម៉ាបានចូលមកប្រទេសថៃកាន់តែច្រើន អ្នកខ្លះមកថៃដោយសារបញ្ហានយោបាយក្នុងប្រទេសរបស់ខ្លួន ។ ដូច្នេះ មានអ្នកចូលមកត្រឹមត្រូវតាមច្បាប់ និងលួចចូលមកតាមច្រកធម្មជាតិ ។ ភ្នាក់ងាររដ្ឋាភិបាលថៃ គួរកុំយកប្រាក់ខ្ពស់ពេកសម្រាប់ការចុះឈ្មោះពលករបរទេស ព្រោះពួកគេមានចំណែករួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចថៃ ហើយពលករខ្លះក៏បានធ្វើជាឈ្មួញកណ្តាលជួយនាំផលិតផលថៃទៅលក់នៅប្រទេសរបស់ខ្លួនដែរ ។ ដូច្នេះ ប្រទេសថៃមិនអាចរីកចម្រើនតែឯងបានទេ ប៉ុន្តែត្រូវមានប្រទេសជិតខាងជួយ ៕

## HRWចាត់ទុកសមត្ថកិច្ចថៃមើលងាយពលករខ្មែរដូចសត្វធាតុករណីយកច្រវាក់ចង

https://www.rfa.org/khmer/news/human-rights/hrw-considers-thai-authorities-to-despise-cambodian-workers-as-animals-05072023072342.html ដោយ ទីន ហ្សាការីយ៉ា2023.05.07

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ចាត់ទុកសកម្មភាពសមត្ថកិច្ចថៃប្រមាថមើលងាយពលករខ្មែរដូចសត្វធាតុ ករណីចាប់ដាក់ច្រវាក់ជាក្រុមៗពេលថ្មីៗនេះ។ ទន្ទឹមនឹងនេះអង្គការសង្គមស៊ីវិល និងអ្នកច្បាប់ក៏ជំរុញឱ្យរដ្ឋាភិបាលធ្វើកំណត់ទូតទៅប្រទេសថៃលើករណីនេះដែរ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Right Watch បានថ្កោលទោស សមត្ថកិច្ចថៃថា ប្រមាថមើលងាយពលករខ្មែរ ដូចសត្វធាតុករណីចាប់ចងដោយច្រវាក់ ហើយទាមទារឱ្យមានការស៊ើបអង្កេតឱ្យបានច្បាស់លាស់។

នាយករងប្រចាំតំបន់អាស៊ី នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ លោក ហ្វីល រ៉ូប៊ឺតសុន (Phil Robertson) ថ្លែងប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី៥ ខែឧសភា ថា ទង្វើសមត្ថកិច្ចថៃជាការប្រមាថមើលងាយពលករខ្មែរដូចសត្វធាតុ។ លោក ហ្វីល រ៉ូប៊ឺតសុន៖ «វាគឺជារឿងហួសហេតុដែលមិនអាចទទួលយកបានទេ ករណីដែលសមត្ថកិច្ចថៃ ប្រើច្រវាក់ដែកចងពលករខ្មែរដែលជាប់ឃុំទាំងនេះ។ នេះជាការប្រមាថមើលងាយលើកិត្តិយស និងបង្ហាញថា សមត្ថកិច្ចថៃមើលងាយពលករដូចសត្វធាតុ»។ លោកទាមទារមន្ត្រីផ្នែកអន្តោប្រវេសន៍របស់ថៃ បើកការស៊ើបអង្កេតរកការពិតលើករណីនេះ ដើម្បីធានាថា មិនមានការប្រើច្រវាក់ចងពលករដោយប្រមាថ មើលងាយរបៀបនេះបន្តទៀតនៅថ្ងៃអនាគត។ ប្រតិកម្មរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិនេះ បន្ទាប់ពីសមត្ថកិច្ចថៃបង្ក្រាបពលករចំណាកស្រុក នៅក្នុងទីក្រុងបាងកក នៅពាក់កណ្តាលខែមេសា ហើយបានចាប់ពលករខ្មែរចងច្រវាក់ជាក្រុមៗបញ្ជូនចេញពីកន្លែងធ្វើការងាររបស់ពួកគេ ទៅកន្លែងឃុំឃាំង។

មន្ត្រីផ្នែកសិទ្ធិមនុស្សបារម្ភថា ក្រៅពីរូបថតប៉ុន្មានសន្លឹកបែកធ្លាយករណីសមត្ថកិច្ចថៃចងដោយច្រវាក់នេះ អាចមានករណីធ្វើទារុណកម្ម និងប្រមាថមើលងាយផ្សេងៗទៀតដែលត្រូវមានការស៊ើបអង្កេត។ នៅក្នុងអំឡុងខែមេសា ក្រោយពេលចូលឆ្នាំខ្មែរ ហើយក៏មានវីដេឃ្លីបថតដោយពលករខ្មែរជាប់ឃុំនៅក្នុងរនាំងដែក ហើយត្អូញត្អែរពីការខ្វះទឹក និងអាហារបរិភោគ។ សំឡេងពលករជាប់ឃុំ៖ «បងប្អូនអើយនេះជាប់គុកអត់ប៉ាស្ព័រ នៅក្នុងគុកច្រើនគ្នាណាស់។ នេះគ្រាន់តែនៅខាងនេះ នៅមាននៅខាងក្រៅនៅបន្ទប់ខាងនេះខាងនោះទៀត នៅច្រើនណាស់។ ឥឡូវគេថាជាប់ទោសក្នុងគុក ៣ខែខ្លះ៨ខែ។ អាហ្នឹងខ្ញុំឮគេថា ដែរនៅក្នុងគុកទាំងអស់គ្នានេះ។ ហើយខ្ញុំអត់ទឹកហូបទឹកអីទេ ហើយជាប់ទោសអី ក៏យូរម្លេះខ្ញុំជំពាក់អង្គការគេច្រើនណាស់បងប្អូនអើយ។ សុំស៊ែខ្ញុំបង្ហោះនេះ សូមបងប្អូនជួយស៊ែដល់សម្តេច ហ៊ុន សែន អីហ្នឹង ប៊ុនរ៉ានីអីហ្នឹង»។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃលោក លឹង សុផុន មានប្រសាសន៍ថា ក្រុមការងាររបស់លោកកំពុងតែតាមដានករណីនេះ។ លោកបន្ត ថាបើត្រឹមតែរស់នៅ និងធ្វើការផុតឯកសារ ស្របច្បាប់គឺមិនគួរចាប់ចងដូចអ្នកប្រព្រឹត្តិបទឧក្រិដ្ឋធ្ងន់ធ្ងរបែបនេះទេ។ លោក លឹង សុផុន៖ «ករណីធម្មតាដែលបងប្អូន មិនមានឯកសារគ្រប់គ្រាន់មិនគួរណាដាក់ច្រវាក់ដល់ថ្នាក់ហ្នឹងទេ។ យើងមើលទៅដូចជា ទោសឧក្រិដ្ឋដូចជាទោសដែលធ្ងន់ពេកហើយ។ យើងមើលទៅមិនគួរដល់ថ្នាក់ហ្នឹងទេ បើយើងត្រឹមតែមិនមានឯកសារគ្រប់គ្រាន់ ឬមិនមានប័ណ្ណការងារត្រឹមត្រូវអីចឹងនោះ»។

សាស្ត្រាចារ្យ និងជាអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់លោក ស៊ឹម វិបុល ពន្យល់ករណីនេះ ថាតាមច្បាប់អន្តរជាតិ កម្ពុជាជាប្រទេសសាមីមានកាតព្វកិច្ចការពារពលរដ្ឋខ្លួន តាមរយៈការធ្វើកំណត់ទូតទៅប្រទេសថៃ ឬប្ដឹងទៅអង្គការអន្តរជាតិរួមទាំងអង្គការសហប្រជាជាតិផងដែរ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងសំការអត្ថាធិប្បាយពីអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ និងអ្នកនាំពាក្យក្រសួងការបរទេសលោក អាន សុខឿន បានទេ នៅថ្ងៃទី៦ ខែឧសភា។ ចំណែកស្ថានទូតខ្មែរប្រចាំប្រទេសថៃ និងស្ថានទូតថៃប្រចាំប្រទេសកម្ពុជា ក៏មិនឆ្លើយតបសាររបស់អ្នកសារព័ត៌មានអាស៊ីសេរីដែលផ្ញើទៅតាំងពីថ្ងៃទី៤ ខែឧសភា។

បើទោះជាអ្នកនាំពាក្យក្រសួងការបរទេសប្រាប់វិទ្យុបារាំង ផ្សាយជាខេមរភាសា តាំងពីថ្ងៃទី២៩ ខែមេសា ដោយទទួលស្គាល់ថា ពលករដែលសមត្ថកិច្ចថៃដាក់ច្រវាក់នោះ ជាពលករខ្មែរក៏ដោយ ក៏រហូតមកដល់ថ្ងៃទី៦ ខែឧសភា នេះ មិនទាន់ឃើញក្រសួងការបរទេស ឬស្ថានទូតខ្មែរប្រចាំប្រទេសថៃមានប្រតិកម្មណាមួយជាផ្លូវការនោះទេ។ ទាំងនៅលើហ្វេសប៊ុកផេករបស់ក្រសួងការបរទេស និងហ្វេសប៊ុកស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃមិនបាននិយាយពីពលរដ្ឋខ្មែរ ដែលត្រូវសមត្ថកិច្ចថៃចាប់ចងដោយច្រវាក់ជាក្រុមៗនោះទេ។

អ្នកផ្សព្វផ្សាយខ្លឹមសារកិច្ចព្រមព្រៀងទីក្រុងប៉ារីស លោក ស្រ៊ុន ស្រ៊ន ចាត់ទុកការដាក់ច្រវាក់ពលករខ្មែរនេះ ជាការប្រមាថធ្ងន់ធ្ងរ ដែលរដ្ឋាភិបាលថៃ និងរដ្ឋាភិបាល កម្ពុជាត្រូវមានការឆ្លើយតបចំពោះករណីនេះ។ លោក ស្រ៊ុន ស្រ៊ន៖ «វាជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទាំងរដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលថៃត្រូវទទួលខុសត្រូវ។ មិនមែនជាបន្ទុកតែរដ្ឋាភិបាលថៃទេ ជាធម្មតាទេ យើងចូលក្នុងប្រទេសគេមួយរយៈចុងក្រោយនេះ មានការរើសអើងខ្លាំងក្លារវាងខ្មែរថៃ។ យើងមើលឃើញពីនីតិវិធីនៃការសង្គ្រោះពលរដ្ឋខ្មែរ ក៏អ៊ីចឹងដែរ បើយើងមិនចូលរួមជួយទេ គឺស្មើនឹងរដ្ឋាភិបាលខ្មែរចូលរួមប្រព្រឹត្តិឧក្រិដ្ឋកម្មហ្នឹងជាមួយរដ្ឋាភិបាលថៃ ជាមួយទាហានថៃជាមួយប៉ូលិស និងអាជ្ញាធរថៃដែរ»។

សេចក្ដីថ្លែងការណ៍របស់អង្គការសង់ត្រាល់ នៅខែឧសភា ឆ្នាំ២០២៣ បានព្រួយបារម្ភចំពោះស្ថានភាពពលករខ្មែរដែលបន្តសម្រុក ទៅរកការងារធ្វើនៅប្រទេសថៃទាំងខុសច្បាប់ ខណៈបច្ចុប្បន្នពលករខ្មែរកំពុងធ្វើការនៅក្នុងប្រទេសនោះចំនួន ២លាននាក់ ហើយក្នុងនោះពាក់កណ្ដាលធ្វើការងារដោយខុសច្បាប់៕

# តើសកម្មភាពរបស់សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ ច្រកខ្សែម បន្តកៀបក្ដាមយកលុយ ពីពលករកម្ពុជាឆ្លងដែនទៅប្រទេសថៃមែនទេ !

http://nokorwatnews.com/archives/998862 09/05/2023

ខេត្តបាត់ដំបង ៖ ច្រកខ្សែមយកលុយដដែលបងប្អូនកុំជឿអោយសោះថា មិនអស់លុយ ញុមទៅទើបនិងមកវិញចេញក៏អស់លុយ ចូលក៏អស់លុយបើមានអីវ៉ាន់ច្រើនកាន់តែជំរិតយកលុយ ថែមទៀត ។ នេះជាការបង្ហោះលើ facebook ដែលមានគណនី ឈ្មោះថា, ( កូលាប លក់ អនឡាញ ) ២ថ្ងៃកន្លងទៅនេះ ។

សូមបញ្ជាក់ថា, បើទោះ មានការបង្ហោះ បែបនេះ ជារឿងពិត ឬមិនពិត អាចជាកម្មវត្ថុ ដែលថ្នាក់ដឹកនាំ ស្ថាប័នពាក់ព័ន្ធ សាមីអង្គភាព ស៊ើបអង្កេត ស្រាវជ្រាវ រកឱ្យឃើញការពិត ដើម្បីជាទុន មានអំណះអំណាងច្បាស់លាស់ ធ្វើការបញ្ជាក់ បកស្រាយ ជូនសាធារណៈជន នូវអ្វីជាការពិត។ គេនៅចាំបានថា, ច្រកខ្សែម ស្រុកកំរៀង ខេត្តបាត់ដំបង ធ្លាប់ប្រព្រឹត្តអំពើពុករលួយ មានភាពមិនប្រក្រតី ក្នុងការយកលុយពីពលករ សម្រាប់ការបំពេញបែបបទ ឆ្លងទៅធ្វើការទឹកដីប្រទេសថៃ ក្នុងម្នាក់ ត្រូវចំណាយរហូតដល់ ១៣០០បាត ដល់ ២០០០បាត និងជួបការលំបាកជាមួយនឹងសមត្ថកិច្ចច្រក បង្កើតបញ្ហាស្មុគ្រស្មាញ បង្កឲ្យមានភាពយឺតយូរ រហូតដល់មានប្រតិកម្ម ពីពលករកម្ពុជាបង្ហោះតាមរយៈបណ្ដាញទំនាក់ទំនងសង្គមហ្វេសបុក បើកកកូរកកាយ ពីអំពើពុករលួយនេះ ល្បីទូទាំងប្រទេស ។

ក្នុងនោះលោកស្រី ហ៊ុន ស៊ីណាត បានប្រតិកម្មមុនគេ ក្នុងគោលបំណងជាតិនិយម ជួយពលករកម្ពុជាដោយចិត្តបរិសុទ្ធ និងសំណូមពរឲ្យអាជ្ញាធរខេត្តបាត់ដំបង មេត្តាពិនិត្យក្នុងរឿងនេះ ។ រឿងមួយនេះត្រូវបានបញ្ចប់ក្រោយពេលចូលឆ្នាំខ្មែររយៈពេលប៉ុន្មានថ្ងៃ បន្ទាប់ពីអាជ្ញាធរខេត្តចុះដោះស្រាយសម្របសម្រួល មិនតម្រូវឲ្យយកលុយពីពលករខ្មែរឆ្លងដែនទៅប្រទេសថៃ។

ពាក់ព័ន្ធក្នុងករណីនេះ នៅយប់ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ លោក សុខ លូ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង បានប្រាប់អង្គភាពមជ្ឈមណ្ឌលព័ត៌មាន"នគរវត្ត" តាមទូរសព្ទយ៉ាងដូច្នេះថា " ដូចជាមិនមានករណីបែបនេះទេ។ ចាំមើលខ្ញុំពិនិត្យបន្ថែមទៀត..," !

សូមជម្រាបជូនថា, នគរបាលអន្តោប្រវេសន៍ច្រកខ្សែម មិនដឹងជាខ្សែខាងអស់លោកណាទេ គាត់ពិតជាល្បីខ្លាំងណាស់ ខាងបន្សល់ទុកនូវការមិនពេញចិត្តរបស់ពលរដ្ឋកម្ពុជា។ គប្បីថ្នាក់លើ មានវិធានការដ៏សមស្រប ណាមួយដើម្បីសម្របសម្រួលនីតិវិធី បង្កភាពងាយស្រួលដល់ពលករខ្មែរ ក្នុងការឆ្លងដែន ! អ្នកទទួលបានប្រាក់ ពីសេចក្ដីអត់របស់ពលករខ្មែរ , អ្នកពិតជាជោគជ័យក្នុងរង្វង់គ្រួសាររបស់អ្នក និងតំណែង ។ ប៉ុន្តែអ្នកមិនបានគិត អំពីសេចក្ដីអត់ ក្រ របស់ពលរដ្ឋរបស់យើងទេ ។ បើអ្នកបានប្រព្រឹត្តយ៉ាងដូច្នេះ អ្នកពិតណាស់ថា, បំផ្លាញសេចក្ដី ស្រឡាញ់របស់ពលរដ្ឋដែលជាពលករ មកលើថ្នាក់ដឹកនាំកម្ពុជា ដែលមានចិត្តសន្ដោសប្រណី លើកតម្កើង ផ្ដល់តម្លៃឲ្យពលករខ្មែរ ស្វែងរកការងារឱ្យពលរដ្ឋខ្មែរមានការងារធ្វើ ដើម្បីកាត់បន្ថយភាពក្រីក្រនោះ ៕

# ថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០២៣

## កម្ពុជា-សិង្ហបុរី ពិភាក្សាលើការពង្រឹង និងពង្រីកនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/national/2023-05-09-2004-249866.html ទិត្យ រានុពិចិត្រ | Publication date 09 May 2023 | 20:04 ICT

**ភ្នំពេញៈ** ថ្នាក់ដឹកនាំនិងមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃកម្ពុជា និងថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងសម្របសម្រួលសន្តិសុខ នៃសាធារណរដ្ឋសិង្ហបុរី បានជួបពិភាក្សាគ្នាទាក់ទងនឹងការពង្រឹងពង្រីកនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន ទាំងបទល្មើសប្រពៃណី និងបទល្មើសមិនប្រពៃណី។ ភាគីទាំងពីរបានលើកឡើងដូចនេះ ក្នុងជំនួបរវាងលោក ស ខេងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក ធាវ ឈី ហាន (TEO CHEE HEAN) ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីសម្របសម្រួលសន្តិសុខ នៃសាធារណរដ្ឋសិង្ហបុរី នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ ២០២៣ នាទីស្តីការក្រសួងមហាផ្ទៃ។

យោងតាមក្រសួងបានឱ្យដឹងថា ក្នុងជំនួបនោះ លោក ស ខេង ក៏បានប្រាប់លោក ធាវ ឈី ហាន ផងដែរថា ភាគីទាំង២កំពុងតែជជែកពាក់ព័ន្ធទៅនឹងការរៀបចំឱ្យមាននូវឯកសារសហប្រតិបត្តិការជាផ្លូវការជាមួយគ្នា។ ក្រសួងបានបញ្ជាក់ថា ៖ «សម្តេចក្រឡាហោម ស ខេង សង្ឃឹមជឿជាក់ថា ការរៀបចំឱ្យមាននូវឯកសារសហប្រតិបត្តិការនេះ គឺជាកិច្ចការមួយដែលសមស្របទៅនឹងបរិបទបច្ចុប្បន្នដែលប្រទេសទាំង២ មានការធ្វើដំណើរទៅវិញទៅមកកាន់តែមានច្រើនឡើងផងដែរ»។ មួយវិញទៀត លោកបានបន្តថា វាសមស្របតាមកាលៈទេសៈ ស្ថានភាពប្រែប្រួល នៃឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេស បទល្មើសមិនប្រពៃណីដែលកំពុងមានការកើតឡើង។

នាឱកាសនោះដែរ លោក ស ខេង និងលោក ធាវ ឈី ហាន ក៏បានជជែកពិភាក្សា និងផ្លាស់ប្តូរយោបល់ទៅវិញទៅមក ពាក់ព័ន្ធទៅនឹងការពង្រឹងនិងពង្រីកនូវកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន គឺមានទាំងបទល្មើសប្រពៃណី និងបទល្មើសមិនប្រពៃណី។ ប្រភពដដែលបានបញ្ជាក់ទៀតថា ៖ «ភាគីទាំង២នឹងខិតខំស្វែងរកនូវឱកាសក្នុងការពង្រីកនូវកិច្ចសហប្រតិបត្តិការនេះ ទាំងក្នុងក្របខណ្ឌទ្វេភាគី ក្របខណ្ឌតំបន់តាមរយៈអាស៊ានណាប៉ូ (ASEANAPOL) និងក្របខណ្ឌអន្តរជាតិតាមរយៈ អ៊ីនធើប៉ូ (INTERPOL) ផងដែរ សំដៅទប់ស្កាត់នូវបទល្មើសធំៗមួយចំនួន ជាពិសេស គឺបញ្ហាគ្រឿងញៀន អំពើជួញដូរមនុស្ស និងបទល្មើសបច្ចេកវិទ្យាជាដើម»។

លោក អំ សំអាត នាយកប្រតិបត្តិអង្គការលីកាដូ បានថ្លែងថា វាជារឿងមួយដែលកម្ពុជាត្រូវតែបង្កើនកិច្ចសហប្រតិបត្តិការទៅក្នុងការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដូចជាករណីជួញដូរមនុស្ស ករណីគ្រឿងញៀន និងករណីលាងលុយកខ្វក់ និងករណីផ្សេងៗទៀតផងដែរ។ លោកបានថ្លែងថា៖ «កម្ពុជាយើងមិនមែនត្រូវបង្កើនតែកិច្ចសហប្រតិបត្តិការជាមួយនឹងសិង្ហបុរីមួយទេ តែត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសនៅក្នុងអាស៊ាន ក៏ដូចជានៅក្នុងតំបន់ ក្នុងអន្តរជាតិដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែននោះ»៕

# បញ្ហាមីយ៉ាន់ម៉ា
# ឧក្រិដ្ឋកម្មឆ្លងដែន និងការបោកប្រាស់ការងារត្រូវបានពិភាក្សាយ៉ាងយកចិត្តទុកដាក់

https://www.khmertimeskh.com/501288804// Khmer Times May 11, 2023

រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី លោក Datuk Seri Zambry Abd Kadir បានមានប្រសាសន៍ថា បញ្ហាមីយ៉ាន់ម៉ា ឧក្រិដ្ឋកម្មឆ្លងដែន និង "ការបោកប្រាស់ការងារ" បានក្លាយជាការផ្តោតការយកចិត្តទុកដាក់នៃកិច្ចពិភាក្សាក្នុងចំណោមរដ្ឋមន្ត្រីការបរទេសអាស៊ាននៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤២ ឆ្នាំ២០២៣។ កិច្ចពិភាក្សាបានចាប់ផ្តើមនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស (AMM) កាលពីថ្ងៃចន្ទ បន្ទាប់មកមានកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) លើកទី២៦ និងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន (ACC) លើកទី៣៣នៅទីក្រុង West Manggarai ខេត្ត East Nusa Tenggara កាលពីថ្ងៃអង្គារ។

ការឯកភាពប្រាំចំណុច (Five Point Consensus) ដែលបន្តជាយុទ្ធសាស្ត្រចម្បងសម្រាប់ដោះស្រាយស្ថានការណ៍នៅក្នុងប្រទេសមីយ៉ាន់ម៉ា ត្រូវបានពិភាក្សាដោយរដ្ឋមន្ត្រីក្នុងអំឡុងពេលកិច្ចប្រជុំដំបូងរបស់ខ្លួន។ វាត្រូវតែត្រូវបានអនុវត្តយ៉ាងពេញលេញដោយភាគីពាក់ព័ន្ធ ហើយក៏ចាំបាច់ត្រូវគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រធានអាស៊ានក្នុងការសន្ទនាជាមួយភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសមីយ៉ាន់ម៉ា។

យោងតាមលោក Zambry ប្រជាជាតិអាស៊ាននឹងបន្តនាំមុខលើប្រតិបត្តិការមនុស្សធម៌នៅក្នុងប្រទេសមីយ៉ាន់ម៉ា តាមរយៈមជ្ឈមណ្ឌលសម្របសម្រួលជំនួយមនុស្សធម៌អាស៊ានសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (AHA Centre)។ ពួកគេក៏យល់ស្របដែរថា អំពើហិង្សាត្រូវតែបញ្ចប់នៅពេលនេះ ដើម្បីធ្វើឱ្យប្រតិបត្តិការអាចដំណើរការទៅមុខ។ លោកបានមានប្រសាសន៍ថា តួនាទីជាប្រេសិតរបស់អាស៊ានប្រចាំប្រទេសមីយ៉ាន់ម៉ា ដែលឥឡូវនេះជាវេនរបស់ឥណ្ឌូនេស៊ី ក៏ចាំបាច់ត្រូវបន្តដើម្បីបញ្ចៀសបញ្ហាដែលកើតឡើងនៅពេលដែលមានការផ្លាស់ប្តូរប្រធានអាស៊ាន។

រដ្ឋមន្ត្រីក៏បានកត់សម្គាល់ពីទំនោរនៃប្រទេសខាងក្រៅ (ដៃគូខាងក្រៅ) ដូចជា អារ៉ាប៊ីសាអូឌីត ប៉ាណាម៉ា និងអេស្ប៉ាញ ក្នុងការបង្កើតសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC)។ លោកបានបន្តថា ប្រទេសខាងក្រៅមើលឃើញថាអាស៊ានកំពុងអភិវឌ្ឍ និងអាចដំណើរការទៅមុខក្នុងលក្ខខណ្ឌល្អ ដោយលោកបានបន្ថែមថា ម៉ាឡេស៊ីបានបញ្ជាក់ជាថ្មីទៀតនូវការគាំទ្ររបស់ខ្លួនចំពោះការស្នើសុំរបស់ប្រទេសម៉ាល់ឌីវដើម្បីចូលរួមក្នុងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ (TAC)។

លោក Zambry ក៏បានផ្តល់របាយការណ៍ ស្តីពីជំហររបស់ប្រទេសម៉ាឡេស៊ីជាប្រទេសសម្របសម្រួលដែលទទួលខុសត្រូវក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-កាណាដាក្នុងខែកញ្ញា និងក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ–អាស៊ាន (ASEAN-GCC) នៅទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអូឌីតក្នុងខែតុលា។ "ម៉ាឡេស៊ីបានជូនដំណឹងអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅកម្រិតក្នុងស្រុក និងតំបន់ក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ រួមទាំងការបង្កើតកិច្ចប្រជុំអន្តរទីភ្នាក់ងារស្តីពីការសម្របសម្រួលបញ្ហានៃក្រុមផ្តល់ការងារក្លែងក្លាយ ដែលដឹកនាំដោយក្រសួងការបរទេស សហការជាមួយ ក្រសួងមហាផ្ទៃ។ ជាពិសេស លោកបានបន្ថែមថា ប្រទេសម៉ាឡេស៊ីបានផ្តោតលើឧក្រិដ្ឋកម្មឆ្លងដែនក្នុងអំឡុងសន្និសីទ APSC ជាពិសេសការជួញដូរមនុស្ស ដែលជាបញ្ហាចម្បងមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោកបានមានប្រសាសន៍ថា "យន្តការនេះក៏បានចូលរួមជាមួយភាគីផ្សេងៗ រួមទាំង INTERPOL និង ASEANAPOL ដើម្បីជួយលើកកម្ពស់ការយល់ដឹងជាសាធារណៈ" លោក Zambry បានមានប្រសាសន៍ថា ម៉ាឡេស៊ីក៏នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយកម្ពុជា និងថៃ ក្នុងគោលបំណងចែករំលែកព័ត៌មាន សម្របសម្រួល

បេសកកម្មជំនួយ កំណត់អត្តសញ្ញាណក្រុមពាក់ព័ន្ធ និងធ្វើការស៊ើបអង្កេតយ៉ាងទូលំទូលាយ ដើម្បីកាត់ទោសភាគីពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ នៅក្នុងកិច្ចប្រជុំ ACC លើកទី៣៣ ម៉ាឡេស៊ីបានស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការអនុវត្ត "អនុសាសន៍សម្រាប់ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័នរបស់អាស៊ាន" ក៏ដូចជាការកែលម្អយន្តការដឹកនាំដោយអាស៊ានផងដែរ។ ទាក់ទិននឹងទីម័រឡេស្តេ ម៉ាឡេស៊ីក៏បានរំលឹកឡើងវិញនូវការគាំទ្ររបស់ខ្លួនចំពោះការដាក់ពាក្យសុំចូលជាសមាជិកអាស៊ាន និងស្វាគមន៍កិច្ចប្រជុំកំពូលដើម្បីអនុម័តផែនទីបង្ហាញផ្លូវសម្រាប់ការចូលរួមរបស់ទីម័រឡេស្តេក្នុងអាស៊ាន។ Bernama

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១៥នាក់

https://freshnewsasia.com/index.php/en/localnews/291062-2023-05-12-01-57-00.html 2023-05-12 08:57am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន ១៥នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៦៩ករណី មានមនុស្ស ២,១៥៩នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៤៥សំណើ និងបិទសំណុំរឿង ២៩២សំណើ (រកឃើញមនុស្ស ១,៥៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣១នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៦៨ករណី៕

## សមត្ថកិច្ចខេត្តបាត់ដំបងចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://www.gdlf-kh.com/2023/05/11/-64 /Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០២៣ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក និងវរសេនីយឯក ស៊ិន ប៊ុនរស្មី ស្នងការរងទទួលដឹកនាំវ: ៨១៩។ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក អិន កុល មេមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់ឲ្យ នាយប៉ុស្តិ៍ប្រចាំការនៅជួរមុខ ត្រៀមកម្លាំងចេញល្បាត រួមមាន៖

១.វេលាម៉ោង០៧និង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាលស្វាយចេក ចំនួន០៣នាក់ អាវុធវែងខ្លី០៣ដើម បានសហការ ជាមួយ វ:៥៣៤(កងពលលេខ៥៣) ចំនួន០៧នាក់ អាវុធវែងខ្លីចំនួន០៤ដើម ដឹកនាំដោយលោកវរសេនីយ៍ទោ ទេព វណ្ណ មេបញ្ជាការរង សឹករងស្រុក ចំនួន០៣នាក់ អាវុធវែងចំនួន១ដើម ដើរល្បាតពិនិត្យព្រំដែន

ក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ប៉ុស្តិ៍ ចាប់ពី ចំណុច(ដើមពោធិ៍ច្រកទ្វារអន្តរជាតិដូង) TV ២២៨១០.៤៨០៥៣ រហូតមកដល់ចំណុចTV ២១៨១៩.៤៩៣៧៩(ចំការដូងដើមខ្ពង់)ជាលទ្ធលពុំមានអ្វីប្រែប្រួលទេ និងបានបញ្ចប់នៅវេលាម៉ោង ០៩នឹង៣០នាទីថ្ងៃដដែល។

២.នៅវេលាម៉ោង ០៧នឹង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាលអូរជា ចំនួន០៤នាក់ អាវុធវែងខ្លី០៤ដើម ដឹកនាំដោយលោកវ.ត្រី តិប រ៉ុម នាយប៉ុស្តិ៍ បានសហការជាមួយកម្លាំងយោធាវរៈ៥៣៤(កងពល៥៣)ចំនួន៤នាក់ អាវុធវែង៣ដើម និងកម្លាំងល្បាត៥០៤ ចំនួន៣នាក់អាវុធវែង០៣ដើម ដឹកនាំដោយលោកពលបាលឯក ខឿន បញ្ញា មេបញ្ជាការរងខ បានដើរល្បាតចាប់ពីនិយាមក INDI 226864E-1443158N ដល់ចំណុចដើមស្រឡៅ និយាមកា INDI 226164E-1444827N ជាលទ្ធផល ស្ងប់ស្ងាត់ធម្មតា និងបានបញ្ចប់នៅវេលាម៉ោងនឹង១៥នាទី ថ្ងៃដដែល ។

# ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ២០២៣

## ក្រសួងការងារ ប្រកាសឲ្យពលករខ្មែរជំនាញផ្នែកកសិកម្ម ប្រញាប់ដាក់ពាក្យធ្វើតេស្ត ដើម្បីបានទៅធ្វើការនៅជប៉ុន

https://www.kampucheathmey.com/local-news/510179 ថ្ងៃសៅរ៍ ១៣ ឧសភា ២០២៣ដោយ Inn Pisey

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសឲ្យពលករខ្មែរជំនាញផ្នែកកសិកម្មទាំងអស់ ប្រញាប់មកដាក់ពាក្យធ្វើតេស្តជំនាញ និងភាសា ដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុន ទទួលបានបទពិសោធន៍ការងារល្អៗ និងទទួលបានប្រាក់ខែខ្ពស់។

លោក ប្រាក់ ចាន់ធឿន រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងនៅក្នុងសេចក្តីជូនដំណឹងមួយទើបទទួលបាននៅថ្ងៃទី ១៣ ឧសភានេះថា អង្គភាពទទួលបន្ទុកការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញ នឹងរៀបចំការធ្វើតេស្តភាសា និងតេស្តជំនាញផ្នែកកសិកម្ម តាមរយៈប្រព័ន្ធកុំព្យូទ័រ។ លោករដ្ឋលេខាធិការបានបន្តថា ការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញនេះ នឹងប្រព្រឹត្តិទៅនៅវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ ដែលមានអាសយដ្ឋាននៅសង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្នុងតម្លៃធ្វើតេស្តចំនួន ២៦ ដុល្លារអាមេរិក ដោយកាលបរិច្ឆេទ នៃការធ្វើតេស្តរួមមាន ថ្ងៃទី ១១ ឧសភា ,២១ ឧសភា ,២៥ ឧសភា ,២៦ ឧសភា ,១និង ២ មិថុនា ៦ ,៧ ១៤, ២៣, ២៤,និងថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៣។ លោករដ្ឋលេខាធិការ បានបន្តទៀតថា ចំពោះការចុះឈ្មោះធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញ បេក្ខជនត្រូវមានអាយុចាប់ពី ១៧ ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា លិខិតឆ្លងដែន ឬ ប័ណ្ណបើកបរ។ ពិន្ទុធ្វើតេស្តជាប់ជាស្ថាពរចាប់ពី ៦០% ឡើងទៅ ហើយចំនួនបេក្ខជនដែលអាចទទួលសម្រាប់ការស្នើសុំធ្វើតេស្តបាន ៥០ នាក់ ក្នុង ១ ខែ។

យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ឆ្នាំ ២០២៣ នេះ កូរ៉េ ត្រូវការកម្លាំងពលកម្មពីប្រទេសកម្ពុជាប្រមាណជាង ១ ម៉ឺននាក់ ខណៈបច្ចុប្បន្នមានពលករខ្មែរកំពុងធ្វើការនៅកូរ៉េប្រមាណជាង ៤៥០០០ នាក់៕ អត្ថបទ ៖ សំអឿន

# ពលករខ្មែរដែលត្រូវបានសមត្ថកិច្ច
# ចាប់ខ្លួនរៀបរាប់ពីទុក្ខលំបាកដែលសមត្ថកិច្ចថៃធ្វើបាបពួកគាត់

https://www.rfa.org/khmer/news/human-rights/arrested-cambodian-workers-in-thailand-described-their-suffering-after-thai-authorities-torture-them-05142023053232.html ដោយ សេក បណ្ឌិត 2023.05.14

ពលករខ្មែរដែលត្រូវបានសមត្ថកិច្ចចាប់ខ្លួនរៀបរាប់ពីទុក្ខលំបាក ដែលសមត្ថកិច្ចថៃធ្វើបាបពួកគាត់ និងរិះគន់ថា មន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ មិនបានយកចិត្តទុកដាក់ជួយពលករទេ។ ការលើកឡើងនេះ ខណៈសមត្ថកិច្ចថៃបានចាប់ពលករខ្មែរ ជាបន្តបន្ទាប់ ហើយពលករមួយចំនួន ត្រូវបានសមត្ថកិច្ចថៃដាក់ច្រវាក់ដូចឧក្រិដ្ឋជន។ មន្ត្រីសង្គមស៊ីវិលការពារសិទ្ធិពលកររិះគន់ថា ការដាក់ច្រវាក់លើពលករបែបនេះហាក់បីដូចក្រុមពលករដែលត្រូវចាប់ខ្លួនប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរ ប៉ុន្តែ ក្រុមពលករទាំងនោះគ្រាន់តែមានបញ្ហាខ្វះខាតឯកសារ ឬលួចធ្វើការដោយគ្មានឯកសារប៉ុណ្ណោះ។ ពលករខ្មែរត្រូវបានសមត្ថកិច្ចថៃ ចាប់ដាក់ច្រវាក់ជាក្រុម និងពលករជាប់ឃុំផ្សេងនៅតែតក់ស្លុតក្នុងចិត្ត នៅពេលនឹកដល់ការជាប់ឃុំរបស់ពួកគាត់នៅប្រទេសថៃ។ ក្រុមពលករលើកឡើងថា សមត្ថកិច្ចថៃ យកពួកគាត់ទៅឃុំនៅកន្លែងតូចចង្អៀតពោរពេញដោយអ្នកជាប់ឃុំ ហើយនៅទីនោះកន្លែងគេង កន្លែងហូបបាយ និងបង្គន់គឺរួមគ្នា។

ស្ត្រីពលករម្នាក់ដែលហៅឈ្មោះក្រៅថា ស្រីលក្ខណ៍ ឱ្យវិទ្យុអាស៊ីសេរីដឹងថា សមត្ថកិច្ចថៃបានបើកឡានចេញធ្នាក់ចេញចាប់ក្រុមលោកស្រី ដែលជិះឡានធ្វើសំណង់មួយកន្លែងនៅប្រទេសថៃ កាលពីខែមេសា។ លោកស្រីឱ្យដឹងទៀតថា មូលហេតុដែលប៉ូលិសថៃ ដេញចាប់ឡានលោកស្រី ព្រោះឡានដឹកកម្មករនោះគ្មានស្លាកលេខ ហើយសមត្ថកិច្ចត្រួតពិនិត្យរកឃើញថា ក្រុមលោកស្រីមិនមានឯកសារធ្វើការងារគ្រប់គ្រាន់ ក៏ត្រូវសមត្ថកិច្ចថៃបានយកដាក់ច្រវាក់ដៃលោកស្រី និងពលករជាង១០នាក់ផ្សេងទៀត ហើយដឹកតាមឡានយកទៅដាក់ឃុំ។ លោកស្រីរំលឹកថា ឱ្យតែនឹកដល់ថា រឿងសមត្ថកិច្ចថៃចាប់ដាក់ច្រវាក់នេះ គឺលោកស្រី នៅតែតក់ស្លុតក្នុងចិត្ត។ ស្រីលក្ខណ៍៖ «កណ្ដោចកណ្ដែងគ្រប់គ្នាយំទាំងអស់តែគ្នា ខ្ញុំអត់ដឹងថា ម៉េចដែរ? នាំគ្នាគ្រាន់តែទោសប៉ុណ្ណឹងដល់ថ្នាក់ដាក់ច្រវាក់ ហើយដល់ពេលហើយនៅពេលខ្ញុំនៅឃុំ គេ (សមត្ថកិច្ចថៃ) គេចាក់សោមួយជាន់ហើយស្រីៗគេចាក់មួយជាន់ទៀត កន្លែងតូច»។

ស្ត្រីពលកររូបនេះរៀបរាប់ទៀតថា សមត្ថកិច្ចថៃ បានយកលោកស្រី និងពលករខ្មែរផ្សេងទៅឃុំខ្លួនក្នុងបន្ទប់ឃុំឃាំងមួយកន្លែងដែលបណ្ដោយជាង ៥ម៉ែត្រ និងទទឹងជាង ៤ម៉ែត្រ ក្នុងនោះមានអ្នកជាប់ឃុំជនជាតិខ្មែរ និងជនជាតិផ្សេងទៀតជាង ៥០នាក់។ លោកស្រីបន្តទៀតថា អ្នកជាប់ឃុំនៅទីនេះត្រូវគេងប្រជ្រៀតគ្នា ហើយក្នុងបន្ទប់នោះទាំងកន្លែងគេង កន្លែងហូបបាយ និងបង្គន់គឺនៅរួមគ្នា ហើយបង្គន់នោះ គ្មានទ្វារបិទបាំងជិតនោះទេ។ លោកបន្តថា អាហារដែលសមត្ថកិច្ចថៃផ្ដល់ឱ្យពិបាកហូប ចំណែកទឹកផឹក គឺជាទឹកចម្រុះពីទុយោ តែបើអ្នកជាប់ឃុំណាមានលុយអាចទិញទឹកទិញបាយម្ហូបនៅកន្លែងឃុំខ្លួននេះបាន។ ស្រីលក្ខណ៍៖ «ណែនដេកមិនចង់កើតទេ មុជទឹកហ្នឹង បង្គន់ក៏នៅហ្នឹង ហូបបាយក៏ហ្នឹងស្អុះស្អាប់ពិបាកណាស់ ហើយទឹកគេដាក់ទុយោតែគេដាក់ចម្រុះអ្នកខ្លះហូបហើយ ឈឺគ្រប់គ្នា។ ខ្ញុំនៅប៉ុន្មានថ្ងៃខ្ញុំចង់កើតស្ត្រេស្ត គេមានបង្គន់មានបន្ទប់ទឹកក្នុងហ្នឹង ហើយបង្គន់គេគ្មានទ្វារគ្មានអីទេ ចានបង្គន់ចំមាត់ទ្វារហ្នឹងបណ្ដោយក្បាលនៅជ្រងោកណ្ដាលវាល»។

លោកស្រី ស្រីលក្ខណ៍ និងពលករខ្មែរជាង១០នាក់ទៀត ដែលក្រុមលោកស្រី ត្រូវសមត្ថកិច្ចដាក់ច្រវាក់នោះបានឃុំនៅប្រទេសថៃអស់រយៈពេល៨ថ្ងៃ។ សមត្ថកិច្ចថៃបានដោះលែងលោកស្រីនិងពលករផ្សេងទៀតកាលពីដើមខែឧសភា ក្រោយពេលក្រុមពលករបង់លុយឱ្យសមត្ថកិច្ចថៃម្នាក់ៗ៣ពាន់បាត ឬជិត ១រយដុល្លារ។ ពេលនេះពល

ករទាំងនោះបានទៅដល់ប្រទេសកម្ពុជាជាងពីរសប្ដាហ៍ហើយ។ លោកស្រី ស្រីលក្ខណ៍ រិះគន់ថា មន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក មិនបានជួយអន្តរាគមន៍ដល់លោកស្រី និងពលករផ្សេងទៀតនោះទេ។ លោកស្រីរំលឹកថា នៅពេលក្រុមលោកស្រីកំពុងជាប់ឃុំឃើញមានមន្ត្រីស្ថានទូតទៅជួបសមត្ថកិច្ចថៃ នៅកន្លែងឃុំខ្លួននោះដែរ តែមន្ត្រីស្ថានទូតមិនបានឱ្យដឹងថា ពួកគេជួយលើផ្នែកអ្វីដល់ពលករនោះទេ។ លោកស្រីថា នៅពេលឃើញមន្ត្រីស្ថានទូតបែប ក្រុមលោកស្រី បានសុំឱ្យមន្ត្រីស្ថានទូតជួយអន្តរាគមន៍ និងជួយឧបត្ថម្ភថវិកាខ្លះដល់ក្រុមពលករ តែមន្ត្រីស្ថានទូតត្រឹមទិញទឹកសុទ្ធពីរយួរឱ្យក្រុមពលករដែលជាប់ឃុំជាង ១០នាក់។ ស្រីលក្ខណ៍៖ «គេ(មន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ) ទៅមើល តែមិនដឹងថា គេជួយម៉េចៗខ្ញុំអត់ដឹងដែរ ខ្ញុំសុំទឹកគេបានពីរយួរ នេះខ្ញុំនិយាយឃើញជាក់ស្ដែង ឬគេបានទៅនិយាយជាមួយប្រធានគុកគេឬក៏រដ្ឋាភិបាលគេអីដែរ ខ្ញុំមិនដឹងទេ ខ្ញុំអត់សួរយល់ដែរ»។

ចំណែក ពលករខ្មែរធ្វើការនៅផ្សារមួយកន្លែងក្នុងខេត្តប៉ាកធុមថានី (Pak Thum Thani ) ដែលត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន កាលពីថ្ងៃទី២៤ ខែមេសា លោក ព្រំ ប៊ុនថន ឱ្យវិទ្យុអាស៊ីសេរីដឹងដែរថា សមត្ថកិច្ចថៃ បានឃុំខ្លួនលោកជាមួយពលករជាង៣០នាក់នៅបន្ទប់តូចចង្អៀត និងគ្មានអាហារហូបគ្រប់គ្រាន់ទេ។ លោក ព្រំ ប៊ុនថន ក៏ត្រូវបានសមត្ថកិច្ចដោះលែងវិញដែរ ក្រោយពេលថៅកែរបស់លោកបង់ប្រាក់មួយចំនួនទៅសមត្ថកិច្ចថៃ ហើយពេលនេះលោកកំពុងធ្វើការងារនៅកន្លែងការងាររបស់លោកដដែល។ លោក ព្រំ ប៊ុនថន៖ «ខ្ញុំក៏មានយោបល់អ៊ីចឹងដែរ អាក្រក់មើល ជនអន្តោប្រវេសន៍ប៉ុណ្ណឹងហើយយើងខុសច្បាប់ ដល់ថ្នាក់ដាក់ច្រវាក់អាក្រក់មើលមែន។ សំណូមពរដល់ខាងអង្គការសហប្រជាជាតិឬអង្គការណាមួយទូទាំងពិភពលោកនេះបើអាចសំណូមពរបានខាងអាជ្ញាធរថៃ បើសំណូមពរបាន ខ្ញុំក៏ជួយត្រេកអរសម្រាប់ប្រជាពលរដ្ឋខ្មែរយើងដែលមករស់នៅស្រុកគេដែរ»។

អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ចាត់ទុកសកម្មភាពសមត្ថកិច្ចថៃដាក់ច្រវាក់ក្រុមពលករខ្មែរ ជាការរំលោភសិទ្ធិមនុស្ស។ នាយករងប្រចាំតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិលោក ហ្វីល រ៉ូប៊ឺតសុន (Phil Robertson) ថ្លែងថា ទង្វើសមត្ថកិច្ចថៃនេះជាការប្រមាថមើលងាយពលករខ្មែរដូចសត្វធាតុ។

អង្គការសង់ត្រាល់ (CENTRAL) រកឃើញថា ពលករខ្មែរភាគច្រើនត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ពួកគាត់ត្រូវបានរងការធ្វើទុក្ខទោស ទារុណកម្ម ដោយការចាប់ដាក់ខ្នោះ និងត្រូវដាក់ឱ្យជាប់ឃុំក្នុងបន្ទប់តូចចង្អៀត។ សេចក្ដីថ្លែងការណ៍របស់អង្គការសង់ត្រាល់ចុះកាលពីថ្ងៃទី០៣ ខែឧសភា ឱ្យដឹងថា នៅរយៈពេលចុងក្រោយនេះ ពលករខ្មែរជាង ៨០០នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនកំឡុងពេលធ្វើដំណើរវិលត្រលប់ទៅបំពេញការងារវិញ នៅប្រទេសថៃក្រោយចប់បុណ្យចូលឆ្នាំថ្មី និងចាប់ខ្លួននៅកន្លែងដែលពលករធ្វើការ។

មន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៣ ខែឧសភា ថា ពលករខ្មែរដែលសមត្ថកិច្ចថៃចាប់ខ្លួនទាំងនោះភាគច្រើនត្រូវបានដោះលែងវិញហើយ។ លោកឱ្យដឹងទៀតថា តាមច្បាប់ប្រទេសថៃ ចំពោះអ្នកជាប់ឃុំស្រាលៗ ឬពលករបរទេសធ្វើការខុសច្បាប់នៅប្រទេសថៃ ជាប់ឃុំត្រឹមរយៈពេល៤៥ថ្ងៃ គឺសមត្ថកិច្ចថៃនឹងបញ្ជូនអ្នកជាប់ឃុំទាំងនោះឱ្យទៅប្រទេសកំណើតវិញ។ អ្នកការពារសិទ្ធិពលកររូបនេះឱ្យដឹងទៀតថា ចំពោះអ្នកដែលបន្តជាប់ឃុំនៅប្រទេសថៃ ព្រោះពួកគេគ្មានប្រាក់បង់ឱ្យសមត្ថកិច្ច គ្មានថៅកែមកធានា និងមិនទទួលបានការជួយធ្វើអន្តរាគមន៍ពីមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ហើយអ្នកខ្លះទៀតសំណុំរឿងពួកគាត់ត្រូវឡើងតុលាការ។ លោក លឹង សុផុន៖ « បើតាមរូបភាពដាក់ច្រវាក់អ៊ីចឹងយើងគិតថា គាត់(ពលករខ្មែរ)ជាអ្នកទោសកម្រិតធ្ងន់អីអ៊ីចឹងតែបើទោសធម្មតាអីមិនគួរដាក់ច្រវាក់ទេ ព្រោះកន្លងមក បើយើងជាប់ធម្មតាដូចខ្វះឯកសារអីហ្នឹងគ្រាន់តែហាមឃាត់ពួកគាត់ហើយឱ្យនៅក្នុងមន្ទីរឃុំឃាំងអីអ៊ីចឹងណា»។

ទាក់ទងរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំបំភ្លឺពីមន្ត្រីអនុព័ន្ធការងារនៃស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ លោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខឿន បានទេនៅថ្ងៃទី១៣ ខែឧសភា។

ចំណែកអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន យល់ថា ករណីសមត្ថកិច្ចថៃ ចាប់ពលករខ្មែរជាបន្តបន្ទាប់ជាងមួយខែមកនេះ គឺជាការអនុវត្តច្បាប់របស់សមត្ថកិច្ចថៃ។ ទោះយ៉ាងណា លោករំពឹងថា នៅពេលពលករខ្មែរធ្វើនៅប្រទេសថៃជួបបញ្ហាដូចនេះ គឺមន្ត្រីស្ថានទូតខ្មែរនឹងជួយធ្វើអន្តរាគមន៍។ លោក សុខ ឥសាន ៖ «ខ្ញុំមិនដល់យ៉ាងម៉េចទេ ខ្ញុំយល់ថា អាជ្ញាធរថៃគេធ្វើតាមច្បាប់របស់គេត្រង់យើងមើលឃើញមិនគួរគប្បីយ៉ាងណាជារឿងទេ ក៏ប៉ុន្តែគេអនុវត្តតាមគោលការណ៍ច្បាប់របស់ថៃ អ៊ីចឹងយើងគ្មានអីក្រៅអំពីទំនាក់ទំនងជាមនោសញ្ចេតនាដើម្បីឱ្យគេ(សមត្ថកិច្ចថៃ)ដោះលែងបងប្អូនត្រឡប់មកស្រុកកំណើតវិញ»។ បើទោះជាមន្ត្រីជាន់ខ្ពស់បក្សកាន់អំណាចរំពឹងបែបនេះក្តី ពលករដែលត្រូវសមត្ថកិច្ចថៃចាប់ខ្លួនបានឱ្យវិទ្យុអាស៊ីសេរីដឹងថា មន្ត្រីស្ថានទូតខ្មែរមិនបានជួយអ្វីដល់ពួកគេទេ ហើយប្រសិនពលករទាំងនោះគ្មានប្រាក់បង់ឱ្យសមត្ថកិច្ចថៃ ឬគ្មានថៅកែបង់ប្រាក់ជានានោះទេ គឺពួកគេនៅជាប់ឃុំក្នុងពន្ធនាគារឡើយទេ។

លោកស្រី ស្រីលក្ខណ៍ ប្រាប់វិទ្យុអាស៊ីសេរីថា កាលពីលោកស្រីកំពុងជាប់ឃុំ លោកស្រី បានលួចផ្ញើសារជាសំឡេងតាមបណ្តាញសង្គមហ្វេសប៊ុក ចេញមកក្រៅថា មន្ត្រីស្ថានទូតខ្មែរមិនបានជួយអ្វីដល់អ្នកជាប់ឃុំទេ តែពេលនោះ មានមន្ត្រីស្ថានទូតដឹងរឿងនេះ ហើយព្រមានអ្នកជាប់ឃុំថា បើក្រុមអ្នកជាប់ឃុំហ៊ានរិះគន់ស្ថានទូតទៀត ពួកគាត់នឹងត្រូវជាប់ឃុំយូរជាងនេះ។ លោកស្រី ស្រីលក្ខណ៍៖ «ជួយស្អីមកមិនបានជួយស្អីផង បានទឹកពីរយូរខ្ញុំនិយាយខ្លាំងៗដែរ នៅក្នុងហ្នឹង (មន្ទីរឃុំឃាំង) យើងមួម៉ៅផង ហើយស្ថានទូតគេមកសម្លុតពួកខ្ញុំ គេមិនមកសម្លុតខ្លួនឯងទេ គេផ្ទាល់គេឱ្យផ្ទាំគុកមកសម្លុតគេថា ពួកខ្ញុំហ្នឹងនិយាយផ្តេសផ្តាសម៉េចចង់ជាប់គុកថែមទៀតអី? ចង់ជាប់គុកបួនប្រាំខែទៀតអី គេថា អ៊ីចឹង ខ្ញុំភ័យរហូតរាល់ថ្ងៃ»។

ក្រសួងការងារឱ្យដឹងថា មានពលករ ១លាន ៣សែននាក់ កំពុងធ្វើការងារនៅប្រទេសថៃ ប៉ុន្តែ អង្គការសង់ត្រាល់រកឃើញថាពលករខ្មែរធ្វើការនៅប្រទេសនេះមានជាង២លាននាក់បូករួមទាំងពលករគ្មានឯកសារគ្រប់គ្រាន់។

ក្រុមពលករលើកឡើងថា ពួកគាត់មិនចង់ធ្វើការខុសច្បាប់នៅប្រទេសថៃទេ ប៉ុន្តែ ពួកគេត្រូវចំណាយប្រាក់អស់ច្រើន ទម្រាំបានឯកសារ ដោយអ្នកខ្លះត្រូវចំណាយប្រាក់ពី ៧រយ ទៅ១ពាន់ដុល្លារ អ្នកខ្លះទៀតដែលមានឯកសាររួចហើយ តែត្រូវផុតកំណត់ គឺត្រូវចំណាយប្រាក់មួយចំនួនធំថែមទៀត ដើម្បីបន្តសុពលភាពប័ណ្ណការងារ ហើយពេលខ្លះពួកគាត់បង់លុយឱ្យមេការរួចហើយ តែមេការមិនធ្វើឯកសារឱ្យទេ ឬផ្តល់ឯកសារមកឱ្យពួកគាត់យឺតយ៉ាវ៕

## សមត្ថកិច្ចខេត្តបាត់ដំបងចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://www.gdlf-kh.com/2023/05/13/-66/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃសៅរ៍ ៩រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក និងវរសេនីយឯក ស៊ិន ប៊ុនស្មី ស្នងការរងទទួលដឹកនាំវរៈ

៨១៩។ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក អិន កុល មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់ឲ្យ នាយប៉ុស្តិ៍ប្រចាំការនៅជួរមុខ ត្រៀមកម្លាំងចេញល្បាត រួមមាន៖

-នៅវេលាម៉ោង០៨៖០០នាទី កម្លាំងប៉ុស្តិ៍នគរបាលប៉ុស្តិ៍អូរអន្លក់ ចំនួន ០៦នាក់ អាវុធវែងខ្លីចំនួន០៤ ដើម ដឹកនាំដោយ លោកអនុសេនីយ៍ឯក សយ សឿន នាយរងប៉ុស្តិ៍ បានចុះល្បាតពិនិត្យតាមខ្សែបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រ ចាប់ពីចំណុច និយាមការ WGS84 217879E 1457965N(ប៉ុស្តិ៍ច្រកទ្វារអូអន្លក់) ដល់ចំណុចនិយាមកា WGS84 218531E 1456660N(ដល់ចំណុកោះតាធឹម)។ ក្រោយពីបានដើរល្បាតរួចពិនិត្យឃើញថាពុំមានអ្វីប្រែប្រួលគួរអោយកត់សំគាល់ឡើយ និងបានបញ្ចប់វេលាម៉ោង០៩នឹង៤០នាទីនាព្រឹកថ្ងៃដដែល។

## កងកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចេញល្បាតទប់ស្កាត់បទល្មើសគ្រប់ប្រភេទ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ(ស្រុកសំពៅលូន)

https://www.gdlf-kh.com/2023/05/13/ 39/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃសុក្រ ៨រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ដោយអនុវត្តតាមបទបញ្ជារបស់ឯកឧត្តមឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ កម្លាំងប៉ុស្តិ៍ព្រំដែនចក្រី ចំនួន៦នាក់ ដឹកនាំដោយលោកព្រិន្ទបាលឯក មុត ស៊ីណាត នាយរងប៉ុស្តិ៍ ចេញល្បាតត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង ពិនិត្យឃើញថាសកម្មភាពតាមព្រំដែនមានសភាពស្ងប់ស្ងាត់ធម្មតា៕

# ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០២៣

## ក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំពិភាក្សា ដោះស្រាយភាពស្របច្បាប់ សម្រាប់ពលករទេសន្តប្រវេសន៍ កំពុងធ្វើការងារនៅថៃដែលមានឯកសារផុតសុពលភាព

https://cen.com.kh/archives/658938.html Posted ByPen Srey NeatMay 16, 2023

ភ្នំពេញ ៖ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំពិភាក្សា ដោះស្រាយភាពស្របច្បាប់សម្រាប់ពលករទេសន្តប្រវេសន៍ ដែលបាននឹងកំពុងធ្វើការងារក្នុងប្រទេសថៃដែលមានឯកសារផុតសុពលភាព, ជិតផុតសុពលភាព និងមិនមានឯកសារ ដោយមានការអញ្ជើញចូលរួមពី រដ្ឋលេខាធិការក្រសួងមហាផ្ទៃ, អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ, អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត នៅទីស្តីការក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃអង្គារ ទី១៦ ខែឧសភា ឆ្នាំ២០២៣នេះ ។

នាឱកាសនោះដែរ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានលើកឡើងថា កម្ពុជា បានបង្កើតឱ្យមានមជ្ឈមណ្ឌលទទួលពលករចំនួន ២កន្លែង នៅខេត្តបន្ទាយមានជ័យ ហើយមណ្ឌលនេះ ក៏ជាទីកន្លែងទទួលព័ត៌មានទិន្នន័យនូវពលករបានឆ្លងកាត់ ពិសេសពលករ ដែលត្រូវបញ្ជូនត្រឡប់មកពីប្រទេសថៃវិញ។ លោកជំទាវ រដ្ឋលេខាធិការ លើកឡើងទៀតថា គ.ជ.ប.ជ ចាត់ទុកការងារទេសន្តប្រវេសន៍ជាផ្នែកមួយ នៃយុទ្ធសាស្ត្របង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេស ក្នុងចំណោមជនទេសន្តប្រវេសន៍ផងដែរ។

ឆ្លៀតឱកាសនោះ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ បានផ្តល់អនុសាសន៍ដល់អង្គប្រជុំថា យើងត្រូវរួមគ្នាពិនិត្យប្រព័ន្ធ និងកិច្ចសហប្រតិបត្តិការរវាង កម្ពុជា-ថៃ ក្នុងការគ្រប់គ្រងពលករ ដែលធ្វើការងារនៅប្រទេសថៃ ខណៈប្រទេសទាំងពីរ បានចុះអនុស្សារណៈយោគយល់គ្នានាពេលកន្លងមក។ ជាមួយគ្នានេះ ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ ក៏បានថ្លែងអំណរគុណចំពោះអង្គប្រជុំ បានរួមគ្នាទប់ស្កាត់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទោះបីមានបញ្ហាជំងឺកូវីដ-១៩ ក៏ដោយ។ ចំពោះវិធានការដោះស្រាយចំពោះមុខ ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ ស្នើគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបន្តធ្វើការងារជាមួយភាគីថៃ ដើម្បីផ្តល់ភាពស្របច្បាប់ចំពោះពលករខ្មែរណាមិនទាន់មានភាពស្របច្បាប់ ដើម្បីធ្វើយ៉ាងណាឱ្យពួកគាត់មានភាពស្របច្បាប់ សម្រាប់បំពេញការងារនៅប្រទេសថៃ៕ រក្សាសិទ្ធដោយ : ចេស្តារ

## ពលករខ្មែរនៅប្រទេសថៃរាប់រយនាក់មានជីវភាពខ្វះខាតដោយសារអត់ការងារធ្វើ

https://www.rfa.org/khmer/news/human-rights/some-cambodian-workers-in-thailand-are-living-in-poverty-due-to-unemployment-05152023072938.html ដោយ សុជីវី2023.05.15

ពលករខ្មែររាប់រយនាក់នៅក្នុងខេត្តមួយនៃប្រទេសថៃកំពុងជួបការលំបាកខ្វះលុយទិញអាហារ និងបង់ថ្លៃបន្ទប់ជួល ដោយសារអត់ការងារធ្វើ។ មន្ត្រីសង្គមស៊ីវិលជំរុញឱ្យស្ថាប័នពាក់ព័ន្ធដោះស្រាយឱ្យបានទាន់ពេលយ៉ាងហោចណាស់ ជួយឱ្យពលករទាំងនោះមានអាហារ និងកន្លែងស្នាក់នៅសមរម្យ។ ពលករខ្មែររាប់រយនាក់ធ្វើការងារនៅក្នុងតំបន់មួយនៅក្នុងខេត្តរ៉ាក់យង់ (Rayong) ប្រទេសថៃ កំពុងជួបបញ្ហាខ្វះខាត អាហារនិងមិនមានលុយបង់ថ្លៃបន្ទប់ជួលដោយ សារតែគ្មានការងារធ្វើ។

ពលករខ្មែរលោកស្រី ស៊ិន ដា ថ្លែងនៅថ្ងៃទី១៤ ខែឧសភា ថា រោងចក្រជាច្រើនបានបញ្ឈប់ពលករខ្មែរជាបន្តបន្ទាប់ ដោយមិនមានផ្តល់សំណងអ្វីសមស្របទេ បណ្តាលឱ្យអ្នកទាំងនោះបាត់បង់ប្រាក់ចំណូលសម្រាប់ចំណាយលើអាហារ និងការស្នាក់នៅ។ លោកស្រី ស៊ិន ដា៖ «ឥឡូវរោងង៉ាន(រោងចក្រ)គេកាត់ឈ្មោះច្រើនណាស់ រាប់រយនាក់ឯណោះ។ គេថា អត់ការងារធ្វើរោងង៉ានគេកាត់ឈ្មោះចោលបណ្តោយ។ គេឱ្យយើងទៅរកការងារថ្មី ទៅរកឯណាក៏រកទៅ»។ លោកស្រីបន្តថា ពលករខ្មែរ៥នាក់កំពុងសុំបន្ទប់របស់លោកស្រីស្នាក់នៅ ខណៈរាប់រយនាក់ផ្សេងទៀតក៏កំពុងសុំអ្នកស្គាល់គ្នាស្នាក់នៅដែរ។

ពលករម្នាក់ទៀតគឺយុវតី គឹម សៀន ឱ្យដឹងថា កញ្ញាត្រូវរើអីវ៉ាន់ចេញទៅនៅបន្ទប់អ្នកជិតខាងនៅប៉ុន្មានថ្ងៃខាងមុខនេះ ដោយសារតែមិនមានលុយបង់ថ្លៃបន្ទប់ជួល។ កញ្ញា គឹម សៀន ថា អត់ការងារធ្វើនៅដើមខែឧសភា ហើយម្យ៉ាងគ្រួសារកញ្ញាជំពាក់បំណុលគេច្រើន ទើបមិនអាចខ្ចីលុយថៅកែ ឬអ្នកផ្សេងដើម្បីដោះស្រាយក្នុងស្ថានភាពលំបាកនេះបានទេ។ កញ្ញា គឹម សៀន៖ «ប្រាប់គាត់ហើយ គាត់ថា ឱ្យយកលុយថៅកែនៅរោងង៉ាន(រោងចក្រ) ចាយសិន។ ប៉ុន្តែថៅកែគាត់ថា អត់អាចយកបានទេ ព្រោះថា ជំពាក់ច្រើនហើយ»។

សមាជិកបណ្តាញអ្នកស្ម័គ្រចិត្តជួយពលករខ្មែរនៅប្រទេសថៃលោក សយ ប៊ុនរ៉េត ឱ្យដឹងថា ពលករខ្មែរនៅក្នុងខេត្តរ៉ាក់យង់ កំពុងជួបការលំបាកច្រើន គឺអ្នកចាស់ បាត់បង់ការងារ ចំណែកអ្នកដែលទើបធ្វើដំណើរពីកម្ពុជាទៅដល់ទឹកដីថៃថ្មីៗ រកការងារមិនបានធ្វើនៅឡើយ។ លោកបន្តថា មូលហេតុដែលពលករខ្មែរត្រូវគេបញ្ឈប់ពីការងារ មិនទទួលបាន សំណងនោះដោយសារពួកគេជាពលករខុសច្បាប់ និងមួយចំនួនមិនគ្រប់អាយុដែល ច្បាប់ការងារថៃទទួលឱ្យធ្វើការ។ ចំណែកករណីយុវតី គឹម សៀន ដែលកំពុងប្រឈមការដេញចេញ ពីបន្ទប់ស្នាក់ នៅនោះលោក ប៊ុន រ៉េត ថា លោកកំពុងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធឱ្យជួយដោះស្រាយ។ លោក ប៊ុន រ៉េត៖ «ខ្ញុំ

ប្រាប់ជាហើយ ហើយជា ថា គេកំពុងពិភាក្សាជាមួយមេធំថា តើអាចជួយថ្លៃហង់(បន្ទប់ជួល)បានឬយ៉ាងណា? ៣ ពាន់ហ្វឹង(បាត) ឬមានកញ្ចប់ស្បៀងអាហារថែមទៀត»។

ប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពលោក យង់ គិមអេង មានប្រសាសន៍ថា អ្នកដែលទទួលខុសត្រូវចំពោះ បញ្ហានេះ គឺស្ថានទូត ខ្មែរប្រចាំនៅប្រទេសថៃ។ លោកជំរុញឱ្យស្ថានទូតជួយដោះស្រាយឱ្យបានទាន់ពេល យ៉ាងហោចណាស់ឱ្យពលករមានអាហារនិងកន្លែងស្នាក់នៅសមរម្យ។ លោក យង់ គិមអេង៖ «ឥឡូវគាត់អស់លុយអស់កាក់ហើយ គាត់អស់ទាំងលុយ ទិញអាហារហូបចុកអីផងអាហ្នឹង យ៉ាងហោចណាស់ក៏ជួយដោះស្រាយ អាហារហូប ចុកគ្នាខ្លះអ៊ីចឹងទៅ»។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ និង មន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសាកសួរបញ្ហានេះបានទេ នៅថ្ងៃទី១៤ ខែឧសភា។

តាមរបាយការណ៍របស់អង្គការសង់ត្រាល់គឺក្រោយពិធីបុណ្យចូលឆ្នាំខ្មែរ នៅខែមេសាកន្លងទៅនេះចំនួនពលរដ្ឋខ្មែរសម្រុកទៅរកការងារធ្វើនៅក្នុងប្រទេសថៃដោយខុសច្បាប់មានចំនួនច្រើន។ របាយការណ៍សង់ត្រាល់ក៏បានឱ្យដឹងទៀតថា ពលករខ្មែរកំពុងធ្វើការងារនៅក្នុងប្រទេសថៃ មានប្រមាណ ២លាននាក់ ក្នុងនោះពាក់កណ្ដាលជាពលករខុសច្បាប់ដែលប្រឈមសមត្ថកិច្ចថៃចាប់ខ្លួន និងប្រឈមការកេងប្រវ័ញ្ចពីថៅកែដែរ។ នៅចុងខែមេសាកន្លងទៅ ក៏មានពលករខ្មែរជាង ៨រយនាក់ត្រូវយោធាថៃចាប់ខ្លួនដោយសារមិនមានឯកសារស្នាក់នៅស្របច្បាប់ នៅក្នុងនោះមួយចំនួនត្រូវយោធាថៃ ចងដោយច្រវាក់ជាក្រុមៗ៕

## ជនជាតិខ្មែរម្នាក់ត្រូវបានចាប់ខ្លួននៅប្រទេសថៃក្រោមបទល្មើសផ្លូវភេទ

https://www.khmertimeskh.com/501291393//?p=1291393 Khmer Times May 16, 2023

បុរសម្នាក់ ដែលបានភៀសខ្លួនទៅប្រទេសថៃបន្ទាប់ពីបានប្រព្រឹត្តបទល្មើសផ្លូវភេទនៅកម្ពុជា ត្រូវបានចាប់ខ្លួននៅខេត្តចាន់ថាបុរី កាលពីថ្ងៃអាទិត្យ។ នគរបាលអន្តោប្រវេសន៍ខេត្ត ចាន់ថាបុរី បានចាប់ខ្លួនឈ្មោះ អ៊ីង សំណាង អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ តាមដីកាចាប់ខ្លួន ដែលចេញដោយតុលាការខេត្តឈុនបុរី កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០២០ បន្ទាប់ពីជននេះរត់គេចពីដីកាចាប់ខ្លួននៅប្រទេសកំណើត។ ជននេះត្រូវបានចោទប្រកាន់ពីបទ«នាំអនីតិជនអាយុលើស ១៥ ឆ្នាំ ទៅប្រព្រឹត្តមិនសមរម្យ ឬចាប់រំលោភ»។

មន្ត្រីស៊ើបអង្កេតនៅប៉ុស្តិ៍នគរបាលស្រីរ៉ាចាបាននិយាយថា សំណាងបានដាក់ពាក្យស្នើសុំការងារក្រោមគម្រោងរបស់រដ្ឋាភិបាលសម្រាប់ពលករបរទេសដែលមាន ៤ សញ្ជាតិ (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) នៅខេត្តចាន់ថាបុរី។ ដូច្នេះនគរបាលបានជូនដំណឹងទៅមន្ត្រីអន្តោប្រវេសន៍ខេត្តចាន់ថា បុរីដោយបានរកឃើញសំណាងឈរនៅលើផ្លូវខាងក្រៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្តចាន់ថាបុរី ហើយបន្ទាប់មកក៏បានស្នើសុំមើលឯកសាររបស់គាត់។

សំណាងបានសារភាពថាខ្លួនជាមនុស្សដែលបានរៀបរាប់លម្អិតក្នុងដីកាចាប់ខ្លួន បន្ទាប់មកនគរបាលបាននាំជននេះទៅប៉ុស្តិ៍នគរបាលស្រីរ៉ាចា ខេត្តឈុនបុរី ដើម្បីយកទៅកាត់ទោស។ Thaiger

# ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០២៣

## រដ្ឋាភិបាលពង្រឹងកិច្ចសហការ
## ជាមួយប្រទេសដៃគូ ដើម្បីទទួលបានឱកាសការងារសម្រាប់ពលរដ្ឋ

https://www.postkhmer.com/national/2023-05-16-1100-250072.html រី សុចាន់ | Publication date 16 May 2023 | 11:00 ICT

ភ្នំពេញៈ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសដៃគូ ដើម្បីទទួលបានឱកាសការងារនៅក្រៅប្រទេសជូនដល់ពលករប្រមាណ ១,៣ លាននាក់ ដែលអាចផ្ញើប្រាក់មកគ្រួសារប្រមាណ ២,៧ ពាន់លានដុល្លារក្នុង ១ ឆ្នាំៗ។ លោកថ្លែងដូច្នេះក្នុងពិធីសំណេះសំណាលជាមួយប្រធានរដ្ឋបាល និងប្រធានផ្នែកនៅតាមរោងចក្រសហគ្រាសជាង ៣ ៧០០ នាក់ មកពីរោងចក្រសហគ្រាសចំនួន ៣៨៤ ក្នុងបណ្តាខណ្ឌមួយចំនួន នៅរាជធានីភ្នំពេញ នៅសាលមហោស្រពកោះពេជ្រ នាថ្ងៃទី ១៤ ខែឧសភា។

លោកបញ្ជាក់ថា៖ «ទន្ទឹមនឹងឱកាសការងារក្នុងស្រុក រាជរដ្ឋាភិបាលខិតខំផ្តល់ជម្រើសជូនប្រជាពលរដ្ឋដែលមានបំណងចង់ធ្វើការងារនៅក្រៅប្រទេស ដោយបានខិតខំពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសដៃគូដើម្បីទទួលបានឱកាសការងារនៅក្រៅប្រទេសជូនពលករសរុបចំនួនប្រមាណ ១,៣ លាននាក់ ដែលមិនត្រឹមតែអាចទទួលបានប្រាក់ចំណូល បានចំណេះជំនាញប៉ុណ្ណោះទេ ថែមទាំងអាចផ្ញើប្រាក់បញ្ញើមកក្នុងប្រទេសជូនគ្រួសារប្រមាណ ២,៧ ពាន់លានដុល្លារអាមេរិកក្នុង ១ ឆ្នាំៗ និងចូលរួមការអភិវឌ្ឍប្រទេសជាតិ»។ បន្ថែមពីនេះ លោក អ៊ិត សំហេង ថ្លែងថា វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូបមានរោងចក្រចំនួន ១ ៣២៥ ហើយតម្លៃសរុបនៃការនាំចេញមានចំនួនប្រមាណជាង ១២,៨ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០២២ ដោយមានកម្មករនិយោជិតចំនួនជាង ៨៥ ម៉ឺននាក់។ កម្ពុជាបានក្លាយជាប្រទេសនាំមុខមួយក្នុងការនាំចេញផលិតផលកាត់ដេរនៅលើទីផ្សារអន្តរជាតិ។

លោកបន្តថា ការអនុវត្តច្បាប់ស្តីពីសហជីព បានបន្តលើកកម្ពស់សេរីភាព អង្គការវិជ្ជាជីវៈ ដោយគិតត្រឹមត្រីមាសទី១ ឆ្នាំ ២០២៣ ការចុះបញ្ជីអង្គការវិជ្ជាជីវៈបានកើនឡើងគួរឱ្យកត់សម្គាល់មានចំនួនសរុប ៦ ០៦៤ ដោយក្នុងនោះសហជីពមូលដ្ឋានចំនួន ៥ ៧៤១ សហព័ន្ធសហជីពចំនួន ២៦៨ សហភាពសហជីពចំនួន ៤២ និងសមាគមនិយោជកចំនួន ១៣។ លោកថា រាជរដ្ឋាភិបាលបានត្រៀមរៀបចំផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជននៃគ្រួសារក្រីក្រ និងងាយរងគ្រោះទូទាំងប្រទេសចំនួន ១,៥ លាននាក់ ដោយរដ្ឋជានាផ្តល់ប្រាក់ឧបត្ថម្ភចាប់ពីឆ្នាំ ២០២៣ នេះតទៅ ដើម្បីផ្តល់ឱកាសឱ្យពួកគេទទួលបានជំនាញសម្រាប់យកទៅធ្វើការងារឬបង្កើតមុខរបរដោយខ្លួនឯង និងបំពេញតម្រូវការនៃកម្លាំងពលកម្មជំនាញសម្រាប់ការវិនិយោគថ្មីៗនៅកម្ពុជា។

បើតាមរដ្ឋមន្ត្រីការងារ បច្ចុប្បន្ន សហគ្រាសគ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារមានចំនួន ១៧ ១០២ សហគ្រាសដែលមានកម្មករនិយោជិតចំនួន ១,៥ លាននាក់បានទទួលប្រាក់ឈ្នួលជាមធ្យមជាង ៤,៥៥ ពាន់លានដុល្លារក្នុង ១ ឆ្នាំៗ ហើយមានប្រជាពលរដ្ឋប្រមាណជាង ២ លាននាក់ទទួលផលដោយប្រយោលពីវិស័យនេះ។ នៅក្នុងពិធីនេះ លោកក៏រំឭកផងដែរថា ក្នុងពេលដែលវិបត្តិជំងឺកូវីដ ១៩ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពដែលអាចជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋរក្សាបាននូវជីវភាពរស់នៅ លំនឹងផលិតកម្ម អាជីវកម្មរបស់រោងចក្រ សហគ្រាស រក្សាបាននូវការងារ ប្រាក់ចំណូលកម្មករនិយោជិតរហូតដល់ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។

កាលពីខែមុន លោក អ៊ិត សំហេង ថ្លែងថា នៅឆ្នាំ ២០២៣ នេះ ដោយសារតែពលករខ្មែរនៅប្រទេសកូរ៉េខិតខំធ្វើការងារបានល្អ ហើយបានធ្វើឱ្យការវាយតម្លៃរបស់ពលករខ្មែរឈរនៅលំដាប់ថ្នាក់ទី ១ ក្នុងចំណោមពលករមកពីប្រទេសផ្សេងទៀត ដែលបាននិងកំពុងធ្វើការនៅកូរ៉េនេះ។ លោកថ្លែងក្នុងពិធីបុណ្យចូលឆ្នាំថ្មីខ្មែរនៅសាធារណរដ្ឋកូរ៉េថា៖ «ភាគីកូរ៉េ បានសន្យានឹងបង្កើនចំនួនពលករ ១ ម៉ឺននាក់បន្ថែមទៀត ឬលើសពីនេះដែលនេះជាព័ត៌មានដ៏ល្អបំផុតសម្រាប់បងប្អូនពលករយើង»៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ១នាក់

https://freshnewsasia.com/index.php/en/localnews/291791-2023-05-17-04-53-04.html 2023-05-17 11:53am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៥ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៧៧ករណី មានមនុស្ស ២,១៨២នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥០សំណើ និងបិទសំណុំរឿង ២៩៣សំណើ (រកឃើញមនុស្ស ១,២៦២នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៨៤ករណី៕

## ក្រសួងចំនួន ២
## កំពុងដោះស្រាយបញ្ហាភាពមិនស្របច្បាប់របស់ពលករមួយចំនួននៅប្រទេសថៃ

https://www.postkhmer.com/national/2023-05-17-1449-250130.html ជា សុខនី | Publication date 17 May 2023 | 14:49 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃកំពុងយកចិត្តទុកដាក់ ដោះស្រាយឱ្យមានភាពស្របច្បាប់សម្រាប់ពលករ ដែលកំពុងធ្វើការនៅប្រទេសថៃ ខណៈដែលក្រសួងការងារ និងអង្គការដៃគូក៏កំពុងពង្រឹងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅធ្វើការនៅប្រទេសថៃ ផងដែរ។

លោកសក់ សេដ្ឋារដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃបានដឹកនាំកិច្ចប្រជុំពិភាក្សាដោះស្រាយភាពស្របច្បាប់សម្រាប់ពលករទេសន្តប្រវេសន៍ក្នុងប្រទេសថៃដែលមានឯកសារផុតសុពលភាពជិតផុតសុពលភាព និងមិនមានឯកសារ។ នេះបើយោងតាមក្រសួងមហាផ្ទៃនាថ្ងៃទី១៦ខែឧសភា។ លោកសក់ សេដ្ឋាបានលើកឡើងនាថា៖« ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរួមគ្នាពិនិត្យប្រព័ន្ធ និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ថៃក្នុងការគ្រប់គ្រងពលករដែលធ្វើការងារនៅប្រទេសថៃខណៈប្រទេសទាំង២ បានចុះអនុស្សរណៈយោគយល់គ្នានាពេលកន្លងមកហើយដែរ»។

ចំពោះវិធានការដោះស្រាយចំពោះមុខ លោកសក់ សេដ្ឋា បានស្នើគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបន្តធ្វើការងារជាមួយភាគីថៃដើម្បីផ្តល់ភាពស្របច្បាប់ចំពោះពលករខ្មែរណាមិនទាន់មានភាពស្របច្បាប់ដើម្បីធ្វើយ៉ាងណាឱ្យពួកគាត់មានភាពស្របច្បាប់សម្រាប់បំពេញការងារនៅប្រទេសថៃ។

ក្នុងកិច្ចប្រជុំនោះដែរ លោកស្រី ជូប៊ុនអេងរដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក៏បានលើកឡើងដែរថាកម្ពុជាបានបង្កើតឱ្យមានមជ្ឈមណ្ឌលទទួលពលករចំនួន២កន្លែងក្នុងខេត្តបន្ទាយមានជ័យ។ មណ្ឌលនេះក៏ជាទីកន្លែងទទួលព័ត៌មានទិន្នន័យពីពលករដែលបានឆ្លងកាត់ពិសេសពលករដែលត្រូវបានបញ្ជូនត្រឡប់មកពីប្រទេសថៃវិញ។ លោកស្រីបានបញ្ជាក់ថា៖«គ.ជ.ប.ជ ចាត់ទុកការងារទេសន្តរប្រវេសន៍ជាផ្នែកមួយនៃយុទ្ធសាស្ត្របង្ការទប់ស្កាត់អំពើជួញដូរមនុស្សជាពិសេសក្នុងចំណោមជនទេសន្តរប្រវេសន៍ផងដែរ»។

ទន្ទឹមគ្នានេះដែរកាលពីថ្ងៃទី១៦ ខែឧសភា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)ក៏បានរៀបចំសិក្ខាសាលាស្តីពីការពិនិត្យលទ្ធផល នៃការសិក្សាលើការពង្រឹងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅធ្វើការនៅប្រទេសថៃផងដែរ។

យោងតាមក្រសួងការងារបានឱ្យដឹងថាសិក្ខាសាលានេះមានគោលបំណងបង្ហាញជូននូវលទ្ធផល នៃការសិក្សា ស្តីពីការពង្រឹងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅធ្វើការនៅប្រទេសថៃ និងពិនិត្យពិភាក្សាផ្តល់ជាតុចូលឬអនុសាសន៍ពីដៃគូពាក់ព័ន្ធលើសេចក្តីព្រាងនៃការសិក្សានេះ។

ជុំវិញរឿងនេះលោកមឿនតុលាប្រធានអង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស(សង់ត្រាល់) បានប្រាប់កាលពីថ្ងៃទី១៧ខែឧសភាថាមិនថាកាលពីមុនឬបច្ចុប្បន្ននេះទេពលករមួយចំនួននៅតែទៅធ្វើចំណាកស្រុកទៅប្រទេសថៃដោយគ្មានឯកសារស្របច្បាប់ដដែល។ លោកបានបន្តថា តាមការលើកឡើងរបស់ពលករការធ្វើឯកសារមានភាពស្មុគស្មាញនិងត្រូវចំណាយសេវាជាច្រើន។ លោកមឿនតុលាបានថ្លែងថា៖«ប្រសិនក្រសួងបានជជែកជាមួយភាគីថៃពីការផ្តល់ និងពន្លឿនក្នុងការធ្វើឯកសារស្របច្បាប់ដល់ពលករ និងការបន្ថយភាពស្មុគស្មាញមួយចំនួនដែលពលករជួបប្រទះនោះវាជាផលប្រយោជន៍យ៉ាងធំធេងសម្រាប់ពលករយើង ដោយសារពួកគាត់ត្រូវការភាពស្របច្បាប់នេះឯងដើម្បីអាចកាត់បន្ថយហានិភ័យនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម»។

យោងតាមការស្ទាបស្ទង់របស់អង្គការសង្គមស៊ីវិល និងសហជីពនៅប្រទេសថៃបានប៉ាន់ប្រមាណថា ពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃមានប្រមាណជាង២លាននាក់ ហើយក្នុងចំណោមពលករទាំងនេះ មានប្រហែលជាង៤០% ជាពលករដែលធ្វើការដោយមិនទាន់មានឯកសារស្របច្បាប់ត្រឹមត្រូវ។នេះបើតាមបញ្ជាក់របស់លោកមឿនតុលា៕

# ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០២៣

## ៣ ខែ ដើមឆ្នាំនេះ ក្រសួងមហាផ្ទៃទទួលសំណើពាក់ព័ន្ធបញ្ហាជួញដូរ មនុស្សជាង ១០០ ករណី ថយចុះ ៧៨ ភាគរយ ធៀបនឹងរយៈដូចគ្នានឹងឆ្នាំមុន

https://www.postkhmer.com/national/2023-05-18-1837-250182.html សំបាន ច័ន្ទដារ៉ា | Publication date 18 May 2023 | 18:37 ICT

ភ្នំពេញៈ ត្រីមាសទី១ ដើមឆ្នាំ ២០២៣ នេះ ក្រសួងមហាផ្ទៃ និងអាជ្ញាធរពាក់ព័ន្ធទទួលបានសំណើ និងសំណូមពរពីជនរងគ្រោះពាក់ព័ន្ធករណីជួញដូរមនុស្សបានចំនួន ១២៨ សំណើដែលចំនួននៃសំណើនេះមានការថមថយចុះ ៧៨ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០២២។ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើការយ៉ាងសស្រាក់សស្រាំ ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្សជួញដូរកម្លាំងពលកម្មនិងអាជីវកម្មផ្លូវភេទក្នុងត្រីមាសដើមឆ្នាំនេះដែលធ្វើឱ្យសភាពការណ៍មានការថយចុះ។

នេះជាការលើកឡើងតាមរយៈសេចក្ដីប្រកាសលើបណ្ដាញសង្គមហ្វេសប៊ុក លោកស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣។ លោកបានឱ្យដឹងដែរថា ការថយចុះនៃសំណើ និងសំណូមពរជុំវិញអំពើជួញដូរមនុស្ស ដែលនៅត្រីមាសទី១ នៃឆ្នាំ២០២៣នេះអាជ្ញាធរទទួលសំណើត្រឹម១៣១សំណើដែលមានមនុស្សចំនួន១៩៥នាក់ (ស្រី៣១នាក់) ក្នុងនោះមានស្ទួនចំនួន៣សំណើ។ ដូចនេះ សំណើជាក់ស្ដែងមានសរុប ១២៨សំណើ បានថយចុះចំនួន ៧៨ភាគរយ បើធៀបនឹងនឹងឆ្នាំមុនដែលមានរហូត៦០៥សំណើ។

បើតាមលោក ស ខេង ក្នុងរយៈពេល៣ខែនេះ ខេត្តដែលមានសំណើច្រើនករណីជាងគេមាន ខេត្តឧត្ដរមានជ័យ ខេត្តកោះកុងកណ្ដាល និងព្រះសីហនុ។ សមត្ថកិច្ចបានស្រាវជ្រាវរកឃើញចំនួន៧៥សំណើ ស្មើនឹងមនុស្សចំនួន១៨៤នាក់ (ស្រី២០នាក់) ៧សញ្ជាតិ ដោយសមត្ថកិច្ចសង្គ្រោះបានជនរងគ្រោះចំនួន១០នាក់ ឃាត់ខ្លួន១៣នាក់។ ក្រៅពីនេះ មានសំណើចំនួន៦៧ទៀត ត្រូវបានរកឃើញថាគ្រាន់តែជាការស្នើសុំកិច្ចអន្តរាគមន៍ដើម្បីបានលាឈប់ពីការងារ និងចង់ត្រឡប់ទៅប្រទេសកំណើតវិញ។ ចំពោះសំណើចំនួន៣៣ ស្មើនឹងមនុស្សចំនួន៦៥នាក់ សមត្ថកិច្ចពុំរកឃើញក្នុងទីតាំងតាមសំណើសាមីជនទេ ខណៈសំណើដែលនៅសេសសល់ចំនួន២១ទៀត ស្មើនឹងមនុស្សចំនួន១២៦នាក់ សមត្ថកិច្ចយើងកំពុងស្រាវជ្រាវ។

លោកស ខេង សង្កត់ធ្ងន់ថា៖ «ក្នុងរយៈពេលត្រីមាសទី១ ឆ្នាំ២០២៣កន្លងទៅនេះ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើការយ៉ាងសស្រោកសស្រាំដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទដែលបានធ្វើឱ្យសភាពការណ៍មានការថយចុះគួរឱ្យកត់សម្គាល់»។ លោកបានបន្ថែមថា អាជ្ញាធរនឹងនៅបន្តពិនិត្យសំណើស្នើសុំកិច្ចអន្តរាគមន៍ខណៈបានបិទជាបណ្ដោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារស្រាវជ្រាវ ស្វែងរកតាមសំណើ ឬសំណូមពរ សំដៅធានាសុវត្ថិភាពឱ្យបានដាច់ខាតដល់ ជនបរទេសដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេតឱ្យបានហ្មត់ចត់។

យោងរបាយការណ៍ពីគណៈបញ្ជាការដឹកនាំប្រតិបត្តិការនៃក្រុមការងារអនុវត្តន៍ច្បាប់ ដឹកនាំដោយលោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានឱ្យដឹងថា ក្នុងចំណោម១២៨សំណើនោះ មានជនបរទេស៣៧៥នាក់ (ស្រី៣១នាក់) ស្មើ១០សញ្ជាតិក្នុងនោះសញ្ជាតិបរទេសរួមមាន ចិន ថៃ បង់ក្លាដែស ប៉ាគីស្ថានម៉ាឡេស៊ី វៀតណាម ហ្វីលីពីន ឥណ្ឌា និងឥណ្ឌូនេស៊ី។

ពាក់ព័ន្ធនឹងបញ្ហានេះ លោកស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក បានប្រាប់ថាទោះបីមានការថមថយចុះនៃចំនួនស្នើសុំកិច្ចអន្តរាគមន៍នេះក្តី ប៉ុន្តែចំនួន ១២៨សំណើក្នុងរយៈពេល៣ខែ នៅតែជាចំនួនច្រើនដដែល ហើយដែលអាចកើនច្រើននៅត្រីមាសក្រោយៗ។ លោកបន្តថា រដ្ឋាភិបាលត្រូវតែផ្ទៀងផ្ទាត់វិធានការឱ្យមានម៉ឺងម៉ាត់បន្ថែមទៀត ដើម្បីអាចឆ្លើយតបបានសមស្របចំពោះបទល្មើសជួញដូរមនុស្សនៅកម្ពុជា ដែលសហគមន៍អន្តរជាតិ និងរដ្ឋាភិបាលផ្ទាល់បានសម្តែងការព្រួយបារម្ភ។ លោក ស៊ឹង សែនករុណា បានបញ្ជាក់ថា៖«យើងក៏បានទទួលករណីជួញដូរមនុស្សនេះច្រើនដែរ ក្នុងរយៈពេលកន្លងទៅនេះ ហើយខាងរដ្ឋាភិបាលក៏បង្ហាញពីករណីដែលនៅបន្តកើតមានឡើងផងដែរ ដែលនេះសបញ្ជាក់ថា ទោះបីយើងមានវិធានការពីសមត្ថកិច្ចបានមួយចំនួនផងដែរក៏វិធានការទាំងនោះ ដូចជាមិនទាន់បានទប់ស្កាត់និងបន្ថយបានច្រើននៅឡើយទេ»។

សូមជម្រាបថា កាលពីខែកក្កដា ឆ្នាំ២០២២កន្លងទៅ កម្ពុជាត្រូវបានដាក់ចូលក្នុងបញ្ជីក្រហម ឬចំណាត់ថ្នាក់កម្រិតទី៣ ក្នុងរបាយការណ៍ជួញដូរមនុស្សប្រចាំឆ្នាំ២០២២ របស់សហរដ្ឋអាមេរិក បន្ទាប់ពីការទប់ស្កាត់បទល្មើសជួញដូរមនុស្សមិនទាន់មានប្រសិទ្ធភាព៕

## សូមប្រុងប្រយ័ត្នកូនចៅ! មកស្តាប់ក្មេងៗដែលរត់រួចពីក្រញាំស្ត្រីម្នាក់ប៉ងចាប់ពង្រត់ចេញពីភូមិ

https://kohsantepheapdaily.com.kh/article/1739651.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បាត់ដំបង១៩ ខែ ឧសភា ឆ្នាំ ២០២៣ ម៉ោង ០៩:២២

ខេត្តបាត់ដំបង ៖ មន្ត្រីរដ្ឋបាលស្រុកមោងឫស្សី រួមទាំងមន្ត្រីមូលដ្ឋានផង កាលពីថ្ងៃទី១៧ ឧសភា បានចុះទៅសួរនាំ និងសួរសុខទុក្ខក្មេងប្រុសម្នាក់ និងក្មេងស្រីចំនួន០២នាក់ នៅភូមិរុណ ឃុំគារ ស្រុកមោងឫស្សី ដែលត្រូវស្ត្រីមិនស្គាល់អត្តសញ្ញាណម្នាក់ចាប់ពង្រត់ចេញពីភូមិដឹកតាមម៉ូតូយកទៅរហូតដល់ទឹកដីខេត្តពោធិ៍សាត់ ទើបពួកគេប្រើល្បិចរត់រួចត្រឡប់មកផ្ទះវិញ ។

លោក បឿន សុវណ្ណ អភិបាលរងស្រុកមោងឫស្សីបានឲ្យដឹងថា តាមពិត រឿងរ៉ាវស្ត្រីម្នាក់ចាប់ពង្រត់កុមារា-កុមារី ទាំង០៣នាក់ខាងលើនេះ បានកើតឡើងតាំងពីសប្តាហ៍មុន តែអាជ្ញាធរស្រុកទើបទទួលបានរបាយការណ៍នេះពីមូលដ្ឋាននៅថ្ងៃទី១៧ ឧសភា ទើបលោកអភិបាលស្រុកបញ្ជាឲ្យសហការីចុះទៅសួរនាំអំពីរឿងរ៉ាវនេះ ដល់លំនៅឋានកុមាររងគ្រោះតែម្តង ។ លោកអភិបាលរងបានបញ្ជាក់ដែរថា កុមាររងគ្រោះដែលមានអាយុត្រឹម១០ឆ្នាំទាំង០៣នាក់ នោះត្រូវបានស្ត្រីមិនស្គាល់អត្តសញ្ញាណម្នាក់ចាប់ពង្រត់ចេញពីក្នុងមូលដ្ឋានដឹកតាមម៉ូតូរហូតដល់ស្រុកបាកាន ខេត្តពោធិ៍សាត់ ទើបស្ត្រីនោះទម្លាក់ពួកគេទាំង០៣នាក់ ដោយសារតែក្មេងៗស្រែកនៅលើម៉ូតូឲ្យអ្នកភូមិជួយអន្តរាគមន៍ ហើយស្ត្រីនោះក៏ជិះម៉ូតូគេចខ្លួនបាត់ស្រមិលទៅ ។

យោងតាមរបាយការណ៍មន្ត្រីមូលដ្ឋានបានឲ្យដឹងថា ហេតុការណ៍នេះបានកើតឡើងកាលពីរសៀលថ្ងៃទី១១ ឧសភា នៅចំណុចវាលស្រែមួយកន្លែង ក្នុងភូមិព្រៃតាពៅ ឃុំគារ ស្រុកមោងឫស្សី បង្កឡើងដោយស្ត្រីម្នាក់ដែលគេមិនស្គាល់ភិនភាគ ឬអត្តសញ្ញាណ ។ ស្ត្រីនោះ បានជិះម៉ូតូទៅឈប់លួងលោមពួកក្មេងៗមួយក្រុមដែលកំពុងអង្គុយជុំគ្នា។ ប៉ុន្តែល្បួងបានប្រុសម្នាក់ និងក្មេងស្រី០២នាក់ឲ្យឡើងជិះម៉ូតូទៅជាមួយខ្លួន ។ ស្ត្រីនោះបានដឹកពួកគេចេញពីមូលដ្ឋាន ឆ្ពោះទៅទិសខាងកើត ឆ្លងព្រំប្រទល់ខេត្តបាត់ដំបង រហូតដល់ទឹកដី ឃុំបឹងខ្នា ស្រុកបាកាន ខេត្តពោធិ៍សាត់ឃើញសភាពមិនស្រួល ដោយសារក្មេងរងគ្រោះទាំង០៣នាក់ ចេះតែស្រែកពេក ពេលជិះនៅលើម៉ូតូឲ្យអ្នកភូមិជួយ ទើបស្ត្រីម្នាក់នោះឈប់ម៉ូតូទម្លាក់ពួកគេទាំង០៣នាក់នោះចោល ហើយជិះគេចខ្លួនបាត់ស្រមោល

ភ្លាមៗតែម្តង។ កុមាររងគ្រោះទាំង០៣នាក់នោះមាន ១-ឈ្មោះ រ៉េន លៀងអេង ស្រីអាយុ៨ឆ្នាំ ២-ឈ្មោះ ឡឿន សុផាន់ណា ស្រីអាយុ៩ឆ្នាំ និង៣-ឈ្មោះ សំ សុភីន ប្រុសអាយុ១០ឆ្នាំ ពួកគេរស់នៅភូមិរុណ ឃុំគារ ស្រុកមោងឫស្សី។

បើតាមមន្ត្រីមូលដ្ឋាន ដែលបានស្រង់សំដីកុមារទាំង០៣នាក់បានរៀបរាប់ថា ពួកគេមិនធ្លាប់ស្គាល់ស្ត្រីបិសាចម្នាក់នោះទេ។ ដំបូងពួកខ្លួនមានគ្នា០៥នាក់នៅអង្គុយលេងជុំគ្នា ហើយពេលនោះក៏ឃើញស្ត្រីម្នាក់នោះជិះម៉ូតូមកដល់ ក៏សួរនាំ និងពឹងពាក់សុំឲ្យពួកខ្លួនជូនទៅបេះស្តៅព្រោះគាត់ប្រាប់ថា គាត់មិនស្គាល់ដើមស្តៅទេ ។ មន្ត្រីបានស្រង់សំដីក្មេងរងគ្រោះទៀតថា ក្រោយសួរនាំចប់ ស្ត្រីរូបនោះក៏ឲ្យពួកគេឡើងជិះម៉ូតូដើម្បីនាំទៅរកដើមស្តៅ តែដោយសារម៉ូតូជិះបានត្រឹម០៣នាក់ ទើបដឹកពួកខ្លួន០៣នាក់ចេញទៅ តែស្ត្រីបិសាចនោះគិតតែជិះរហូតមិនព្រមឈប់ បើទោះជាពួកគេប្រាប់ឲ្យឈប់ក្តី ។ ប៉ុន្តែក្រោយពីជិះចេញឆ្ងាយពីភូមិ ស្ត្រីនោះបានឈប់ រួចសុំដោះកងដៃ និងក្រវិលពីពួកគេ តែដោះកងដៃបានម្នាក់ដែរ ហើយក៏ឡើងជិះម៉ូតូបន្តទៅទៀត ។ រហូតដល់ទឹកដីខេត្តពោធិ៍សាត់ ពួកនាងគិតថា សភាពមិនល្អ ក៏ជិះបណ្តើរស្រែកហៅឲ្យអ្នកភូមិជួយបណ្តើរ រហូតដល់ចំណុចទឹកដី ឃុំបឹងខ្នា ស្រុកបាកាន។

ដោយឃើញពួកក្មេងៗទាំងនោះស្រែកខ្លាំងពេក ស្ត្រីទុច្ចរិតនោះក៏ឈប់ម៉ូតូទម្លាក់ពួកក្មេងៗទាំង០៣នាក់ចោលទៅនោះតែម្តងទៅ ។ ក្មេងស្រីម្នាក់បាននិយាយថា ពេលត្រូវស្ត្រីបិសាចទម្លាក់ពួកនាងចោលតាមផ្លូវ ពួកនាងក៏ដើរតាមផ្លូវរថភ្លើង ក្នុងគោលបំណងត្រឡប់មករកផ្ទះនៅស្រុកមោងឫស្សីវិញ ដែលមានចម្ងាយរាប់សិបគីឡូម៉ែត្រ ។ នាងនិយាយថា ពេលនាំគ្នាដើរក៏ជួបអ្នកភូមិ ហើយពួកនាងបានរៀបរាប់ប្រាប់ពីដំណើររឿងមានគេចាប់ពង្រត់ពួកនាងដឹកតាមម៉ូតូ ទើបអ្នកភូមិទូរស័ព្ទទំនាក់ទំនង តាមលេខដែលនាងប្រាប់ ដើម្បីហៅជីតានាងឲ្យទៅទទួលយកពួកនាង នៅចំណុចខាងលើ ។ គេមិនដឹងថា តើស្ត្រីមិនស្គាល់អត្តសញ្ញាណ ដែលចាប់ពង្រត់កុមាររងគ្រោះទាំង០៣នាក់នោះ ក្នុងគោលបំណងអ្វីឲ្យប្រាកដទេ? ឬក៏ស្ត្រីបិសាចនោះចាប់កុមារទាំងនោះយកទៅលក់ក៏គេមិនដឹងដែរ ? ឬក្នុងគោលបំណង់ទុច្ចរិតអ្វីផ្សេង? ឬស្ត្រីម្នាក់នេះ ចង់ដោះយកគ្រឿងអលង្ការដែលពួកនាងមានបន្តិចបន្តួចពាក់ជាប់ខ្លួន? រហូតមកដល់ពេលនេះ គេនៅមិនទាន់ដឹងពីមូលហេតុច្បាស់លាស់ នៃការចាប់ពង្រត់ក្មេងប្រុស ស្រីទាំង០៣នាក់ខាងលើនេះនៅឡើយទេ។ ហើយក៏មិនដឹងថា តើសមត្ថកិច្ចបានធ្វើការស៊ើបអង្កេតលើសំណុំរឿងនេះដែរ ឬយ៉ាងណានោះទេ ? បើតាមព័ត៌មាន ទំនងគ្មានសមត្ថកិច្ចក្នុងស្ថាប័នណាមួយខ្វល់ខ្វាយពីរឿងនេះឡើយ។

កោះសន្តិភាព បានព្យាយាមសុំការបំភ្លឺចំពោះករណី «ចាប់ពង្រត់ក្មេងប្រុស ស្រី០៣នាក់» ខាងលើនេះពីលោក ស គឹមឡុង អធិការស្រុកមោងឫស្សី តាមទូរស័ព្ទច្រើនលើកច្រើនសារ នៅថ្ងៃទី១៨ ឧសភា តែលោកអធិការរូបនេះមិនលើកទូរស័ព្ទឡើយ ហើយរហូតមកដល់ត្រឹមម៉ោង៤រសៀលថ្ងៃដដែលនេះ ក៏គ្មានការឆ្លើយតបពីលោកអធិការរូបនេះដែរ ។ ដោយឡែក លោក ហឿន សុវណ្ណ អភិបាលរងស្រុកមោងឫស្សីបានបញ្ជាក់ថា ក្រុមការងារនៃរដ្ឋបាលស្រុកមោង ឫស្សី រួមជាមួយមន្ត្រីមូលដ្ឋានផង បានចុះទៅជួបសួរនាំផ្ទាល់ជាមួយអាណាព្យាបាលកុមាររងគ្រោះទាំងអស់ រួមទាំងក្មេងប្រុសស្រីដែលរងគ្រោះទាំង០៣នាក់នោះផង។ លោកបានបញ្ជាក់បន្ថែមថា នៅពេលចុះជួបសួរសុខទុក្ខ រដ្ឋបាលស្រុកក៏បានផ្តល់ជូននូវថវិកា និងអំណោយបន្តិចបន្តួចជួយដល់កុមាររងគ្រោះទាំង០៣នាក់ផងដែរ ជាមួយនឹងការការអំពាវនាវរបស់លោកអភិបាលស្រុក សូមឲ្យអាណាព្យាបាលនានា ឬកុមារតូចៗនៅគ្រប់ទីកន្លែងក្នុងមូលដ្ឋាន ត្រូវមានប្រុងប្រយ័ត្នចំពោះកូនៗតូចៗរបស់ខ្លួន។ ប្រសិនជាជួបនូវមនុស្សដែលគួរឲ្យសង្ស័យត្រូវរាយការណ៍ភ្លាមៗ ទៅកាន់សមត្ថកិច្ចឬអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុត ដើម្បីសុំឲ្យជួយពិនិត្យនិងអន្តរាគមន៍ទៅលើមុខសញ្ញានោះ ។

# ថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០២៣

## ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ សមត្ថកិច្ចសង្គ្រោះជនរងគ្រោះ ១០នាក់ និងឃាត់ខ្លួន ១៣នាក់ ក្នុងបទល្មើសជួញដូរមនុស្ស

https://www.information.gov.kh/articles/105284 AKP ភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហា ផ្ទៃបានគូសបញ្ជាក់ថា ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ សមត្ថកិច្ចស្រាវជ្រាវរកឃើញបទល្មើសប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ចំនួន ៧៥សំណើ សង្គ្រោះ បានជនរងគ្រោះចំនួន ១០នាក់ ព្រមទាំងឃាត់ខ្លួន ១៣នាក់ផងដែរ។

យោងតាមរយៈគេហទំព័រហ្វេសប៊ុកផ្លូវការរបស់សម្តេចក្រឡាហោមសខេងនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២៣ សម្តេចក្រឡាហោម ស ខេង បានលើកឡើងអំពីលទ្ធផល នៃការអនុវត្តផែនការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្នុងត្រីមាសទី១ ឆ្នាំ២០២៣។ សម្តេចក្រឡាហោមបញ្ជាក់ថាក្នុងរយៈពេល ៣ខែនេះ មានអ្នកដាក់សំណើ និងសំណូមពរ មកហ្វេស ប៊ុកផេកសម្តេច និងប្រភពផ្សេងៗចំណុះក្រសួងមហាផ្ទៃ ចំនួន ១៣១សំណើ ត្រូវជាមនុស្ស ចំនួន១៩៥នាក់ ក្នុងនោះមានស្ទួនចំនួន ៣សំណើ។ ដូច្នេះសរុបសំណើរជាក់ស្តែងមានចំនួន ១២៨សំណើ។

បើតាមរបាយការណ៍ពីគណៈបញ្ជាការដឹកនាំប្រតិបត្តិការនៃក្រុមការងារអនុវត្តន៍ច្បាប់ ដឹកនាំដោយ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងថា ក្នុងចំណោម ១២៨សំណើនោះ មានជនបរទេស ៣៧៥នាក់ (ស្រី៣១នាក់)ស្មើ១០ សញ្ជាតិ ក្នុងនោះសញ្ជាតិបរទេស រួមមាន ចិន ថៃ បង់ក្លាដេស ប៉ាគីស្ថាន ម៉ាឡេស៊ី វៀតណាម ហ្វីលីពីន ឥណ្ឌា និងឥណ្ឌូណេស៊ី។ សម្តេចក្រឡាហោមគូសបញ្ជាក់ទៀតថា៖ «ជាលទ្ធផល ក្នុងចំណម ១២៨សំណើនោះ សមត្ថកិច្ចយើង បានស្រាវជ្រាវរកឃើញ ចំនួន ៧៥សំណើ ស្មើនឹងមនុស្ស ចំនួន ១៨៤នាក់ (ស្រី២០នាក់) ៧សញ្ជាតិ ដោយសមត្ថកិច្ចសង្គ្រោះបានជនរងគ្រោះ ចំនួន ១០នាក់ ឃាត់ខ្លួន១៣នាក់។ ក្រៅពីនេះ មានសំណើចំនួន ៦៧ទៀត ត្រូវបានរកឃើញថាគ្រាន់តែជាការស្នើសុំកិច្ចអន្តរាគមន៍ ដើម្បីបានលាឈប់ពីការងារ និងចង់ត្រឡប់ទៅប្រទេសកំណើតវិញ។ ចំពោះសំណើចំនួន៣៣ ស្មើនឹងមនុស្សចំនួន៦៥នាក់ សមត្ថកិច្ចពុំរកឃើញក្នុងទីតាំងតាមសំណើសាមីជនទេ ខណៈសំ ណើដែលនៅសេសសល់ចំនួន ២១ទៀត ស្មើនឹងមនុស្ស ចំនួន ១២៦នាក់ (ស្រី២នាក់) សមត្ថកិច្ចយើងកំពុងស្រាវជ្រាវ»។

សម្តេចក្រឡាហោមបន្តថា ក្នុងរយៈពេលត្រីមាសទី១ ឆ្នាំ២០២៣កន្លងទៅនេះ សម ត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើការយ៉ាងសស្រាក់សស្រាំដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទដែលបានធ្វើឱ្យសភាពការណ៍ មានការថយចុះគួរឱ្យកត់សម្គាល់។ ជាក់ស្តែង បើធៀបនឹងរយៈពេលដូចគ្នាចាប់ពីពេលចាប់ផ្តើមទទួលសំណើ យើងពិនិត្យឃើញថា សំណើសុំកិច្ចអន្តរាគមន៍ បានថយចុះ ៧៨ភាគរយ ពោលគឺពី៦០៥ មកនៅត្រឹ ម១២៨សំណើ។

ក្នុងរយៈពេល ៣ខែ ឆ្នាំ២០២៣នេះ តាមការកត់សម្គាល់ឃើញថាខេត្តឧត្តរមានជ័យ ខេត្តកោះ កុងកណ្តាល និងព្រះសីហនុ មានសំណើច្រើនករណី។ សម្តេចក្រឡាហោម សូមបញ្ជាក់ជូនថា អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា នៅតែបន្តជំរុញសកម្មភាពក្នុងការត្រួតពិនិត្យ និងបង្ក្រាបទីតាំងអាជីវកម្ម ក្នុងករណីមានសំណើ ឬមានព័ត៌មានជាក់លាក់ពាក់ព័ន្ធទៅនឹងបទល្មើស ការបង្ខាំងមនុស្ស ការរឹតត្បិតសេរីភាព ការធ្វើទារុណកម្ម

អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការលួច លាក់បើ កអាជីវកម្មល្បែង ស៊ីសងខុសច្បាប់គ្រប់ប្រភេទ ព្រមទាំងស្រាវជ្រាវរកជនល្មើស ដើម្បីផ្ត ន្ទាទោសតាមច្បាប់។

សម្តេចក្រឡាហោម ស ខេង បានអះអាងដែរថា៖ «យើងនឹងបន្តពិនិត្យ លើសំណើសុំអន្តរាគមន៍ដែលត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារ ស្រាវជ្រាវ ស្វែងរកតាមសំណើ ឬសំណូមពរ សំដៅធានាសុវត្ថិភាពឱ្យបានដាច់ខាតដល់ ជនបរ ទេសដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងចាត់វិធានការ ឱ្យបានម៉ឺងម៉ាត់ចំពោះជនបរទេសដែលប្ដឹងបំប៉ោងព័ត៌មាន ឬបំពុលបរិយាកាសសង្គម ដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន៕ដោយ៖ ចាន់ សុធីវង្ស សម្រួលផ្សាយដោយ៖ ធូ កុសល

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៦នាក់

https://freshnewsasia.com/index.php/en/localnews/292078-2023-05-19-13-26-12.html 2023-05-19 08:26pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៦នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៨៥ករណី មានមនុស្ស ២,២១០នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥២សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,២៦៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី៕

## ឯកអគ្គរាជទូតកម្ពុជាស្នើភាគីជប៉ុនផ្តល់សេវាគាំពារដល់ពលករខ្មែរ

https://www.kampucheathmey.com/local-news/514061 ថ្ងៃសៅរ៍ ២០ ឧសភា ២០២៣ដោយ Thoeun Vansong

ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន លោក ទុយ រី បានស្នើអាជ្ញាធរខេត្តតូយ៉ាម៉ាផ្តល់សេវាគាំពារដល់កម្មសិក្សាការី និងពលករជំនាញកម្ពុជាដែលកំពុងបម្រើការនៅខេត្តនេះរបស់ប្រទេសជប៉ុន។ លោកឯកអគ្គរាជទូតស្នើបែបនេះក្នុងជំនួបជាមួយលោកអភិបាលខេត្តតូយ៉ាម៉ា កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

តាមរយៈការបង្ហោះនៅលើបណ្តាញសង្គមហ្វេសប៊ុករបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅជប៉ុន បានឲ្យដឹងថា «នៅថ្ងៃទី១៨ និងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ លោក ទុយ រី ឯកអគ្គរាជទូតកម្ពុជា និងសហការី បានជួបពិភាក្សាជាមួយលោក Hachiro Nitta អភិបាលខេត្តតូយ៉ាម៉ា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងខេត្តតូយ៉ាម៉ា និងស្ថានទូតកម្ពុជាឲ្យកាន់តែរលូនបន្ថែមទៀត។ ក្នុងជំនួបនោះ លោក ទុយ រី បានជំរុញ និងលើកទឹកចិត្តដល់ក្រុមហ៊ុនជប៉ុនឲ្យសិក្សាពីការវិនិយោគនៅកម្ពុជា ក៏ដូចជាការលើកទឹកចិត្តដល់បណ្តាក្រុមហ៊ុនជប៉ុនដែលមានតម្រូវការ

កម្លាំងពលកម្មជនបរទេស គឺធ្វើការជ្រើសរើសកម្មសិក្សាការី និងពលករជំនាញរបស់កម្ពុជាឲ្យបានកាន់តែច្រើនថែមទៀត។ លោកឯកអគ្គរាជទូត បានលើកឡើងថា ប្រទេសកម្ពុជា គឺជាប្រទេសដែលមានកម្លាំងពលកម្មវ័យក្មេងច្រើននៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ លើសពីនេះ លោកឯកអគ្គរាជទូត ក៏បានស្នើសុំដល់លោកអភិបាលខេត្តតូយ៉ាម៉ា និងអាជ្ញាធរពាក់ព័ន្ធបន្តជួយផ្តល់សេវាគាំពារដល់កម្មសិក្សាការី និងពលករជំនាញខ្មែរនៅក្នុងខេត្ត ដែលបច្ចុប្បន្នមានប្រមាណ២០០នាក់។

ដោយឡែក លោក ទុយ រី ក៏បានជួបសំណេះសំណាលដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនជប៉ុនផងដែរ ដោយលោកបានលើកទឹកចិត្ត និងពន្យល់ពីគោលនយោបាយគាំពាររបស់រាជរដ្ឋាភិបាលកម្ពុជាដល់វិនិយោគិនបរទេស និងច្បាប់វិនិយោគថ្មីរបស់កម្ពុជា ព្រមជាមួយនឹងការស្នើសុំជ្រើសរើសកម្លាំងខ្មែរមកធ្វើការនៅតាមរោងចក្រសហគ្រាសរបស់ជប៉ុន។ ទន្ទឹមនេះ លោកក៏បានចុះជួបសំណេះសំណាលជាមួយកម្មសិក្សាការីខ្មែរ និងបានស្នើសុំដល់ថ្នាក់ដឹកនាំក្រុមហ៊ុនផ្តល់ការយកចិត្តទុកដាក់ដល់កម្មសិក្សាការីខ្មែរប្រកបដោយក្តីស្រឡាញ់ និងអធ្យាស្រ័យ។

ឆ្លៀតក្នុងឱកាសនោះដែរ លោក ទុយ រី ក្នុងនាមឯកអគ្គរាជទូតកម្ពុជា ក៏បានចូលរួមកម្មវិធីគម្រប់ខួបលើកទី៤០ នៃការបង្កើតសមាគមមិត្តភាពតូយ៉ាម៉ា-កម្ពុជា នៅខេត្តតូយ៉ាម៉ា ផងដែរ។ សមាគមនេះបានចូលរួមអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា និងវប្បធម៌ខ្មែរដល់ប្រទេសជប៉ុន ក៏ប៉ុន្តែត្រូវបានផ្អាកសកម្មភាពរបស់ខ្លួនមួយរយៈ ដោយសារកោរីករាលជំងឺឆ្លង កូវីដ១៩។ លោក បានថ្លែងអំណរគុណដល់សមាគមដែលបានចំណាយកម្លាំងពេលវេលា និងថវិកានៅក្នុងសកម្មភាពមនុស្សធម៌នៅកម្ពុជា និងស្នើសមាគមពង្រីកវិសាលភាពនៅតាមខេត្តក្រុងរបស់កម្ពុជាដែលមិនទាន់មានគម្រោងនេះផងដែរ៕

## ស្ថានទូតកម្ពុជាលើកទឹកចិត្តដល់ក្រុមហ៊ុនជប៉ុន ជ្រើសរើសកម្មសិក្សាការី និងពលករជំនាញខ្មែរឱ្យកាន់តែច្រើន

https://www.postkhmer.com/national/2023-05-20-0750-250254.html រី សុចាន់ | Publication date 20 May 2023 | 14:50 ICT

**ភ្នំពេញៈ** ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុនលើកទឹកចិត្តដល់ក្រុមហ៊ុនជប៉ុន ដែលមានតម្រូវការកម្លាំងពលកម្មជនបរទេសធ្វើការជ្រើសរើសកម្មសិក្សាការី និងពលករជំនាញខ្មែរឱ្យកាន់តែច្រើន ដោយបញ្ជាក់ថា កម្ពុជាជាប្រទេស ដែលមានកម្លាំងពលកម្មវ័យក្មេងនៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន។

ការជំរុញលើកទឹកចិត្តនេះធ្វើឡើងក្នុងពិធីសំណេះសំណាល នាថ្ងៃទី១៨-១៩ ខែឧសភា រវាងលោក ទុយ រី ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងមន្ត្រីស្ថានទូត ជាមួយលោក Hachiro Nitta អភិបាលខេត្តតូយ៉ាម៉ា និងលោក Hirohisa Fujii អភិបាលក្រុងតូយ៉ាម៉ា ប្រទេសជប៉ុន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងខេត្តតូយ៉ាម៉ា និងស្ថានទូតឱ្យកាន់តែរលូន។ ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុនបញ្ជាក់ក្នុងហ្វេសប៊ុកនាថ្ងៃទី២០ ខែឧសភា ថា៖ «ឯកឧត្តម ទុយ រី ឯកអគ្គរាជទូតកម្ពុជា បានស្នើសុំជំរុញ និងលើកទឹកចិត្តដល់ក្រុមហ៊ុនជប៉ុនឱ្យសិក្សាពីការវិនិយោគនៅកម្ពុជា ការលើកទឹកចិត្តដល់បណ្តាក្រុមហ៊ុនជប៉ុនដែលមានតម្រូវការកម្លាំងពលកម្មជនបរទេសធ្វើការជ្រើសរើសកម្មសិក្សាការី និងពលករជំនាញខ្មែរឱ្យកាន់តែច្រើន ក្នុងខណៈដែលប្រទេសកម្ពុជាជាប្រទេសដែលមានកម្លាំងពលកម្មវ័យក្មេងនៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន»។ លោកក៏បានស្នើដល់លោក Hachiro Nitta និងអាជ្ញាធរពាក់ព័ន្ធផ្តល់សេវាគាំពារដល់កម្មសិក្សាការី និងពលករជំនាញខ្មែរនៅក្នុងខេត្តនេះ ដែលបច្ចុប្បន្នមានប្រមាណ ២០០ នាក់។

លោក ទុយ រី ក៏បានចូលរួមកម្មវិធីគម្រប់ខួបលើកទី៤០ នៃការបង្កើតសមាគមមិត្តភាព តូយ៉ាម៉ា-កម្ពុជា នៅខេត្តតូយ៉ាម៉ា ជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមនេះ។ ហ្វេសប៊ុកដដែលបន្តថា សមាគមនេះបានចូលរួមអភិវ

ឃ្លាន់ធនធានមនុស្សនៅកម្ពុជា និងវប្បធម៌ខ្មែរដល់ប្រទេសជប៉ុន ក៏ប៉ុន្តែបានផ្អាកសកម្មភាពរបស់ខ្លួនមួយរយៈដោយសារការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩។ លោក ទុយ រី បានថ្លែងអំណរគុណដល់សមាគមនេះដែលបានចំណាយកម្លាំង ពេលវេលា និងថវិកានៅក្នុងសកម្មភាពមនុស្សធម៌នៅកម្ពុជា និងស្នើឱ្យសមាគមនេះពង្រីកវិសាលភាពនៅតាមខេត្ត ក្រុង ដែលមិនទាន់មានគម្រោងពីមុនមក។ ហ្វេសប៊ុកដដែលបន្តថា៖ «ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមលោក ទុយ រី បានជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនជប៉ុនក្នុងគោលបំណងលើកទឹកចិត្ត និងពន្យល់ពីគោលនយោបាយគាំពាររបស់រាជរដ្ឋាភិបាលកម្ពុជាដល់វិនិយោគិនបរទេស និងច្បាប់វិនិយោគថ្មីរបស់កម្ពុជា ព្រមជាមួយនឹងការស្នើសុំជ្រើសរើសកម្លាំង [ពលកម្ម] ខ្មែរមកធ្វើការនៅតាមរោងចក្រសហគ្រាសរបស់ខ្លួន»។

លោក ទុយ រី ក៏បានចុះជួបសំណេះសំណាលជាមួយកម្មសិក្សាការីខ្មែរដែលធ្វើការនៅរោងចក្រផលិតសម្ភារប្លាស្ទិករបស់ក្រុមហ៊ុន Hanshin Group Co., Ltd និងស្នើសុំដល់ថ្នាក់ដឹកនាំក្រុមហ៊ុននេះផ្តល់ការយកចិត្តទុកដាក់ដល់កម្មសិក្សាការីខ្មែរប្រកបដោយក្តីស្រឡាញ់ និងអធ្យាស្រ័យ។ បើតាមហ្វេសប៊ុកដដែល បច្ចុប្បន្ន ក្រុមហ៊ុននេះមានកម្មសិក្សាការីខ្មែរចំនួន ៧០ នាក់ ធ្វើការនៅតាមសាខារោងចក្ររបស់ខ្លួន និងបន្តជ្រើសរើសបន្ថែមនាពេលខាងមុខ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤នាក់

https://freshnewsasia.com/index.php/en/localnews/292168-2023-05-21-01-25-52.html 2023-05-21 08:25am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៨៩ករណី មានមនុស្ស ២,២១៤នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥២សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,២៦៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១១៤ករណី៕

# ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០២៣

## នាយឧត្តមសេនីយ៍ ខៀវ សុភ័គ ៖ សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្ដឹង ៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៦នាក់

http://nokorwatnews.com/archives/1002318 21/05/2023

ភ្នំពេញ៖ បើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានថ្លែងថា សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៦នាក់ ,នេះបើគិតចាប់ពីម៉ោង ៣៖០០នាទី នាថ្ងៃទី១៨ ដល់វេលាម៉ោង ៣៖០០នាទី ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ម្សិលមិញនេះ។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានថ្លែងបញ្ជាក់ថា៖ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៨៨៥ករណី មានមនុស្ស ២,២១០នាក់។

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥២សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,២៦៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី៕ **ដោយ៖ សហការី**

## ស្ត្រីជនជាតិហ្វីលីពីនដែលបានក្លែងបន្លំឯកសារអាពាហ៍ពិពាហ៍ជាមួយជនជាតិចិនត្រូវបានហាមឃាត់មិនឲ្យចាកចេញមកកម្ពុជា

https://www.khmertimeskh.com/501294100/ May 21, 2023

ការិយាល័យអន្តោប្រវេសន៍បាននិយាយកាលពីថ្ងៃសុក្រថា ស្ត្រីជនជាតិហ្វីលីពីនម្នាក់ត្រូវបានហាមឃាត់មិនឱ្យចាកចេញពីប្រទេស នៅពេលដែលអាជ្ញាធរបានរកឃើញថា នាងបានក្លែងបន្លំឯកសារអាពាហ៍ពិពាហ៍របស់នាងជាមួយជនជាតិចិនដែលរស់នៅកម្ពុជា។ ស្ត្រីជនជាតិហ្វីលីពីនដែលត្រូវបានគេសង្ស័យថាជាជនរងគ្រោះនៃការជួញដូរត្រូវបានមន្ត្រីអន្តោប្រវេសន៍ហាមឃាត់មិនឱ្យឡើងយន្តហោះកាលពីថ្ងៃទី១ ខែឧសភា នៅអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino "បន្ទាប់ពីនាងបានបង្ហាញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ដ៏គួរឱ្យសង្ស័យ" ។ ក្រៅពីភាពមិនស្របគ្នា និងមាន"ភាពមិនស៊ីសង្វាក់គ្នាជាច្រើន" ដែលបានរកឃើញនៅក្នុងឯកសាររបស់នាង។

យោងតាមការិយាល័យអន្តោប្រវេសន៍បានឱ្យដឹងថា ស្ត្រីជនជាតិហ្វីលីពីន ដែលមិនបញ្ចេញឈ្មោះរូបនេះបានជួលគេអោយរៀបចំឯកសារធ្វើដំណើររបស់នាង និងបានបង់ប្រាក់ចំនួន ៣៥,០០០ ប៉េសូ ដែលចេញដោយប្ដីក្លែងក្លាយរបស់នាង។ តាមការត្រួតពិនិត្យកំណត់ត្រាធ្វើដំណើររបស់ប្ដីក្លែងក្លាយនាងបានបង្ហាញថាជននេះត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសហ្វីលីពីនដោយមន្ត្រីអន្តោប្រវេសន៍នៅអាកាសយានដ្ឋាន NAIA កាលពីខែកញ្ញាឆ្នាំមុនដោយផ្អែកលើហេតុផលថាជននេះអាចនឹងត្រូវវងការពិន័យជាសាធារណៈ" ។ លិខិតបញ្ជាក់អាពាហ៍ពិពាហ៍បានបង្ហាញអោយដឹងថា អាពាហ៍ពិពាហ៍របស់ពួកគេបានធ្វើឡើងនៅក្នុងខែតុលាឆ្នាំមុន ឬមួយខែបន្ទាប់ពីប្ដីក្លែងក្លាយរូបនេះត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសហ្វីលីពីន"។ ស្នងការអន្តោប្រវេសន៍លោក Norman Tansingco បាននិយាយថា ការប្រើប្រាស់ឯកសារអាពាហ៍ពិពាហ៍ក្លែងក្លាយ ដើម្បីគេចពីការត្រួតពិនិត្យគឺជា "ល្បិចចាស់ដែលមិនមានប្រសិទ្ធភាពទៀតនោះទេ" ។ ABS-CBN News

## សមត្ថកិច្ចបញ្ជាក់ថា ការផ្សព្វផ្សាយព័ត៌មានអំពីការចាប់ក្មេងៗជាព័ត៌មានក្លែងក្លាយបង្កើតឡើងដោយក្រុមជនអាក្រក់

https://www.btv.com.kh/article/23586 2023/05/21 07:55:48 pm

ភ្នំពេញ៖ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃក្រសួងមហាផ្ទៃ នាយប់ថ្ងៃទី២១ ខែឧសភានេះបាន បញ្ជាក់ថា ការផ្សព្វផ្សាយនៅលើគេហទំព័រហ្វេសប៊ុកមួយចំនួននាពេលថ្មីៗនេះថា មានករណីចាប់ក្មេង ឬការចាប់ក្មេងវះក្រលៀន ជាព័ត៌មានមិនពិត បង្កើតឡើងដោយក្រុមជនអាក្រក់ ប្រឆាំងរាជរដ្ឋាភិបាល មានបំណងបំពុលសង្គម។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានជម្រាបជូនសាធារណជនជ្រាបថានាពេលកន្លងទៅនេះ ទំព័រហ្វេសប៊ុកឈ្មោះ "អនុរក្ស", "កាមទេពលឹមហុង" និងគណនីហ្វេសប៊ុកមួយចំនួន បានចុះផ្សាយព័ត៌មានអំពីការចាប់ក្មេង ឬការចាប់ក្មេងវះក្រលៀន ។

«បន្ទាប់ពីទទួលព័ត៌មានខាងលើនេះ នាយកដ្ឋានបានចាត់មន្ត្រីជំនាញធ្វើការស្រាវជ្រាវបន្ទាន់ ជាលទ្ធផលកំណត់បានថា ព័ត៌មានទាំងនេះ ជាព័ត៌មានក្លែងក្លាយ ដែលបង្កើតឡើងដោយក្រុមដែលមាននិន្នាការប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់ ។ បច្ចុប្បន្ននាយកដ្ឋានជំនាញ កំពុងប្រមូលភស្តុតាង ដើម្បីអនុវត្តនិតិវិធីច្បាប់»។ នេះបើតាមសេចក្តីក្នុងហ្វេសប៊ុកនាយកដ្ឋានដដែល។ នាយកដ្ឋានសង្ឃឹមថា មហាជន និងសាធារណជនដែលប្រើប្រាស់បណ្តាញសង្គម មេត្តាកុំបន្តចែកចាយព័ត៌មានក្លែងក្លាយខាងលើនេះ ដើម្បីចៀសវាងបង្កការយល់ច្រឡំ ឬបង្កអសន្តិសុខសង្គមផ្សេងៗ៕

## អ្នកនាំពាក្យក្រសួងយុត្តិធម៌៖ សមត្ថកិច្ចកំពុងស្រាវជ្រាវក្រុមបំពុលសង្គម ដែលប្រឌិតព័ត៌មានចាប់ក្មេងយកសរីរាង្គ, ជនទាំងនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់

https://freshnewsasia.com/index.php/en/localnews/292219-2023-05-21-13-37-57.html 2023-05-21 08:37pm

**(ភ្នំពេញ)៖** លោក គឹម សន្តិភាព អ្នកនាំពាក្យក្រសួងយុត្តិធម៌ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣នេះ បានចេញមកបញ្ជាក់ថា កម្លាំងសមត្ថកិច្ចកំពុងបើកការស្រាវជ្រាវ ដើម្បីស្វែងរកក្រុមបំពុលសង្គមប្រឌិតព័ត៌មានករណីចាប់ក្មេងយកសរីរាង្គ នៅតាមបណ្តាញសង្គម Facebook ដែលកើតមានប៉ុន្មានថ្ងៃចុងក្រោយនេះ។ ថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News លោក គឹម សន្តិភាព បានអះអាងថា ក្រុមជនទុច្ចរិតដែលបំពុលសង្គមទាំងអស់នោះ នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ដែលបានប្រឌិតព័ត៌មានបង្កឲ្យមានការភិតភ័យ និងបង្កឲ្យយល់ច្រឡំពីសំណាក់ប្រជាពលរដ្ឋ។ លោក គឹម សន្តិភាព បានថ្លែងយ៉ាងដូច្នេះថា «មួយរយៈនេះឃើញមានព័ត៌មានមួយចំនួនទាក់ទងនឹងការចាប់ក្មេងៗដើម្បីយកសរីរាង្គ! ខ្ញុំសូមជម្រាបជូនថា សមត្ថកិច្ចកំពុងស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់លើព័ត៌មានទាំងនេះ តែមកទល់ពេលនេះពុំមានតម្រុយណាមួយទាក់ទងនឹងករណីនេះទេ។

ទន្ទឹមនេះ សមត្ថកិច្ចក៏កំពុងស្រាវជ្រាវផងដែរនូវប្រភពព័ត៌មានដែលកំពុងចែកចាយទាំងនេះ ដើម្បីស្វែងរកការពិតជូនបងប្អូនយើង។ សូមលើកទឹកចិត្តសម្រាប់ការបង្ហាញព័ត៌មានពិត តែសម្រាប់អ្នកដែលបំពុលព័ត៌មាននេះក៏នឹងទទួលខុសត្រូវចំពោះមុខច្បាប់ផងដែរ។ សូមបងប្អូនកុំបន្តចែកចាយនូវព័ត៌មានពុំមានប្រភពច្បាស់លាស់ ដើម្បីចូលរួមថែរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមយើង»។ គួរជម្រាបថា នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី២១ ខែឧសភានេះ ក៏បានចេញមកអះអាងដូចគ្នាដែរថា ករណី

ដែលគេបង្ហោះចែកចាយពេញបណ្តាញសង្គម រឿងចាប់ក្មេងវះយកក្រលៀន ឬករណីចាប់ក្មេងផ្សេងៗនោះ គឺជារឿងប្រឌិត ក្នុងចេតនាបំពុលសង្គមប៉ុណ្ណោះ។

នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានគូសបញ្ជាក់ថា បន្ទាប់ពីទទួលបានព័ត៌មានគេចែកចាយនោះ មន្ត្រីជំនាញបានបើកការស្រាវជ្រាវបន្ទាន់ភ្លាមៗ និងឈានដល់ការកំណត់បានថា ព័ត៌មានទាំងអស់នោះ ជាព័ត៌មានក្លែងក្លាយ ដែលបង្កើតឡើងដោយក្រុមដែលមាននិន្នាការប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់។ បច្ចុប្បន្ននាយកដ្ឋានជំនាញ កំពុងប្រមូលភស្តុតាង ដើម្បីអនុវត្តនិតិវិធីច្បាប់៕

## អន្តោប្រវេសន៍ហ្វីលីពីន ឃាត់ខ្លួនស្ត្រីជនជាតិហ្វីលីពីនម្នាក់ដែលសង្ស័យថាចាញ់បោកក្រុមជួញដូរមនុស្សនៅកម្ពុជា

https://www.khmertimeskh.com/501294567//?p=1294567 Khmer Times May 22, 2023

ការិយាល័យអន្តោប្រវេសន៍ហ្វីលីពីននៅអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino (NAIA) បាននិយាយកាលពីថ្ងៃសុក្រថា មន្ត្រីការិយាល័យអន្តោប្រវេសន៍ហ្វីលីពីនបានជួយសង្គ្រោះស្ត្រីម្នាក់ខណៈដែលនាងព្យាយាមចាកចេញពីប្រទេសដោយប្រើឯកសាររៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ។ ហេតុការណ៍នេះបានកើតឡើងកាលពីថ្ងៃទី ១៤ ឧសភា នៅអាកាសយានដ្ឋាន NAIA នៅពេលដែលស្ត្រីរូបនេះត្រូវបានហាមឃាត់មិនអោយឡើងយន្តហោះ Air Asia ទៅកាន់ទីក្រុង Kuala Lumpur បន្ទាប់មកទីក្រុងភ្នំពេញ។

លោក Norman Tansingco ប្រធានអង្គភាពត្រួតពិនិត្យ និងអនុវត្តច្បាប់ធ្វើដំណើរ របស់អន្តោប្រវេសន៍ហ្វីលីពីនបាននិយាយថាស្ត្រីរូបនេះបានបង្ហាញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ក្លែងក្លាយ ដែលនាងបានអះអាងថានាងនឹងទៅជួបប្តីរបស់នាងនៅកម្ពុជា។ ក្រៅពីភាពមិនស្របគ្នា និងមាន"ភាពមិនស៊ីសង្វាក់គ្នាជាច្រើន" ដែលបានរកឃើញនៅក្នុងឯកសាររបស់នាង។ យោងតាមការិយាល័យអន្តោប្រវេសន៍បានឱ្យដឹងថា ស្ត្រីជនជាតិហ្វីលីពីនដែលមិនបញ្ចេញឈ្មោះរូបនេះបានជួលគេអោយរៀបចំឯកសារធ្វើដំណើររបស់នាង និងបានបង់ប្រាក់ចំនួន ៣៥,០០០ ប៉េសូ ដែលចេញដោយប្តីក្លែងក្លាយរបស់នាង។

តាមការត្រួតពិនិត្យកំណត់ត្រាធ្វើដំណើររបស់ប្តីក្លែងក្លាយនាងបានបង្ហាញថាជននេះត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសហ្វីលីពីនដោយមន្ត្រីអន្តោប្រវេសន៍នៅអាកាសយានដ្ឋាន NAIA កាលពីខែកញ្ញាឆ្នាំមុន ដោយផ្អែកលើហេតុផលថាជននេះអាចនឹងត្រូវរងការពិន័យជាសាធារណៈ" ។ លិខិតបញ្ជាក់អាពាហ៍ពិពាហ៍បានបង្ហាញអោយដឹងថា អាពាហ៍ពិពាហ៍របស់ពួកគេបានធ្វើឡើងនៅក្នុងខែតុលាឆ្នាំមុន ឬមួយខែបន្ទាប់ពីប្តីក្លែងក្លាយរូបនេះត្រូវបានហាមឃាត់មិនឱ្យចូលប្រទេសហ្វីលីពីន"។ លោក Norman Tansingco បាននិយាយថា អន្តរាគមន៍ជោគជ័យនៅក្នុងករណីជួញដូរនេះ បង្ហាញពីការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងសកម្មភាពខុសច្បាប់នៅព្រលានយន្តហោះក្នុងប្រទេស។ Manila Bulletin

# ក្រសួងមហាផ្ទៃ អន្តរាគមន៍សង្គ្រោះជនបរទេសជិត៤០០នាក់ ពាក់ព័ន្ធការ ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

https://www.khmertimeskh.com/501295126// ហង្ស ពណ្ណរាយ / Khmer Times May 23, 2023

គិតត្រឹមរយៈពេល៣ខែ ឬក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃ បានអន្តរាគមន៍ជួយសង្គ្រោះជនបរទេសចំនួន ៣៧៤នាក់ ស្មើនឹង ១០សញ្ជាតិ ដែលភាគច្រើនពាក់ព័ន្ធនឹងជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីឱ្យពួកគេមានសេរីភាព និងអាចធ្វើដំណើរទៅប្រទេសរបស់ខ្លួនវិញ។

ទំព័រហ្វេសប៊ុកផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង កាលពីថ្ងៃព្រហស្បតិ៍ បានចេញរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០២៣ ថាក្រសួងបានជួយសង្គ្រោះជនបរទេសសរុប ៣៧៥ នាក់ (ស្រី ៣១ នាក់) ស្មើនឹង១០សញ្ជាតិ។ ក្នុងនោះមានដូចជា ចិន ថៃ បង់ក្លាដេស ប៉ាគីស្ថាន ម៉ាឡេស៊ី វៀតណាម ហ្វីលីពីន ឥណ្ឌា និងឥណ្ឌូនេស៊ី។ ក្រសួងបន្ថែមថា ក្នុងរយៈពេលត្រីមាសទី១ ឆ្នាំ២០២៣ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នា ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលបានធ្វើឱ្យសភាពការណ៍នេះមានការថយចុះគួរឱ្យកត់សម្គាល់។ ក្រសួងបន្តថា សំណើសុំកិច្ចអន្តរាគមន៍ខាងលើនេះបានថយចុះ ៧៨ ភាគរយ ពីចំនួន ៦០៥ សំណើ មកនៅត្រឹមតែ ១២៨ សំណើ បើធៀបទៅនឹងរយៈពេល៣ខែដូចគ្នា កាលពីឆ្នាំមុន។ ចំពោះខេត្តដែលមានសំណើច្រើនជាងគេ មានខេត្តឧត្តរមានជ័យ កោះកុង កណ្តាល និងព្រះសីហនុ។

លោក ស ខេង បញ្ជាក់ថា៖ «អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា នៅតែបន្តជំរុញសកម្មភាពក្នុងការត្រួតពិនិត្យ និងបង្ក្រាបទីតាំងអាជីវកម្ម ក្នុងករណីមានសំណើ ឬព័ត៌មានជាក់លាក់ពាក់ព័ន្ធទៅនឹងបទល្មើស ការបង្ខាំងមនុស្ស ការរឹតត្បិតសេរីភាព ការធ្វើទារុណកម្ម អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការលួចលាក់បើកអាជីវកម្មល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ព្រមទាំងស្រាវជ្រាវរកជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់»។ លោកបន្ថែមថា បច្ចុប្បន្ន អាជ្ញាធរ និងសមត្ថកិច្ច នឹងបន្តពិនិត្យលើសំណើសុំអន្តរាគមន៍ដែលត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារស្រាវជ្រាវ ស្វែងរកតាមសំណើ ឬសំណូមពរ ដើម្បីធានាសុវត្ថិភាពឱ្យបានដាច់ខាតដល់ជនបរទេស ដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេតឱ្យបានហ្មត់ចត់។

លោកថា ក្រសួងនឹងបន្តពិនិត្យ វាយតម្លៃ លើសំណុំរឿងដែលពាក់ព័ន្ធបទល្មើស ដើម្បីពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់ ពង្រឹងការងារគ្រប់គ្រង ត្រួតពិនិត្យតំបន់ព្រំដែន និងច្រកទ្វារព្រំដែន នៅតាមច្រកសមុទ្រ សំដៅទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់របស់ជនបរទេស។ លើសពីនេះ បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលមានជនជាតិរបស់ខ្លួន ដែលប្រកាសថា ជាជនរងគ្រោះ ហើយស្នើសុំអន្តរាគមន៍ ដើម្បីស្រាវជ្រាវ អង្កេត និងបង្ក្រាបឱ្យបាននូវមេខ្លោង ខ្សែរយៈបណ្តាញមានអង្គការចាត់តាំង ដែលធ្វើការអូសទាញ ឬក៏បញ្ឆោតជនបរទេសឱ្យឆ្លងដែនដោយស្របច្បាប់នឹងមិនស្របច្បាប់ចូលមកកម្ពុជា ដើម្បីធ្វើការងារដោយខុសច្បាប់។

អភិបាលរងខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តព្រះសីហនុ លោក ឡុង ឌីម៉ង់ ប្រាប់កាសែតខ្មែរថាមស៍កាលពីម្សិលមិញថា បច្ចុប្បន្ន ចំពោះកិច្ចការបង្ក្រាបបទល្មើសគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅខេត្តព្រះសីហនុ ត្រូវបានកាត់បន្ថយច្រើនគួរឱ្យកត់សម្គាល់។ លោកបញ្ជាក់ថា៖ «នៅពេលនេះ ខេត្តព្រះសីហនុ សឹងតែគ្មានពាក្យបណ្តឹងទៀតផង កន្លងមក យើងតែងទទួលពាក្យបណ្តឹងច្រើនពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែក្រោយពីប្រតិបត្តិការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់នេះ [...] យើងឃើញថា សកម្មភាពទាំងនេះមានការថយចុះច្រើន ហើយសឹងតែគ្មានពាក្យបណ្តឹងទៀតផង»។ លោកបន្ថែមថា ការប្រតិបត្តិការដោយទទួលបានជោគជ័យនេះ គឺមានការដឹកនាំដោយផ្ទាល់ពីលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្លាប់ឱ្យដឹងថា ចំពោះបទល្មើសជួញដូរមនុស្ស ជួញដូរពល និងការធ្វើអាជីវកម្មផ្លូវភេទ នៅតែស្ថិតក្នុងស្ថានភាពប្រឈម ដែលត្រូវយកចិត្តទុកដាក់ និងចុះបង្ក្រាបជាប្រចាំ។ លោកស្រីថ្លែងថា ប្រសិនបើថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធទាំងអស់ខិតខំអនុវត្តទៅតាមទិសដៅដែលបានដាក់ចេញ ប្រាកដណាស់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នឹងទទួលបានលទ្ធផលកាន់តែប្រសើរទាំងបច្ចុប្បន្ន និងសម្រាប់ថ្ងៃអនាគត។ លោកស្រីថា រដ្ឋាភិបាលកម្ពុជា មានគោលនយោបាយ និងប្តេជ្ញាចិត្តច្បាស់លាស់ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដែលទាមទារឱ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវរួមគ្នា ដើម្បីដោះស្រាយបញ្ហាខាងលើនេះ។ តាមរបាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ (គ.ជ.ប.ជ.)កាលពីឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានស្រាវជ្រាវ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទសរុបចំនួន ១៦៦ករណី បើធៀបទៅនឹងឆ្នាំ២០២១ មានចំនួន៣៥៩ករណី គឺបានថយចុះចំនួន ១៩៣ករណី ស្មើនឹង៥៥,៧៦ភាគរយ៕

# ថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០២៣

## ឃាត់ខ្លួនម្ចាស់ហាងខារ៉ាអូខេនិងមេការស្រីម្នាក់ ពាក់ព័ន្ធនឹងការ បើកទីតាំងខារ៉ាអូខេមួយកន្លែង លួចបង្កប់សេវាកម្មផ្លូវភេទ នៅខេត្តកំពង់ស្ពឺ

https://cen.com.kh/archives/661472.html Posted ByPen Srey NeatMay 23, 2023

ខេត្តកំពង់ស្ពឺ៖ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣ បានចុះបង្ក្រាប និង ឃាត់ខ្លួនមនុស្សប្រុស-ស្រីចំនួន២នាក់ ម្នាក់ជាម្ចាស់ហាង និងម្នាក់ទៀតជាមេការ ពាក់ព័ន្ធនឹងការ បើកទីតាំងខារ៉ាអូខេមួយកន្លែង លួចបង្កប់សេវាកម្មផ្លូវភេទ ប្រព្រឹត្ត នៅទីតាំងខារ៉ាអូខេមួយកន្លែងដែលមានឃីហោ (មាន់ស្រែបន្លែធម្មជាតិ) ស្ថិតនៅភូមិបឹងស្គុក ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

សមត្ថកិច្ចនគរបាលជំនាញបានឲ្យដឹងថា មនុស្សចំនួន២នាក់ខាងលើមាន៖ ១- ឈ្មោះ យូរ អាត់ ភេទប្រុស អាយុ ៤៥ ឆ្នាំ ( ត្រូវជាម្ចាស់ហាង) ។ ២- ឈ្មោះ លី ខុំ ភេទ ស្រី អាយុ ៣០ ឆ្នាំ ( ត្រូវជាមេការ ) ។ អ្នកទាំងពីរនាក់ មានទីលំនៅ ភូមិបឹងស្គុក ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ សមត្ថកិច្ចនគរបាលជំនាញបានបញ្ជាក់ថា ក្រោយចុះបង្ក្រាប ទីតាំងខារ៉ាអូខេខាងលើគឺសមត្ថកិច្ចបានរកឃើញបទល្មើសជាក់ស្តែងមានកន្លែងសម្រាប់បម្រើសេវារួមភេទចំនួនពីរបន្ទប់ ។ និងជួយសង្គ្រោះនារីរងគ្រោះដែលបម្រើសេវាផ្លូវភេទនៅទីនោះចំនួន១៨នាក់ ។

បច្ចុប្បន្ន, មនុស្សប្រុស-ស្រីខាងលើ ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលខេត្ត កំពង់ស្ពឺ ដើម្បីរៀបចំបែបបទ និង កសាងសំណុំរឿង ចាត់ការតាមនីតិវិធីច្បាប់ ៕ រក្សាសិទ្ធដោយ ៖ចន្ទា ភា

## ជនជាប់ចោទវៀតណាមប្រុស-ស្រី ២នាក់ ត្រូវជាប់គុក ម្នាក់ៗ ៨ ឆ្នាំ ដោយសារតែព្រួតគ្នាវាយ ស្តេចបំរើផ្លូវភេទ ម្នាក់ បណ្តាលឲ្យស្លាប់ ព្រោះខឹងនាង មិនព្រមទទួលភ្ញៀវ

https://cen.com.kh/archives/661379.html Posted ByPen Srey NeatMay 23, 2023

ភ្នំពេញ: ជនជាប់ចោទប្រុស-ស្រី ជនជាតិវៀតណាម ចំនួន២នាក់ កាលពីព្រឹកថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣ ត្រូវបានសាលាឧទ្ធរណ៍ រាជធានីភ្នំពេញធ្វើការ ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ ពួកគេ ជាប់ពាក់ព័ន្ធនឹងការព្រួតគ្នា វាយ ធ្វើបាប នារីវៀតណាម បំរើផ្លូវភេទម្នាក់ ដែលអ្នកបម្រើការងារ នៅក្នុងហាងម៉ាស្សារបស់ពួកគេ បណ្តាលឲ្យស្លាប់ ពីព្រោះខឹងនឹងជនរងគ្រោះ មិនព្រមទទួលភ្ញៀវ រួចដឹកសពយកទៅវត្ត ដើម្បីបូជា ប្រព្រឹត្ត កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅផ្ទះជួលលេខ ១៥៨ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

លោក អ៊ឹម វណ្ណៈ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងឲ្យដឹងថា ជនជាប់ចោទទាំង២នាក់ មានឈ្មោះ ឈ្មោះ ង្វៀង យ៉ាំងចូវ ភេទប្រុស អាយុ ២៨ ឆ្នាំ ជនជាតិវៀតណាម មុខរបរ មេការមើលខុសត្រូវនារីបំរើផ្លូវភេទ និងម្នាក់ទៀត ឈ្មោះ ង្វៀង ធីយុង ភេទស្រី អាយុ ៣៨ ឆ្នាំ ជនជាតិវៀតណាម ជាថៅកែ និង ម្ចាស់ហាង។ ចំណែកឯនារីរងគ្រោះត្រូវជាជនជាតិវៀតណាមដូចគ្នា មានអាយុ អាយុ ២៨ ឆ្នាំ ។ អ្នកទាំង៣នាក់ មានទីលំនៅ ផ្ទះជួលលេខ ១៥៨ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ លោកចៅក្រម បានថ្លែងថា: នៅក្នុងសំណុំរឿងក្តីនេះ ជនជាប់ចោទទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៩ ដាក់ពន្ធនាគាកំណត់ ម្នាក់ៗ ០៨ ឆ្នាំ ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ។ តែពួកគាត់បានប្តឹងឧទ្ធរណ៍ ។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅសង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ សំណុំរឿងក្តីនេះ, សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ បានលើកពេលប្រកាសសាលដីកា នៅព្រឹកថ្ងៃទ ១៤ ខែ មិថុនា ឆ្នាំ ២០២៣ ខាងមុខនេះ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

# ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ២០២៣

## ស្ត្រីជនជាតិចិនម្នាក់ សម្រេចចិត្តប្តឹងស្នើសុំ អន្តរាគមន៍ទៅទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម ដោយប្រឌិតថាខ្លួនត្រូវបានគេបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ និងជំរិតទារប្រាក់នៅក្នុងទីតាំងមួយ

https://cen.com.kh/archives/661784.html Posted ByPen Srey NeatMay 24, 2023

ភ្នំពេញ ៖ ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិនៅថ្ងៃទី ២៣ ខែឧសភាឆ្នាំ២០២៣ បានចេញរបាយការណ៍លទ្ធផលកិច្ចប្រតិបត្តិការស្វែងរកជនបរទេស ដែលបានស្នើសុំអន្តរាគមន៍ តាមរយៈទំព័រហ្វេសបុកសម្តេចក្រឡាហោម (ករណីលេខ ៨១៧) ដែលបានផ្តល់ព័ត៌មានថាខ្លួនត្រូវបានបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ និងជំរិតទារប្រាក់នៅ ក្នុងក្រុមហ៊ុនមួយ ស្ថិតក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។ ផ្អែកតាមការបំភ្លឺ និងពិនិត្យលើស្ថានភាពជាក់ស្តែង ក្រុមប្រតិបត្តិការ ពិនិត្យឃើញថា ករណីនេះពុំមានសញ្ញាណពាក់ព័ន្ធនឹងករណីបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ ឬជំរិតទារប្រាក់ នោះទេ ផ្ទុយទៅវិញសាមីខ្លួនគ្រាន់តែចង់ឈប់ពីការងារភ្លាមៗ ដើម្បីបានត្រឡប់ទៅប្រទេសកំណើតវិញ។

ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវបណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ បានឲ្យដឹងថា នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ក្រុមប្រតិបត្តិការ ទទួលបានសំណើសុំអន្តរាគមន៍ពីស្ត្រីជនជាតិចិន ឈ្មោះ ZHAO ZHONGQIONG កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ កាន់លិខិតឆ្លងដែនលេខ EE7455850 ដែលបានផ្តល់ព័ត៌មានថាខ្លួនត្រូវបានបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ និងជំរិតទារប្រាក់នៅ ក្នុងក្រុមហ៊ុនមួយ ស្ថិតក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។ បន្ទាប់ពីទទួលបានសំណើ កម្លាំងសមត្ថកិច្ច នៃស្នងការដ្ឋាននគរបាលខេត្តកោះកុង បានចុះស្រាវជ្រាវរកឃើញស្ត្រីជនជាតិចិនខាងលើ កំពុងស្នាក់នៅក្នុង ក្រុមហ៊ុនមួយកន្លែង និងបានអញ្ជើញមកធ្វើការសាកសួរ។

យោងតាមការបំភ្លឺរបស់សាមីខ្លួនបានឲ្យដឹងថា រូបនាងបានចូលមកប្រទេសកម្ពុជាកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២ តាមច្រកអាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ ដើម្បីស្វែងរកការងារធ្វើតាមរយៈភ្នាក់ងារ និងបានធ្វើជាចុងភៅនៅក្នុងក្រុមហ៊ុនខាងលើ រហូតមកដល់បច្ចុប្បន្ន អំឡុងពេលធ្វើការ រូបនាងពុំធ្លាប់ត្រូវបានគេបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ ឬជំរិត ទារប្រាក់នោះទេ។ រហូតដល់ដើមខែធ្នូ ឆ្នាំ២០២២ រូបនាងបានដាក់ពាក្យលាឈប់ពីការងារដោយសារ តែនាងបារម្ភពីក្រុមគ្រួសារនៅឯប្រទេសចិន ប៉ុន្តែក្រុមហ៊ុនមិនទាន់អនុញ្ញាត និងបានស្នើសុំឲ្យរូបនាងបន្ត ធ្វើការរហូតរកបានបុគ្គលិកថ្មីមកជំនួស ដោយមិនអាចរង់ចាំបន្តទៀតបាន ទើបរូបនាងសម្រេចចិត្តប្តឹងស្នើសុំអន្តរាគមន៍ទៅទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម ដោយប្រឌិតថាខ្លួនត្រូវបានគេបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ និងជំរិតទារប្រាក់នៅក្នុងទីតាំងមួយ។

ផ្អែកតាមការបំភ្លឺ និងពិនិត្យលើស្ថានភាពជាក់ស្តែង ក្រុមប្រតិបត្តិការ ពិនិត្យឃើញថា ករណីនេះពុំមានសញ្ញាណពាក់ព័ន្ធនឹងករណីបង្ខាំងបង្ខំឲ្យធ្វើការខុសច្បាប់ ឬជំរិតទារប្រាក់ នោះទេ ផ្ទុយទៅវិញសាមីខ្លួនគ្រាន់តែចង់ឈប់ពីការងារភ្លាមៗ ដើម្បីបានត្រឡប់ទៅប្រទេសកំណើតវិញតាមតម្រូវការរបស់ខ្លួនតែប៉ុណ្ណោះ។ បច្ចុប្បន្នសមត្ថកិច្ចជំនាញបានបញ្ជូនឈ្មោះ ZHAO ZHONGQIONG ទៅកាន់មណ្ឌលត្រៀមបណ្តេញ ចេញនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤៩នាក់

https://freshnewsasia.com/index.php/en/localnews/292508-2023-05-24-08-24-51.html 2023-05-24 03:24pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៨៩ករណី មានមនុស្ស ២,២១៤នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥៥សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,២៦៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១១១ករណី៕

# ករណីជនវៀតណាម៣៩នាក់ស្លាប់ក្នុងរថយន្ត៖ តុលាការបារាំងនឹងបើកសវនាការកាត់ទោសជនជាប់ចោទ១៩នាក់

ករណីប្រទះឃើញសាកសព ជនជាតិវៀតណាម៣៩នាក់ ស្លាប់នៅក្នុងរថយន្តមួយ នៅជាយទីក្រុងឡុងដ៍ កាលពីខែតុលាឆ្នាំ២០១៩ បានបង្កឲ្យមានការតក់ស្លុតជាខ្លាំង។ ឆ្លងកាត់ការស៊ើបអង្កេតជាង៣ឆ្នាំមកនេះ ចៅក្រមស៊ើបអង្កេតបារាំង បានប្រកាសកាលពីថ្ងៃពុធ ទី២៤ឧសភា ថានឹងចាប់ផ្តើមនីតិវិធី ឈានទៅបើកសវនាកាជំនុំជំរះទោស លើជនសង្ស័យចំនួន១៩នាក់ ដែលចូលរួមនៅក្នុងបណ្តាញជួញដូរ និងដឹកជញ្ជូនជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់។

https://www.rfi.fr/km//20230524-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 24/05/2023

ចៅក្រមស៊ើបអង្កេតបារាំង២នាក់ បានសម្រេចរុញឈ្មោះជនសង្ស័យចំនួន១៩នាក់ ឡើងទៅកាន់តុលាការ ដើម្បីបើកសវនាការ នៅក្នុងសំណុំរឿងសាកសពជាតិវៀតណាម៣៩នាក់ ស្លាប់ក្នុងរថយន្តដែលគេប្លុងចោលនៅជាយទីក្រុងឡុងដ៍។ ជនសង្ស័យទាំង១៩នាក់ មានខ្លះសញ្ជាតិវៀតណាម សញ្ជាតិបារាំង ចិន អាល់ហ្សេរី ឬម៉ារ៉ុក។ យោងតាមប្រភពសិទ្ធនឹងតុលាការបារាំង ជនសង្ស័យទាំងនោះ ជាប់ចោទថាបានចូលរួមក្នុងបណ្តាញជួញដូរ ជនអន្តោប្រវេសន៍វៀតណាម ដូចជាអ្នករករថយន្ត អ្នកបើកបរ និងអ្នកបានផ្តល់ជាទីកន្លែងស្នាក់នៅបណ្តោះអាសន្នដល់ជនអន្តោប្រវេសន៍ នៅតំបន់ក្រុងប៉ារីស។ បទល្មើសឃុបឃិត ក្នុងបណ្តាញដឹកជញ្ជូនជនអន្តោប្រវេសន៍ខុសច្បាប់ អាចប្រឈមនឹងទោសជាប់ពន្ធនាគារ១០ឆ្នាំ។ ដោយឡែក មានជនសង្ស័យ៤នាក់ ក្នុងចំណោមទាំង១៩នាក់ នឹងត្រូវប្រឈមនឹងការចោទប្រកាន់ពីបទល្មើស មនុស្សឃាតដោយអចេតនា។ ជនសង្ស័យ៦នាក់ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន និងមាន២នាក់ទៀត កំពុងរត់គេចខ្លួន។

សូមរំលឹកថា កាលពីខែតុលា ឆ្នាំ២០១៩ សាកសពជនជាតិវៀតណាម៣៩នាក់ ប្រុស៣១នាក់ និងស្រី៨នាក់ អាយុចន្លោះពី១៥ដល់៤៤ឆ្នាំ ត្រូវបានគេប្រទះឃើញនៅក្នុងរថយន្តកាមីញ៉ុងមួយ ចតចោលនៅតំបន់ឧស្សាហកម្មមួយជាយទីក្រុងឡុងដ៍។ ឆ្លងកាត់ការស៊ើបអង្កេតជិត៤ឆ្នាំ ដោយមានការសហការ ពីអាជ្ញាធរបារាំង ប៊ែលហ្ស៊ិក និងអង់គ្លេស បានបង្ហាញឲ្យឃើញថា ករណីនេះពាក់ព័ន្ធនឹងបណ្តាញជួញដូរជនអន្តោប្រវេសន៍វៀតណាមដែលមានប្រភពនៅបារាំង។ ជនអន្តោប្រវេសន៍វៀតណាម ត្រូវគេបញ្ជូនពីវៀតណាមមកដល់បារាំង បន្ទាប់មកដឹកបន្តទៅកាន់កំពង់ផែ Zeebruges ប្រទេសប៊ែលហ្ស៊ិក មុននឹងដឹកឆ្លងទូក ឆ្ពោះទៅកាន់អង់គ្លេស ជាទីដែលរថយន្តកាមីញ៉ុងមួយទៀត មកចាំដឹកបន្ត។

បណ្តាញព័ត៌មានបារាំង AFP បានទាក់ទងជួបជាមួយក្រុមគ្រួសាររបស់ជនរងគ្រោះ ភាគច្រើនមានដើមកំណើតនៅខេត្តហាទិញ ដែលជាខេត្តក្រីក្រមួយនៅភាគខាងត្បូងវៀតណាម។ បុរសជនម្នាក់ ដែលមានប្អូនស្រីអាយុ២៦ឆ្នាំស្លាប់ក្នុងចំណោមជនរងគ្រោះទាំង៣៩នាក់ បានប្រាប់ថា មុននឹងស្លាប់ ប្អូនស្រីខ្លួនបានផ្ញើសារទៅកាន់ទូរស័ព្ទរបស់ម្តាយនៅវៀតណាម ថាកំពុងតែស្លាប់ ដោយថប់ ដកដង្ហើមលែងរួចនៅក្នុងរថយន្ត។

យោងតាមបណ្តាញព័ត៌មានបារាំង AFP ជនជាប់ចោទដែលជាជនជាតិវៀតណាមមេក្លោងបណ្តាញជួញដូរនេះ បានអះអាងថាខ្លួន ធ្វើសកម្មភាពនេះ ដោយសារតែចង់ជួយជីវភាពជនជាតិវៀតណាមគ្នាឯង។ តែយ៉ាងណាចៅក្រមស៊ើបអង្កេតបារាំង បានច្រានចោល អំណះអំណាងនេះ ដោយផ្អែកថា នៅពីក្រោយសកម្មភាពនេះ គឺជនសង្ស័យបានសំឡឹងឃើញប្រាក់ចំណេញដ៏សន្ធឹកសន្ធាប់៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១១នាក់

https://freshnewsasia.com/index.php/en/localnews/292914-2023-05-26-02-16-47.html 2023-05-26 09:16am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១១ នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៩២ករណី មានមនុស្ស ២,២២៥នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៥៧សំណើ និងបិទសំណុំរឿង ២៩៣សំណើ (រកឃើញមនុស្ស ១,២៧៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៥ករណី៕

# ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០២៣

## ក្រសួងមហាផ្ទៃ ផ្សព្វផ្សាយគោលនយោបាយភូមិ-សង្កាត់ ជូនអាជ្ញាធរក្នុងមូលដ្ឋានរាជធានីភ្នំពេញ ដើម្បីអនុវត្តឱ្យកាន់តែល្អប្រសើរ និងផ្តល់ភាពកក់ក្តៅដល់ពលរដ្ឋ

https://freshnewsasia.com/index.php/en/localnews/292971-2023-05-26-06-23-08.html 2023-05-26 01:23pm

**(ភ្នំពេញ)៖** លោកសន្តិបណ្ឌិត ខៀវ សុភ័គ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារទី១ ត្រួតពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ នៅរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣នេះ បានបើកកិច្ចប្រជុំស្តីពីការត្រួតពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ជូនអាជ្ញាធរក្នុងមូលដ្ឋានរាជធានីភ្នំពេញ ដើម្បីអនុវត្តឱ្យកាន់តែល្អប្រសើរ និងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ។

នាឱកាសនោះ លោកសន្តិបណ្ឌិត ខៀវ សុភ័គ បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់លើវិស័យសន្តិសុខជាតិយ៉ាងខ្លាំង ដោយបានបង្កើតឱ្យមានគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ដើម្បីឱ្យថ្នាក់ក្រោមជាតិអនុវត្ត សំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋរស់នៅ ដោយគ្មានភាពភ័យខ្លាច។ មិនត្រឹមតែប៉ុណ្ណោះទេ រាជរដ្ឋាភិបាលនូវបានបង្កើតឱ្យមានការប្រលងប្រណាំង និងផ្តល់រង្វាន់លើកទឹកចិត្តចំពោះមូលដ្ឋានណា ដែលអនុវត្តគោលនយោបាយភូមិ-សង្កាត់មានសុវត្ថិភាពនេះ បានល្អជាងគេផងដែរ។

លោកសន្តិបណ្ឌិត ខៀវ សុភ័គ បានបន្តថា កិច្ចប្រជុំខាងលើនេះធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទាំង៧ចំណុចឱ្យកាន់តែល្អប្រសើរ ជាមួយនឹងការកៀរគរឱ្យមាន ការចូល

រួមអនុវត្តពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើយ៉ាងណាអោយការអនុវត្តគោលនយោបាយនេះ អនុវត្តទៅកាន់តែល្អប្រសើរ និងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ។ លោកសន្តិបណ្ឌិត ខៀវ សុភ័គ បានបន្ថែមទៀតថា កងកម្លាំង និងអាជ្ញាធររបស់យើងនេះហើយ ជាអ្នករួមចំណែកយ៉ាងពិតប្រាកដ ក្នុងការធ្វើអោយប្រទេសជាតិ ដែលដើរចេញពីចំណុចសូន្យ រហូតមានការអភិវឌ្ឍរីកចម្រើនដូចសព្វថ្ងៃនេះ។ លោកសន្តិបណ្ឌិត ខៀវ សុភ័គ បានលើកឡើងថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ជាអ្នកស្វែងរកសន្តិភាព ដោយបានធ្វើអោយប្រទេសកម្ពុជា មានសន្តិភាពពេញផ្ទៃប្រទេស ក្រោយពីខកខានជាង៥០០ឆ្នាំមកហើយ។

លោក ហ៊ុន សុរិទ្ធី អភិបាលរងរាជធានីភ្នំពេញ តំណាងឱ្យលោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់លើវិស័យសន្តិសុខជាតិ ដែលជាវិស័យអាទិភាពមួយដ៏សំខាន់ ពីព្រោះថាវិស័យនេះ គឺជាឆ្អឹងខ្នងសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ព្រមទាំងការអភិវឌ្ឍវិស័យដទៃទៀត ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤។ លោក ហ៊ុន សុរិទ្ធី បានបន្តថា ក្នុងរយៈពេល៥ខែ ដើមឆ្នាំ២០២៣នេះ រដ្ឋបាលរាជធានីភ្នំពេញ បានបន្តចាត់តាំងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»** ដោយរក្សាបាននូវ សន្តិសុខ-សណ្តាប់ធ្នាប់សាធារណៈយ៉ាងល្អប្រសើរ ជាពិសេសក្នុងអំឡុងពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងការធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេម លើកទី៣២ ដែលទើបកន្លងផុតទៅថ្មីៗនេះ ប្រកបដោយបរិយាកាសសប្បាយរីករាយ អធិកអធម និងពោរពេញ ដោយក្តីមោទនភាពបំផុត។

ជាមួយគ្នានេះដែរ លោក ហ៊ុន សុរិទ្ធី បានបន្ថែមថា ក្នុងត្រីមាសទី១ ឆ្នាំ២០២៣នេះ ទោះបីចំនួនបទល្មើសព្រហ្មទណ្ឌដែលបានកើតមានក្នុងរាជធានីភ្នំពេញ មានការកើនឡើង ១៤៤/១៣៣លើក កើនឡើងចំនួន ១១លើក ស្មើនឹង ៨,២% ប៉ុន្តែគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ បានម្ចាស់ការបង្ក្រាបបទល្មើសទាំងនេះ សរុបចំនួន ១២២ ករណី ស្មើនឹង ៨៤,៧២% ចំនួនបទល្មើសរួម ដោយបានឃាត់ខ្លួនជនល្មើសចំនួន ២០៦នាក់ និងបានដកហូតវត្ថុតាង ព្រមទាំងសម្ភារពាក់ព័ន្ធមួយចំនួនទៀត ដែលនេះបានបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ «ភូមិ សង្កាត់ មានសុវត្ថិភាព» ដូចភ្លៀងរលឹមរបស់កងកម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៅរាជធានីភ្នំពេញ។

**គួរបញ្ជាក់ថា គោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពចំនួន៧ចំណុចនេះរួមមាន៖**

១៖ ការផ្តល់សេវាសាធារណៈ ជាពិសេស សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

២៖ គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

៣៖ មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

៤៖ គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង។

៥៖ ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៦៖ មានអនាម័យ មានសោភណភាពល្អ និងបរិស្ថានល្អ

៧៖ ឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៕

# លំហសមុទ្រ កម្ពុជា អាចជាច្រកបទល្មើសផ្សេងៗ

https://kohsantepheapdaily.com.kh/article/1744371.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៦ ខែ ឧសភា ឆ្នាំ ២០២៣ ម៉ោង ១៦:២៤

រាជធានីភ្នំពេញ ៖ នៅក្នុងពេលដែលសមត្ថភាពរបស់កងកម្លាំងសមត្ថកិច្ចកម្ពុជានៅតែបន្តមានកម្រិតលំហសមុទ្រ កម្ពុជានៅតែជាច្រកបទល្មើសផ្សេងៗកើតមាននៅក្នុងប្រទេសកម្ពុជា ដូច្នេះកម្ពុជាចាំបាច់ត្រូវតែពង្រឹងសមត្ថភាពកងកម្លាំង និងពង្រឹងប្រសិទ្ធភាពការពារបទល្មើសនានានៅលំហសមុទ្រ ។ នៅពេលនេះគេដឹងថា បទល្មើសដែលអាចនឹងកើតមានយ៉ាងងាយស្រួលនៅដែនសមុទ្រកម្ពុជា គឺជាបទល្មើសជលផលការរត់ពន្ធទំនិញ ច្រកឧក្រិដ្ឋជនជួញដូរមនុស្ស ភេរវកម្ម ហើយក៏អាចនឹងកើតមាន ទាំងបទល្មើសសេដ្ឋកិច្ច ដូចជា ករណីលាងលុយ ព្រមទាំងសកម្មភាពខុសច្បាប់ជាច្រើនទៀតទាំងបទល្មើសឆ្លងកាត់ព្រំដែន និងបទល្មើសដែលអាចកើតមាននៅក្នុងទឹកដីនៃប្រទេសកម្ពុជាផ្ទាល់ ដោយសារតែមកដល់ពេលនេះ សមត្ថភាពរបស់សមត្ថកិច្ចការពារលំហសមុទ្រកម្ពុជាហាក់នៅមានកម្រិតដែលទាមទារការធ្វើទំនើបកម្ម និងបំពាក់ឧបករណ៍ទំនើបៗជាច្រើនប្រភេទ ។

មកដល់ពេលនេះគេដឹងថា ឆ្នេរសមុទ្រកម្ពុជា ដែលអូសបន្លាយប្រមាណជា៤៤០ គីឡូម៉ែត្រចាប់ពីខេត្តកោះកុង ខេត្តព្រះសីហនុ កំពត និងកែប គឺមានទំហំ១៧.៨០០ គីឡូម៉ែត្រក្រឡា ហើយលំហសមុទ្រដែលស្ថិតនៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ កម្ពុជាទំហំប្រមាណជា ៤២.០០០ គីឡូម៉ែត្រក្រឡា ដោយមានកោះសរុបប្រមាណជាជាង ៦០កោះ ។ ផ្អែកតាមតួរលេខនេះ លំហសមុទ្រកម្ពុជាមិនសូវធំល្វឹងល្វើយដូចជា បណ្តាប្រទេសនានានៅលើពិភពលោកទេ ប៉ុន្តែសមត្ថភាពការពារ និងធានាសន្តិសុខនៅលំហសមុទ្រកម្ពុជានៅមានកម្រិត ប្រសិនបើប្រៀបធៀបនឹងប្រទេសជិតខាងដែលកំពុងតែមានព្រំដែនទឹកជាប់គ្នានៅឈូងសមុទ្រថៃ ។

ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខនៅលំហសមុទ្រនេះដែរ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានកត់សម្គាល់អំពីបញ្ហានេះដែរ ហើយបានបញ្ជាក់ថា កម្ពុជាកំពុងតែពង្រឹងយកចិត្តទុកដាក់នៅលើចំណុចឆកល្វែងនេះ ។ ថ្លែងនៅពេលចូលរួមប្រជុំពិភាក្សាអំពីផែនការបង្កើនការប្រយុទ្ធប្រឆាំងលើអំពើជួញដូរមនុស្ស កាលពីពេលថ្មីៗនេះ សម្តេចបានកត់សម្គាល់ថា ឈរលើការងារដ៏មានសារៈសំខាន់នេះដែរ យើងក៏នឹងបន្តពិនិត្យ វាយតម្លៃលើសំណុំរឿងដែលពាក់ព័ន្ធបទល្មើស ដើម្បីពន្លាតនីតិវិធី ប្រឆាំងការសម្អាតប្រាក់ ពង្រឹងការងារគ្រប់គ្រង ត្រួតពិនិត្យតំបន់ព្រំដែន និងច្រកទ្វារព្រំដែននៅតាមច្រកសមុទ្រ សំដៅទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់របស់ជនបរទេស និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ដែលមានជនជាតិរបស់ខ្លួន ប្រកាសថា ជាជនរងគ្រោះហើយស្នើសុំអន្តរាគមន៍ ដើម្បីធ្វើការស្រាវជ្រាវ អង្កេត និងបង្ក្រាបឲ្យបាននូវមេខ្លោងខ្សែរយៈបណ្តាញមានអង្គការចាត់តាំង ដែលធ្វើការអូសទាញ ឬក៏បញ្ឆោតជនបរទេសឲ្យឆ្លងដែនដោយស្របច្បាប់ និងមិនស្របច្បាប់ចូលមកកម្ពុជាធ្វើការងារដោយខុសច្បាប់ ។

ក្រៅពីនោះ សមត្ថកិច្ចប៉ូលិស នៅពេលនេះកម្ពុជាក៏កំពុងតែរៀបចំខ្លួនដើម្បីពង្រឹងសមត្ថភាព កងទ័ពជើងទឹកផងដែរ ខណៈដែលមកដល់ពេលនេះសមត្ថភាពកងទ័ពជើងទឹកយើងនៅខ្វះខាត និងទាមទារការបំពាក់សម្ភារៈ និងឧបករណ៍យោធាទំនើបៗជាច្រើនទៀត ។ នៅលើការងារបង្ក្រាបការរត់ពន្ធ និងបង្ក្រាបបទល្មើសសេដ្ឋកិច្ចផ្សេងៗ នៅពេលនេះ គយកម្ពុជាមាននាវាប្រដេញដែរហើយ ដោយមានជំនួយពីប្រទេសជប៉ុន ប៉ុន្តែចំនួន និងសមត្ថភាពរបស់ជំនាញក៏មិនគ្រាប់គ្រាន់ដែរ ដើម្បីឆ្លើយតបនឹងក្រុមឧក្រិ.ដ្ឋជន និងអ្នកដែលឆ្លៀត ឱកាសនានា ។

សរុបមកវិញ ដើម្បីរិតបន្តឹង និងធានាសុវត្ថិភាព និងសន្តិសុខនៅលំហសមុទ្រកម្ពុជាបានពេញលេញមានតែការធ្វើទំនើបកម្ម និងបំពាក់សម្ភា រៈបច្ចេកទេសខាងគ្រប់គ្រងលំហសមុទ្រ នៅក្នុងប្រទេសបន្ថែមទៀត ទេបានអាចទៅរួច បើមិនដូច្នេះទេ យើងព្រួយបារម្ភថា លំហសមុទ្រកម្ពុជា គឺជាមាត់ច្រកនៃឧក្រិដ្ឋកម្មនានាចូលមកក្នុងប្រទេស

ឬឆ្លងកាត់កម្ពុជាទៅប្រទេសទី៣ ដែលនាំអោយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងមុខមាត់ប្រទេសកម្ពុជា ៕ ដោយៈ ហេង ចេស្តារ

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៩ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១៦នាក់

https://freshnewsasia.com/index.php/en/localnews/293086-2023-05-27-04-26-22.html 2023-05-27 11:26am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៥ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៩ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១៦នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩០២ករណី មានមនុស្ស ២,២៨៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៦០សំណើ និងបិទសំណុំរឿង ២៩៣សំណើ (រកឃើញមនុស្ស ១,៣១៥នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៤នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤២ករណី៕

## ខេត្តតាកែវ និងខេត្តអានយ៉ាង ឯកភាពដាក់ចេញទិសដៅទប់ស្កាត់គ្រឿងញៀន និងជួញដូរមនុស្ស នៅតាមតំបន់ព្រំដែន

https://www.postkhmer.com/national/2023-05-26-1506-250473.html រី សុចាន់ | Publication date 26 May 2023 | 15:06 ICT

តាកែវៈ ខេត្តតាកែវ និងខេត្តអានយ៉ាងរបស់វៀតណាម បានឯកភាពគ្នាដាក់ចេញទិសដៅកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់អំពើភេរវកម្ម ព្រហ្មទណ្ឌ គ្រឿងញៀន និងជួញដូរមនុស្ស នៅតាមតំបន់ព្រំដែននៃខេត្តទាំង ២។

លោក សៅ សារុន ស្នងការរងខេត្តតាកែវ កាលពីថ្ងៃទី២៥ ខែឧសភា បានដឹកនាំប្រតិភូ ជួបសំណេះសំណាល និងទទួលយកអំណោយរបស់ស្នងការដ្ឋាននគរបាលខេត្តអានយ៉ាង សាលាក្រុងចូវដុក ខេត្តទិញបៀន និងសាលាស្រុកអានភូ របស់វៀតណាម ជូនដល់ស្នងការដ្ឋាននគរបាលខេត្តតាកែវ និងស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង។ ប្រតិភូស្នងការដ្ឋាននគរបាលខេត្តអានយ៉ាងដឹកនាំដោយលោក ឡឹម គៀកង្វៀង ស្នងការនគរបាលខេត្តអានយ៉ាង។

គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិបញ្ជាក់នាថ្ងៃទី២៦ ខែឧសភា ថា៖ «ភាគីទាំង២បានឯកភាពដាក់ចេញនូវទិសដៅកិច្ចសហប្រតិបត្តិការ ក្នុងការបង្ការទប់ស្កាត់អំពើភេរវកម្ម ព្រហ្មទណ្ឌ គ្រឿងញៀន ជួញដូរមនុស្ស និងបន្តរក្សាសាមគ្គីភាព មិត្តភាព កិច្ចសហប្រតិបត្តិការ ជាពិសេសសហការប្រយុទ្ធប្រឆាំងជំងឺកូវីដ នៅតាមតំបន់ព្រំដែននៃខេត្តទាំង២»។

លោក សៅ សារុន បានកោតសរសើរ និងអរគុណដល់ស្នងការនគរបាលខេត្តអានយ៉ាង ដែលតែងតែបានឧបត្ថម្ភគាំទ្រជាថវិកាសម្ភារនិងគ្រឿងឧបភោគបរិភោគជូនដល់ស្នងការដ្ឋាននគរបាលខេត្តតាកែវនាពេលកន្លងមក។ ភាគីទាំង២បានជូនវត្ថុអនុស្សាវរីយ៍ឱ្យគ្នាទៅវិញទៅមក ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាពយូរអង្វែង និងពិសាអាហារសាមគ្គី៕

## កិច្ចជុំត្រួតពិនិត្យលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែឧសភាឆ្នាំ ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប គ.ខ.ប.ជ

https://www.facebook.com/ncct.cambodia ? ឆ្នាំ ២០២៣ ខែឧសភា ថ្ងៃទី26 នៅម៉ោង 7:00 ល្ងាច

ថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប គ.ខ.ប.ជ បានរៀបចំ កិច្ចជុំប្រចាំខែឧសភា ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ ខ ប ជ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងប្រធានគណៈកម្មាធិការ គ ខ ប ជ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក និងអង្គការដៃគូជាតិ អន្តរជាតិ សរុប ៦០ នាក់ ស្រី៣៦នាក់ អញ្ជើញចូលរួមផងដែរ។ កិច្ចប្រជុំបានពិនិត្យនិងពិភាក្សាតាមរបៀបវារៈរួមមាន៖

១. ពិនិត្យលើសេចក្តីរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែឧសភា ឆ្នាំ ២០២៣

២. ពិនិត្យនិងពិភាក្សាលើបញ្ហាប្រឈម ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបានផ្តោតសំខាន់ទៅលើ៖

- ការគាំទ្របន្តទៅដល់កុមារដែលបានធ្វើការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្ម នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ដោយផ្តល់ជាសម្ភារសិក្សា សម្លៀកបំពាក់ និងការឧបត្ថម្ភកុមារសម្រាប់ការរៀនបំប៉នបន្ថែម។

-ជំរុញដល់អាជ្ញាធរមូលដ្ឋានពង្រឹងទៅលើការតាមដានត្រួតពិនិត្យលើករណីរៀបការផ្ទុយពីធន្ទៈ ដែលបានធ្វើសមាហរណកម្មត្រឡប់ទៅមូលដ្ឋានវិញ និងពង្រឹងទៅលើការផ្សព្វផ្សាយអំពីហានិភ័យនៃការនាំចេញទៅក្រៅប្រទេសដើម្បីរៀបការជាមួយជនបរទេសខុសច្បាប់ (ការរៀបការផ្ទុយពីធន្ទៈ) នៅតាមមូលដ្ឋាន។

-ជំរុញលើការអនុវត្ត និងស្រាវជ្រាវ ការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ និងផ្លូវចិត្តទៅលើកុមារដែលសង្ស័យទទួលរងការរំលោភបំពានតាមប្រព័ន្ធអនឡាញ។

-ជំរុញ និងពង្រឹងទៅការទប់ស្កាត់ការរំលោភបំពានផ្លូវភេទទៅកុមារ ការកេងប្រវ័ញ្ចគ្រប់រូបភាព អំពើហិង្សាគ្រប់ប្រភេទ អំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ នីតិវិធីនៃការធ្វើការ ចំណាកស្រុកដោយសុវត្ថិភាព គុណវិបត្តិនៃការធ្វើចំណាកស្រុក និងត្រូវផ្សព្វផ្សាយអំពីឱកាសការងារក្នុងស្រុក និងការទទួលការ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីធ្វើការទប់ស្កាត់ការធ្វើចំណាកស្រុកស្វែងរកការងារ នៅក្រៅ ប្រទេស ៕

# ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០២៣

## សេចក្តីជូនដំណឹងពុកម៉ែអ៊ុំពូមីង និងបងប្អូនពលករកំពុងស្នាក់នៅនិងធ្វើការនៅថៃ

https://www.facebook.com/la.in.thailand ? អនុព័ន្ធការងារអេមស្ថានទូតកម្ពុជានៅថៃ 29/05/2023

បញ្ជប់ជាបន្ទាន់៖ សេចក្ដីជូនដំណឹងពុកម៉ែអ៊ុំពូមីង និងបងប្អូនពលករកំពុងស្នាក់នៅ និងធ្វើការនៅថៃ មេត្តាជ្រាបចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ អគ្គនាយកការងារ នៃក្រសួងការងារប្រចាំប្រទេសថៃ តម្រូវឲ្យសហគ្រាសរោងចក្រ និងអ្នកត្រូវការកម្លាំងពលករកម្ពុជានិងឡាវ តម្រូវដាក់ពាក្យស្នើសុំDemandនៅតាមមន្ទីរការងារខេត្តដែលខ្លួនកំពុងរស់នៅនិងការិយាល័យនៃនាយកការងារ នៃអគ្គការងារប្រចាំប្រទេសថៃ ទីក្រុងបាងកក ប៉ុណ្ណោះ។

#នេះជាចំណុចល្អណាស់

-ការស្នើសុំDemandនៅតាមខេត្តមានរយៈពេល ៧ថ្ងៃ ប៉ុណ្ណោះ ពីមុនមានរយៈយូរ នៅពេលការស្នើសុំនៅក្រសួងខាងថៃ។

-នេះជាចំណុចល្អណាស់សម្រាប់ជនជាតិខ្មែរ និងជនជាតិឡាវ ដែលចង់មកធ្វើការនៅថៃ មិនរងចាំយូរដីចមុខ ពិសេសសហគ្រាសរោងចក្រនិងអ្នកត្រូវការពលកម្មបរទេស គឺសប្បាយចិត្តទៅវិញ ព្រោះពីដើរមកការស្នើសុំDemandមានរយៈពេលយូរខ្លាំង។ហើយក៏គុណក្រសួងនៅខ្មែរតែងតែដោះស្រាយបញ្ហារបស់ពលករកម្ពុជា។

ស្នើសុំបញ្ឈប់ជាបន្ទាន់ក្រុមមេៗពលករ និងអ្នករកស៊ីរឹស័យពលករដែលផ្សព្វផ្សាយព័ត៌មានដល់ពលករក្នុងប្រទេសថៃ គ្មានមូលដ្ឋានឯកសារច្បាស់លាស់និងបានបង្កភាពជ្រួលច្របល់ពលករនៅថៃ។

## ការពង្រឹងសមត្ថភាពដល់ មន្ត្រីនគរបាលយុត្តិធម៌ និងអាជ្ញាធរស្រុក ឃុំ នៅក្នុងស្រុកស្រីស្នំ និងស្រុកក្រឡាញ់

https://www.facebook.com/deputygovernoryousophear ? 30/05/2023

ខេត្តសៀមរាប ៖ ថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពលើការអនុវត្តច្បាប់ស្តីពី យុត្តិធម៌អនីតិជន និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាដោយសមស្រប ដល់មន្ត្រីមានសមត្ថកិច្ចនៅថ្នាក់ក្រុង ស្រុក ជាអភិបាលរងទទួលបន្ទុក អធិការ អធិការរងទទួលបន្ទុកព្រហ្មទណ្ឌនិងប្រយុទ្ធប្រឆាំងគ្រឿងញៀន កងរាជអាវុធហត្ថ ស្រុក ក្រុង មន្ត្រីការិយាល័យសុខុមាលភាពសង្គម ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក ឃុំ និងនាយ នាយរងប៉ុស្តិ៍ ឃុំ ក្នុងស្រុកស្រីស្នំ និងស្រុកក្រឡាញ់ សរុបចំនួន ៧៨នាក់ ស្រី ២៥នាក់ ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ។ វគ្គបណ្តុះបណ្តាលខាងលើប្រព្រឹត្តទៅដោយមានការហការរៀបចំនិងគាំទ្រដោយរដ្ឋបាលសាលាខេត្តសៀមរាប អង្គការមូលនិធិអេ២១ អង្គការជីវិតនៅកម្ពុជា និងអង្គការមូលនិធិអន្តរជាតិហាការ ព្រមទាំងមានការគាំទ្របច្ចេកទេសពីស្នងការនដ្ឋាននគរបាលខេត្តផងដែរ។

វគ្គបណ្តុះបណ្តាលរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តនៅថ្នាក់មូលដ្ឋាន ឱ្យបានយល់ដឹងបន្ថែម អំពីច្បាប់ គោលនយោបាយដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កិច្ចការពារ

កុមារពីការរំលោភបំពាននានា និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាដោយសមស្រប។ វគ្គបណ្តុះបណ្តាលបានផ្តោតលើទៅប្រធានសំខាន់ៗរួមមាន៖

១. រចនាសម្ព័ន្ធ យន្តការគាំទ្រ និងការអនុវត្តតួនាទីភារកិច្ច របស់គណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ រាជធានី-ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់។

២. ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ៖

- ក្រមសីលធម៌ក្នុងការធ្វើសម្ភាសន៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីសង្គមកិច្ច

- វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍រហ័ស (សារៈសំខាន់នៃការប្រើប្រាស់ទម្រង់សម្ភាសន៍ខ្លី និងសូរចនាករស្តីពី អំពើជួញដូរមនុស្ស)។

៣. នីតិវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់

៥. នីតិវិធីកុមារមេត្រី

៦. ការផ្តល់សេវារបស់អង្គការមូលនិធិអេ២១ សម្រាប់កុមារ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

៧. ការផ្តល់សេវារបស់អង្គការជីវិតនៅកម្ពុជា (TLC) សម្រាប់កុមារ

មានប្រសាសន៍នៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាល លោកស្រី យូ សុភា អភិបាលរងខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជំរុញដល់មន្ត្រីនគរបាលយុត្តិធម៌ពង្រឹងទៅលើការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពិសេសការអនុវត្តនីតិវិធីបង្វែរកុមារទំនាស់នឹងច្បាប់ នីតិវិធីកុមារមេត្រី ឱ្យបានត្រឹមត្រូវ ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ។ បន្ថែមពីនោះលោកស្រី ក៏បានជំរុញទៅក្រុមការងារនៅថ្នាក់ឃុំសង្កាត់បន្ថែម ត្រូវរៀបចំផែនការសកម្មភាព និងបង្កើនកញ្ចប់ថវិកាសម្រាប់អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយដាក់បញ្ចូលទៅក្នុងកញ្ចប់សេវាសង្គមឱ្យបានសមស្រប និងមានការឆ្លើយតបទៅនឹងតម្រូវការងារនៅក្នុងមូលដ្ឋាននីមួយៗ។

## តើបុគ្គលដែលចែកចាយរូបភាពអាសអាភាស ត្រូវផ្តន្ទាទោសបែបណា?

https://www.kampucheathmey.com/local-news/487300 ថ្ងៃចន្ទ ២៩ ឧសភា ២០២៣ដោយ អុន ស្រីមាន

ក្នុងសម័យឌីជីថល មនុស្សងាយនឹងរងគ្រោះបំផុតចំពោះពាក្យលួងលោម បោកបញ្ឆោតឱ្យផ្ញើរូបអាក្រាតកាយរបស់ខ្លួន ជាថ្នូរនៃការស្រឡាញ់ ឬដោះដូរអ្វីមួយមកវិញ។ ជាពិសេស ជនបោកប្រាស់ទាំងនោះ តែងប្រើពាក្យស្រឡាញ់ដើម្បី លួងលោមពួកគេ និងគម្រាមបង្ហោះរូបទាំងនោះនៅលើបណ្តាញសង្គម ឬ Internet ។ កុមារក៏មានបញ្ហាប្រឈមដូចគ្នា។ តើបុគ្គលដែលប្រព្រឹត្តអំពើទាំងនេះ មានទោសបែបណាខ្លះ?

កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចបានចុះឃាត់ខ្លួនបុរសម្នាក់ នៅខេត្តកណ្តាល បន្ទាប់ពីរូបគេបានស្គាល់គ្នាជាមួយក្មេងស្រីម្នាក់តាមប្រព័ន្ធបណ្តាញសង្គម និងគម្រាមបង្ហោះរូបភាពអាក្រាត និងអាសអាភាសរបស់ក្មេងស្រីនោះជាសាធារណៈ ដែលបង្កជាភាពភ្ញាក់ផ្អើលយ៉ាងខ្លាំងដល់អ្នកនៅក្នុងបណ្តាញសង្គម។

បើតាមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ របស់កម្ពុជា គឺក្នុងមាត្រា៣៩ បានចែងថា ជនណាដែល កាន់កាប់ ចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាពអាសអាភាសត្រូវមានទោសពី ៧ថ្ងៃ ដល់១ខែ និងពិន័យជាទឹកប្រាក់ចំនួន ១សែនរៀល ដល់២សែនរៀល។

ក្នុងមាត្រាដដែល សម្រាប់បុគ្គលណាដែលបានផលិតរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលបំណងយកទៅប្រើប្រាស់ ឬ ប្រព្រឹត្តបទល្មើសណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ដល់២លានរៀល។

ចំពោះច្បាប់ដដែលសម្រាប់កុមារវិញ នៅក្នុងមាត្រា៤១ ទាក់ទងនឹងរូបភាព និងសម្ភារៈអាសអាភាសនៃកុមារបានចែងមកថា ជនណាដែលកាន់កាប់ ចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ដល់៥ឆ្នាំ និងពិន័យជាទឹកប្រាក់ចំនួន ៤លានរៀល ដល់១០លានរៀល។ ជនណាដែលផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ឆ្នាំ។ មាត្រា៤០នៃច្បាប់នេះ បានឱ្យនិយមន័យចំពោះរូបភាព និងសម្ភារៈអាសអាភាសនៃកុមារថា ជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជារូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជន៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ១នាក់

https://freshnewsasia.com/index.php/en/localnews/293349-2023-05-29-12-58-16.html 2023-05-29 07:58pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩០២ករណី មានមនុស្ស ២,២៨៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៦៥សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,៣២៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៤នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៧ករណី៕

# ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០២៣

## ជនជាតិឥណ្ឌាម្នាក់ត្រូវបានគេអះអាងថាបានចាញ់បោកក្រុមជួញដូរមនុស្សនៅកម្ពុជា

https://www.khmertimeskh.com/501299022// Khmer Times May 30, 2023

យុវជនអាយុ២១ ឆ្នាំម្នាក់មកពីទីក្រុង Hyderabad បានអះអាងថា ខ្លួនត្រូវបានសន្យាថា នឹងទទួលបានការងារជាប្រតិបត្តិករបញ្ចូលទិន្នន័យនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែត្រូវបានបង្ខំឱ្យធ្វើសកម្មភាពបោកប្រាស់ និងជំរិតប្រាក់ពីមនុស្ស។ Mohammed Ismail Ullah បានស្វែងរកជំនួយពីរដ្ឋមន្ត្រីការបរទេស S Jaishankar ដើម្បីខ្លួនអាចត្រលប់ទៅ Telangana វិញ។ យុវជនរូបនេះមានការភ័យខ្លាចដល់អាយុជីវិត ដោយទទួលបានការគំរាមកំហែងពីថៅកែខ្លួន។ យុវជនរូបនេះបានអះអាងថាលិខិតឆ្លងដែនរបស់ខ្លួនត្រូវបានដកហូតហើយត្រូវបានគេវាយដំប្រសិនបើបដិសេធមិនធ្វើតាមនូវអ្វីដែលគេបានប្រាប់។ Ismail បានប្រាប់ STOI ពីទីក្រុងភ្នំពេញកាលពីថ្ងៃសៅរ៍ថាលិខិតឆ្លងដែនត្រូវបានបំផ្លាញដោយមនុស្សដែលបានជ្រើសរើសគាត់ឱ្យមកធ្វើការនៅប្រទេសកម្ពុជា។

Ismail និយាយថា"ខ្ញុំត្រូវគេវាយដំយ៉ាងខ្លាំង ហើយខ្ញុំមានរបួសជាច្រើន»។ ជននេះរងរបួសត្រង់ក្បាល និងជើង។ ដោយចង់ធ្វើការផ្នែកបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រទេសថៃ ជនជាតិឥណ្ឌាជាង៣០០ នាក់ រួមទាំង Telugus ត្រូវបានក្លាយជាជនរងគ្រោះក្នុងប្រទេសមីយ៉ាន់ម៉ា តាំងពីខែកញ្ញា ឆ្នាំ ២០២២។ ពួកគេត្រូវបានបង្ខំឱ្យធ្វើឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ហើយអ្នកដែលបដិសេធមិនស្តាប់បង្គាប់ត្រូវបានវាយដំ និងឆក់ដោយអគ្គិសនី។ Ismail បាននិយាយថា "ខ្ញុំបានទៅសុំជំនួយពីស្ថានទូតឥណ្ឌា។ ពួកគេបានស្នើឱ្យខ្ញុំដាក់ពាក្យបណ្តឹងជាមួយនគរបាលក្នុងស្រុក ប៉ុន្តែខ្ញុំបារម្ភថាតើក្រុមហ៊ុននឹងធ្វើអ្វីមកលើខ្ញុំ។ ខ្ញុំភ័យខ្លាច ព្រោះខ្ញុំត្រូវគេធ្វើទារុណកម្មលើរាងកាយ»។

រូបថតធ្វើទារុណកម្មរបស់ជននេះត្រូវបានចែករំលែកដោយបុគ្គលិកសង្គមនិងមេដឹកនាំ MBT លោក Amjed Ullah Khan នៅលើ Twitter ដែលបានជំរុញឱ្យលោករដ្ឋមន្ត្រី Jaishankar ជួយសង្គ្រោះ Ismail ពីកណ្តាប់ដៃរបស់ថៅកែ។នៅពេលមកដល់ប្រទេសកម្ពុជា Ismail ត្រូវបានបង្ខំអោយបោកប្រាស់មនុស្សនិងយកប្រាក់ពីពួកគេ។ នៅក្នុងលិខិតមួយផ្ញើទៅកាន់ក្រសួងការបរទេសឥណ្ឌា បងប្រុសរបស់ Ismail លោក Mohammed Yaseen Khan បាននិយាយថា ប្អូនប្រុសខ្លួនបានបន្តការសិក្សាសញ្ញាបត្រនៅប្រទេសសិង្ហបុរី ហើយបានត្រលប់ទៅ Telangana វិញនៅថ្ងៃទី១៩ ខែកុម្ភៈឆ្នាំនេះ។ ពេលនៅសិង្ហបុរី មានមនុស្សម្នាក់ដែលមកពីប្រទេសឥណ្ឌាបានសន្យាផ្តល់ការងារនៅកម្ពុជាអោយប្អូនរបស់ខ្លួន។

ជនជាតិឥណ្ឌានៅសិង្ហបុរីបានសុំលុយ២,៥lakhដើម្បីរត់ការដាក់ពាក្យសុំការងារ និងបន្ទាប់មកបានសុំលុយ ១lakh បន្ថែមទៀត។ Ismail បានបង់ប្រាក់ជាមុន ហើយដំបូងបានទៅទីក្រុងបាងកកតាមរយៈទិដ្ឋាការភ្ញៀវទេសចរនៅថ្ងៃទី៧ ខែមេសា។ «បន្ទាប់ពីបានទៅដល់ទីក្រុងបាងកក អ្នកបើកតាក់ស៊ីម្នាក់បានរង់ចាំគាត់ ហើយបានយកគាត់ទៅព្រំដែនកម្ពុជា។ នៅពេលដែលគាត់ចូលប្រទេស អ្នកបើកតាក់ស៊ីម្នាក់ទៀតបាននាំគាត់ដោយផ្ទាល់ទៅកាន់ក្រុមហ៊ុនដែលគាត់ត្រូវធ្វើការ"។ Ismail និយាយថា "ខ្ញុំបដិសេធមិនធ្វើការងារនោះទេ ហើយបានស្នើឲ្យបញ្ជូនខ្ញុំទៅ Telangana វិញ។ ពួកគេបដិសេធដោយនិយាយថាខ្ញុំត្រូវបង់ប្រាក់៣lakh ទៅឱ្យភ្នាក់ងារដែលយកខ្ញុំ។ ខ្ញុំត្រូវសងគេវិញនូវចំនួននោះ។ ខ្ញុំបានប្រាប់ពួកគេថាខ្ញុំមិនមានលុយច្រើនបែបនេះទេ"។ ភ្នាក់ងារដែលបានជ្រើសរើសIsmail មិនបានទាក់ទងមកខ្លួនវិញទេទោះបីជាគាត់បានព្យាយាមទាក់ទងគាត់ក៏ដោយ។ Times of India

## ការពង្រឹងសមត្ថភាព
## ដល់មន្ត្រីនគរបាលយុត្តិធម៌ និងអាជ្ញាធរស្រុក ឃុំ នៅក្នុងស្រុកអង្គរជុំ និងស្រុកវ៉ារិន

https://www.facebook.com/deputygovernoryousophear ? 31/05/2023

ខេត្តសៀមរាប ៖ ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពលើការអនុវត្តច្បាប់ស្តីពី យុត្តិធម៌អនីតិជន និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាដោយសមស្រប ដល់មន្ត្រីមានសមត្ថកិច្ចនៅថ្នាក់ក្រុង ស្រុក ជាអភិបាលរងទទួលបន្ទុក អធិការ អធិការរងទទួលបន្ទុកព្រហ្មទណ្ឌនិងប្រយុទ្ធប្រឆាំងគ្រឿងញៀន កងរាជអាវុធហត្ថ ស្រុក ក្រុង មន្ត្រីការិយាល័យសុខុមាលភាពសង្គម ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក ឃុំ និងនាយ នាយរងប៉ុស្តិ៍ ឃុំ ក្នុងស្រុកអង្គរជុំ និងស្រុកវ៉ារិន សរុបចំនួន ៧២នាក់ ស្រី ២០នាក់ ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ នៅរដ្ឋបាលស្រុកអង្គរជុំ។ វគ្គបណ្តុះបណ្តាលខាងលើប្រព្រឹត្តទៅដោយមានការហេការរៀបចំនិងគាំទ្រដោយរដ្ឋបាលសាលាខេត្តសៀមរាប អង្គការមូលនិធិអេ២១ និងអង្គការជីវិតនៅកម្ពុជា ព្រមទាំងមានការគាំទ្របច្ចេកទេសពីស្នងការនដ្ឋាននគរបាលខេត្តផងដែរ។

វគ្គបណ្តុះបណ្តាលរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តនៅថ្នាក់មូលដ្ឋាន ឱ្យបានយល់ដឹងបន្ថែម អំពីច្បាប់ គោលនយោបាយដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កិច្ចការពារកុមារពីការរំលោភបំពាននានា និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាដោយសមស្រប។ វគ្គបណ្តុះបណ្តាលបានផ្តោតលើទៅប្រធានសំខាន់ៗរួមមាន៖

១. រចនាសម្ព័ន្ធ យន្តការគាំទ្រ និងការអនុវត្តតួនាទីភារកិច្ច របស់គណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ រាជធានី-ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់។

២. ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ៖

- ក្រមសីលធម៌ក្នុងការធ្វើសម្ភាសន៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីសង្គមកិច្ច

- វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍រហ័ស (សារៈសំខាន់នៃការប្រើប្រាស់ទម្រង់សម្ភាសន៍ខ្លី និងសូរចនាករស្តីពី អំពើជួញដូរមនុស្ស)។

៣. នីតិវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់

៥. នីតិវិធីកុមារមេត្រី

៦. ការផ្តល់សេវារបស់អង្គការមូលនិធិអេ២១ សម្រាប់កុមារ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

៧. ការផ្តល់សេវារបស់អង្គការជីវិតនៅកម្ពុជា (TLC) សម្រាប់កុមារ

មានប្រសាសន៍នៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាល លោកស្រី យូ សុភា អភិបាលរងខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជំរុញដល់មន្ត្រីនគរបាលយុត្តិធម៌ពង្រឹងទៅលើការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពិសេសការអនុវត្តនីតិវិធីបង្វែរកុមារទំនាស់នឹងច្បាប់ នីតិវិធីកុមារមេត្រី ឱ្យបានត្រឹមត្រូវ ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ។ បន្ថែមពីនោះលោកស្រី ក៏បានជំរុញទៅក្រុមការងារនៅថ្នាក់ឃុំសង្កាត់បន្ថែម ត្រូវរៀបចំផែនការសកម្មភាព និងបង្កើនកញ្ចប់ថវិកាសម្រាប់អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយដាក់បញ្ចូលទៅក្នុងកញ្ចប់សេវាសង្គមឱ្យបានសមស្រប និងមានការឆ្លើយតបទៅនឹងតម្រូវការងារនៅក្នុងមូលដ្ឋាននីមួយៗ។